# ព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់

## ព្រះជាម្ចាស់បានសម្ដែងអង្គទ្រង់

## តាមរយៈព្រះបន្ទូល និង ការប្រព្រឹត្តរបស់ព្រះអង្គ

និពន្ធដោយលោក ចន ហ្វាវែល

រក្សាសិទ្ធិ © ឆ្នាំ២០០៩
ដោយក្រុមជំនុំ សាឡូម (សឹង្ហបុរី)

Copyright © 2009
by Shalom Church. All Rights Reserved.

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានផលិតសៀវភៅ «ប្រភពប្រាជ្ញា»**

ផ្ទះលេខ១១អា ផ្លូវលេខ២០០២ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ : ០២៣-៨៨៣-៤៤៥
គេហទំព័រ : www.fountofwisdomph.com

Fount of Wisdom Publishing House
#11A, Street 2002, Tuk Thla, Russei Keo, Phnom Penh, Cambodia
Tel : 023 883 445
E-mail : fountofwisdom@online.com.kh
Website: www.fountofwisdomph.com

ទទួលការអនុញ្ញាតឲ្យបកប្រែ កែសម្រួល និង បោះពុម្ពផ្សាយ ដោយ
គ្រេស ផាប្លីខេសិន ត្រាស (អង់គ្លេស) និង ក្រុមជំនុំ សាឡូម (សឹង្ហបុរី)
Translated, edited and printed with permission of and in agreement with

| | | |
|---|---|---|
| Grace Publications Trust (UK) | and | Shalom Church |
| 139 Grosvenor Avenue, | | 8 New Industrial Road |
| London, N5 2NH. | | # 03-01, Singapore 536200 |

បោះពុម្ពនៅរោងពុម្ព ហាវ៉ៃ ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ខែតុលា ឆ្នាំ២០០៩
Printed at Hawaii Printing House in Phnom Penh, Cambodia. October 2009.

សូមជួយរក្សាសិទ្ធិ។ ហាមការបោះពុម្ពចម្លងជាសាធារណៈ ឬថតទុកដាក់នៅក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រដែលយកមក ប្រើការបានវិញឬបញ្ជូនចេញ និង តាមរយៈម៉ាស៊ីនណាមួយ មធ្យោបាយអេឡិចត្រូនិក លក្ខណៈបច្ចេកទេសថត ចម្លង ឬផ្តិតយកពីម៉ាស៊ីន (ហ្វូតូកូពី) ដោយមិនបានសុំអនុញ្ញាតពីអ្នកបោះពុម្ពជាមុន។

All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted, in any form or by any means, electronic, mechanical, photocopying, recording, or otherwise, without the prior written permission of the publisher.

# ព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់

**ជាសៀវភៅសង្ខេប ហើយមានលក្ខណៈងាយស្រួលអាន**
**ដែលចេញមកពីសៀវភៅដ៏ល្អមួយ មានចំណងជើងថា**
**«ការប្រតិបត្តិនៃព្រះ ឬអាថ៌កំបាំងនៃព្រះតម្រិះសម្រេច»**
**និពន្ធដោយលោក ចន ហ្វាវែល**
**បោះពុម្ពលើកទី១ នៅឆ្នាំ១៦៧៧**


**រៀបចំដោយ ហើរី ម៉កហ្វ័ដ**
**អ្នកកែសម្រួលទូទៅ ដោយលោក ជេ.ខេ. ដាវីស៍**


*(សម្រាប់សៀវភៅជាភាសាអង់គ្លេស)*

# មាតិកា

**សេចក្ដីផ្ដើម** VII

**ជំពូក១**

ការថែរក្សាយ៉ាងពិសេសរបស់ព្រះជាម្ចាស់ចំពោះរាស្ត្រទ្រង់ ...................... ១

**ជំពូក២**

របៀបដែលព្រះជាម្ចាស់ប្រព្រឹត្តតាមព្រះតម្រិះសម្រេចរបស់ទ្រង់នៅក្នុងជីវិតយើង .. ១១

**ជំពូក៣**

ហេតុអ្វីបានជាយើងត្រូវគិតយ៉ាងជ្រៅពីព្រះតម្រិះសម្រេចដ៏វិសេសនោះ .......... ២៩

**ជំពូក៤**

យើងគួរតែគិតពីព្រះតម្រិះសម្រេចដ៏ពិសេសនេះយ៉ាងដូចម្ដេច ................... ៣១

**ជំពូក៥**

ភាពរីករាយ និង ប្រយោជន៍ដែលបានមកពីការសម្លឹងមើលអ្វី

ដែលព្រះជាម្ចាស់ធ្វើនៅក្នុងព្រះតម្រិះសម្រេច ................................. ៤១

**ជំពូក៦**

ផលវិបាកនៃជំពូកមុនៗ.................................................... ៦១

**ជំពូក៧**

បញ្ហាដែលមិនសាំញុំ ................................................... ៦៥

*(ជំពូកនេះ ក៏រួមបញ្ចូលជាមួយនឹងជំពូក៨ របស់លោកហ្វាវែលដែរ)*

**ចំណារបន្ថែម** ........................................................ ៨៥

**អំពីអ្នកនិពន្ធ** ........................................................ ៨៧

# សេចក្ដីផ្ដើម

**«ទូលបង្គំនឹងអំពាវនាវដល់ព្រះដ៏ខ្ពស់បំផុត គឺដល់ព្រះ**
**ដែលទ្រង់សម្រេចគ្រប់ការឱ្យទូលបង្គំ»**

*ទំនុកដំកើង ៥៧:២*

មានវិធីពីរយ៉ាង ដែលព្រះជាម្ចាស់បានសម្ដែងអង្គទ្រង់ផ្ទាល់មកដល់ខ្ញុំ គឺតាមរយៈព្រះបន្ទូល និង ការប្រព្រឹត្តរបស់ព្រះអង្គ។ សិរីរុងរឿងដ៏អស្ចារ្យនៃការប្រព្រឹត្តរបស់ព្រះជាម្ចាស់នៅក្នុងការបង្កើតពិភពលោក ហើយព្រះតម្រិះសម្រេចនោះបញ្ជាក់ពីអ្វីដែលព្រះអង្គបានមានបន្ទូល នៅក្នុងសំណេរនៃព្រះបន្ទូលទ្រង់។

មានសេចក្ដីរីករាយយ៉ាងអស្ចារ្យ នៅពេលយើងសង្កេតមើលឃើញព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់ចំពោះរាស្ត្រទ្រង់។ ព្រះតម្រិះសម្រេចនេះ មិនត្រឹមតែនាំពួកគេទៅនគរស្ថានសួគ៌ប៉ុណ្ណោះទេ ប៉ុន្តែបាននាំនគរស្ថានសួគ៌មកឯពួកគេវិញផង។ ព្រះជាម្ចាស់ដែលមានប្រាជ្ញាបំផុត បានតម្រង់មនុស្សទាំងអស់ឲ្យសរសើរដំកើងដល់ព្រះអង្គ តែទ្រង់បាននាំសុភមង្គលមកឲ្យរាស្ត្ររបស់ទ្រង់វិញ ហើយទោះបីជាមនុស្សលោកទាំងមូលកំពុងរវល់ក្នុងការរៀបចំក្ដោង និង ច្រវា ដើម្បីរុញច្រាននាវាជីវិតក្នុងគោលបំណងផ្ទុយពីព្រះជាម្ចាស់ក៏ដោយ ក៏ភាពរីករាយដ៏អស្ចារ្យកើតមាននៅពេលយើងមើលឃើញរបៀបដែលពិភពលោក បានសម្រេចតាមគោលបំណងរបស់ព្រះជាម្ចាស់ ដោយសារការជំទាស់របស់មនុស្សចំពោះគោលគំនិតរបស់ព្រះអង្គ ការធ្វើតាមបំណងព្រះហឫទ័យទ្រង់ដោយការទប់ទល់ និង ពង្រីកក្រុមជំនុំរបស់ទ្រង់ដោយការខ្ចាត់ខ្ចាយរបស់ក្រុមជំនុំទាំងនោះវិញ។

មានភាពសប្បាយរីករាយមួយចំនួននៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ ដែលអស្ចារ្យណាស់មិនអាចពិពណ៌នាបាននោះ គឺជាភាពសប្បាយរីករាយនៃការសិក្សាពីព្រះតម្រិះសំរេច តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក។ សូមសាកល្បងដោយខ្លួនឯង ភ្លក់មើល នោះអ្នកនឹងឃើញ ហើយមិនត្រូវឲ្យមានអ្នកណាមកអន្ទងអ្នកឲ្យជឿឡើយ *«ទូលបង្គំនឹងអំពាវនាវដល់ព្រះដ៏ខ្ពស់បំផុត គឺដល់ព្រះដែលទ្រង់សម្រេចគ្រប់ការឲ្យទូលបង្គំ»* (ទំនុកដំកើង ៥៧:២)។

នៅពេលដាវីឌអធិស្ឋាននូវឃ្លានៃកណ្ឌទំនុកដំកើង ជំពូក៥៧ ខាងលើនេះ គាត់កំពុងតែស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដោយព្រោះស្តេចសូលរកធ្វើឃាតគាត់ (១សាំយូអែល ២៤:១, ២)។ ព្រះជាម្ចាស់បានឆ្លើយចំពោះសំណូមពររបស់ដាវីឌ ដោយនាំគាត់ឲ្យឆ្លងផុតពីភាពគ្រោះថ្នាក់នោះ។ ព្រះជាម្ចាស់តែងតែឆ្លើយតបចំពោះការអធិស្ឋានរបស់កូនទ្រង់គ្រប់រូប។ ការប្រព្រឹត្តរបស់ព្រះអង្គនេះ កើតឡើងនៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់យើង ចាប់តាំងពីការតូចរហូតដល់ការធំ ហើយយើងហៅការនេះថា «ការប្រតិបត្តិ»។ បទពិសោធន៍របស់ដាវីឌ ពីការប្រព្រឹត្តរបស់ព្រះនៅក្នុងជីវិតគាត់ កាលពីអតីតកាលនោះ បានផ្តល់ឲ្យគាត់មានសេចក្តីសង្ឃឹម និង មានកម្លាំងដើម្បីអំពាវនាវទៅព្រះអង្គនៅពេលដែលមានទុក្ខលំបាក។ ដូច្នេះ នៅក្នុងសម័យកាលរបស់យើងនេះ គ្រីស្ទបរិស័ទគួរគិតពីរបៀបដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់គេ កាលពីអតីតកាល ដើម្បីឲ្យក្តីសង្ឃឹម និង ជំនឿរបស់គេរីកចំរើនកាន់តែខ្លាំងឡើង។

ប៉ុន្តែ រាស្ត្ររបស់ទ្រង់មិនយល់ទាំងអស់ ពីអ្វីដែលបានកើតឡើងចំពោះពួកគេនៅតាមផ្លូវទៅកាន់នគរស្ថានសួគ៌នោះទេ សូម្បីតែលោកពេត្រុសក៏មិនដឹងដែរថា អ្វីដែលព្រះគ្រីស្ទធ្វើចំពោះគាត់ ខណៈដែលទ្រង់លាងជើងឲ្យគាត់ ហើយទ្រង់ក៏បានបញ្ជាក់ប្រាប់ពេត្រុសដែរថា គាត់នឹងយល់ច្បាស់ពីការដែលកើតឡើងទាំងនោះ នៅពេលក្រោយ (យ៉ូហាន ១៣:៧)។ ពេលដែលយើងទៅដល់នគរស្ថានសួគ៌ នោះយើងនឹង

មើលឃើញមិនត្រឹមតែជាកន្លែងមួយដែលស្អាតប៉ុណ្ណោះទេ ប៉ុន្តែជាងនោះទៅទៀត យើងនឹងមើលឃើញពីរបៀប ដែលយើងបានមកដល់ផង នោះហាក់ដូចជាការមើលឃើញផ្នែកផ្សេងៗនៃនាឡិកាដៃអ៊ីចឹងដែរ ដំបូងយើងមើលឃើញបំណែកដែលនៅដាច់ចេញពីគ្នា បន្ទាប់មកនឹងឃើញនាឡិកាទាំងមូល ដែលគេបានដាក់បញ្ចូលគ្នាវិញ ហើយផ្នែកនីមួយៗក៏ដំណើរការយ៉ាងល្អជាមួយនឹងផ្នែកផ្សេងទៀត។ នោះជារឿងគួរឲ្យចាប់អារម្មណ៍ដែលឃើញពីផែនការនៃព្រះតម្រិះសម្រេចទាំងមូល និង មួយទៀតជាការមើលឃើញហេតុផលដ៏ត្រឹមត្រូវ ពីសកម្មភាពរបស់ព្រះអង្គតាមទស្សនៈមួយ ទោះបីជាទស្សនៈរបស់យើងនៅពេលបច្ចុប្បន្ននេះ មិនសូវល្អ បើប្រៀបធៀបទៅនឹងទស្សនៈដែលយើងនឹងឃើញនៅនគរស្ថានសួគ៌ នោះក៏នៅតែមានភាពរីករាយជាច្រើននៅក្នុងទស្សនៈនាបច្ចុប្បន្ននេះដែលខ្ញុំអាចហៅថា «ជាផ្នែកតូចមួយនៃនគរស្ថានសួគ៌»។

# ជំពូក ១

## *ការថែរក្សាយ៉ាងពិសេសរបស់ព្រះជាម្ចាស់ចំពោះរាស្ត្រទ្រង់*

ព្រះគ្រីស្ទជាសិរសាឯលរាស្ត្រទ្រង់នៅក្នុងក្រុមជំនុំ ហើយទ្រង់ក៏ជាអ្នកគ្រប់គ្រងពិភពលោកទាំងមូលដែរ។ ព្រះអង្គគ្រប់គ្រងព្រឹត្តិការណ៍ទាំងអស់នៅលើពិភពលោកបានល្អបំផុតចំពោះក្រុមជំនុំ។ គោលបំណងរបស់ខ្ញុំនៅទីនេះ មិនសូវទាក់ទិនប៉ុន្មានទៅនឹងអ្នកដែលមិនជឿព្រះនោះទេ ខ្ញុំចង់នាំអស់អ្នកដែលនិយាយថា មានព្រះដែលរស់មែននោះថា ការប្រព្រឹត្តតាមព្រះតម្រិះសំរេចដ៏ពិសេសរបស់ទ្រង់ មិនមែនគ្រាន់តែជាឧបទ្ទវហេតុនោះទេ។ មានមនុស្សជាច្រើនដែលហៅខ្លួនឯងថាជាគ្រីស្ទបរិស័ទ ដោយសម្លឹងមើលទៅអ្វីដែលកើតឡើងនៅក្នុងជីវិតរបស់គេ ដូចជាព្រឹត្តិការណ៍ធម្មតា។ ពួកគេគិតពីកិច្ចការនៅលើពិភពលោក និង ពីពួកបរិសុទ្ធរបស់ព្រះដែលមិនមែនគ្រប់គ្រងដោយព្រះតម្រិះសំរេច ប៉ុន្តែជាបុព្វហេតុដែលកើតឡើងជាធម្មតាវិញ គំនិតនោះមានន័យថា គេរស់នៅដោយគិតថាគ្មានព្រះជាម្ចាស់ទេវិញ! សូមឲ្យអស់អ្នកណាដែលគិតយ៉ាងដូច្នេះ ពិចារណាពីសំណួរខាងក្រោមនេះ ៖

**១•** *រាស្ត្រទ្រង់ទទួលសេចក្តីសង្គ្រោះពីភាពគ្រោះថ្នាក់ និង អំពើអាក្រក់តាមរយៈអំណាចមួយដែលឧត្តុង្គឧត្តមជាងអំណាចធម្មជាតិជាច្រើនដង ហើយសេចក្តីសង្គ្រោះនោះមានលក្ខណៈជាញឹកញាប់តែងតែប្រឆាំងនឹងធម្មជាតិទៅវិញ តើនោះកើតឡើងយ៉ាងដូចម្តេច?*

ទឹកអាចជន់ហូរហៀរ ហើយធ្វើឲ្យអ្នូរទាំងអស់លិចលង់បាន ប៉ុន្តែសមុទ្រក្រហមបានញែកចេញពីគ្នាដូចជញ្ជាំងខណ្ឌផ្ទៃទឹក ក៏បានធ្វើឲ្យកូនចៅអ៊ីស្រាអែលធ្វើដំណើរឆ្លងកាត់ដោយសុវត្ថិភាព។ ភ្លើងអាចឆេះសន្ធោសន្ធៅដល់កំរិតខ្ពស់បំផុតបាន ប៉ុន្តែនៅពេលស្តេចនេប៊ូក្នេសាជាស្តេចបាប៊ីឡូន បង្គាប់ឲ្យបោះកម្លោះបីនាក់ជាសាសន៍យូដាដែលជឿព្រះជាម្ចាស់ចូលទៅក្នុងគុកភ្លើង ពេលនោះអណ្តាតភ្លើងគ្មានអំណាចលើខ្លួនគេសោះ សូម្បីតែសក់ក្បាលគេក៏មិនបានរួញដែរ ប៉ុន្តែពេលនោះអណ្តាតភ្លើងបានឆាបហើយឆេះសម្លាប់ពួកអ្នកដែលបានលើកកម្លោះទាំងបីនាក់នោះ បោះចូលទៅក្នុងគុកភ្លើងនោះទៅវិញ។ ជាការធម្មតាទេ ដែលសត្វព្រៃដូចជាសត្វតោ នៅពេលដែលវាឃ្លានវាត្រូវសំឡាប់សត្វ ឬមនុស្សធ្វើជាអាហារ ប៉ុន្តែសត្វតោនៅក្នុងរូងជាកន្លែងដែលគេដាក់ដានីយ៉ែលអស់រយៈពេលមួយយប់ មិនបានធ្វើទុក្ខដល់គាត់ឡើយ។

**២.** *ប្រសិនបើបុព្វហេតុធម្មជាតិ មិនមានការបង្គាប់ពីព្រះតម្រិះសម្រេចដ៏ពិសេសនោះទេ តើបុព្វហេតុជាលក្ខណៈធម្មជាតិនោះ អាចដំណើរការជាមួយគ្នាដោយរបៀបចម្លែកៗ ដើម្បីឲ្យមានប្រយោជន៍ដល់មនុស្សសុចរិតយ៉ាងដូចម្តេច?*

នៅក្នុងសាច់រឿង ដែលលោកយ៉ូសែបបានឡើងធ្វើជានាយករដ្ឋមន្ត្រីនៃប្រទេសអេស៊ីព្ទ នោះតាមជំហានទាំង១២នៃព្រះតម្រិះសម្រេច។ ប្រសិនបើជំហានមួយមិនបានសម្រេច សាច់រឿងនោះនឹងមានលទ្ធផលខុសគ្នា។ នៅក្នុងសម័យនាងអេសធើរ មានកិច្ចការនៃព្រះតម្រិះសម្រេចចំនួនប្រាំពីរ ដែលត្រូវគ្នាដើម្បីទំលាក់លោកហាម៉ានជាមនុស្សអាក្រក់ និង ជួយសង្គ្រោះពួកយូដាចេញពីការបំផ្លាញ។ ព្រះជាម្ចាស់អាចធ្វើការផ្សេងៗបានដើម្បីថែរក្សារាស្ត្រទ្រង់ ដូចជាកម្មករដែលអាចប្រើប្រាស់ឧបករណ៍គ្រប់ប្រភេទនៅក្នុងកិច្ចការរបស់គាត់។ ដូចគ្នានឹងកម្មករនោះដែរ ដែលព្យាយាមធ្វើឲ្យ

ឈើដែលគគ្រើមក្លាយទៅជាសិល្បៈយ៉ាងល្អ គឺប្រាកដជាមានដៃដែលមានជំនាញបំផុត បានប្រើប្រាស់ឧបករណ៍នៅក្នុងរោងនៃព្រះតម្រិះសម្រេចនោះហើយ។

**៣.** *ប្រសិនបើកិច្ចការរបស់រាស្ត្រទ្រង់ មិនបានគ្រប់គ្រងដោយព្រះតម្រិះសម្រេចជាពិសេសនោះទេ តើហេតុអ្វីបានជាវិធីដ៏ឆ្លាត ហើយមានអំណាចបំផុត ដែលបានប្រើប្រាស់ដើម្បីបំផ្លាញពួកគេមិនមានឥទ្ធិពល ហើយវិធីដែលខ្សោយហើយឥតកម្លាំង ដែលបានប្រើប្រាស់សម្រាប់សុវត្ថិភាពរបស់ពួកគេនោះ មានជ័យជំនះទៅវិញ?*

នេះជាអំណាច និង ជំនាញដ៏អស្ចារ្យដែលស្តេចផារ៉ោនព្យាយាមប្រើ ដើម្បីបំផ្លាញពួកអ៊ីស្រាអែលជារាស្ត្ររបស់ព្រះជាម្ចាស់ ដូច្នេះវិធីនេះមើលទៅហាក់ដូចជាហេតុផលធម្មជាតិមិនអាចចៀសវាងបានទេ។អធិរាជរ៉ូមដែលបានដណ្តើមពិភពលោកបានប្រើប្រាស់អំណាចទាំងប៉ុន្មានរបស់គេ ប្រឆាំងនឹងក្រុមជំនុំដែលក្រីក្រ ហើយគ្មានអ្វីការពារខ្លួន ក៏ប៉ុន្តែក្រុមជំនុំនៅតែមានជីវិតរស់ដោយកម្លាំងដដែល! ប្រសិនបើការប្រើអំណាចនោះតែពាក់កណ្តាល ដើម្បីប្រឆាំងទៅនឹងមនុស្សផ្សេងទៀត នោះក៏អាចបំផ្លាញពួកគេបានទាំងស្រុងដែរ។ យើងឃើញថា ព្រះជាម្ចាស់បានបំពេញសេចក្តីសន្យារបស់ទ្រង់យ៉ាងល្អ នៅក្នុងព្រះបន្ទូលត្រង់នេះ *«ពីព្រោះអញនឹងធ្វើឲ្យអស់ទាំងនគរ... អញនឹងមិនបណ្តោយឲ្យឯងនៅ ដោយឥតវាយផ្ចាលឡើយ»* (យេរេមា ៣០:១១) ហើយនិង *«ឯគ្រឿងសស្ត្រាវុធណាដែលគេធ្វើឡើង នោះគ្មានណាមួយនឹងអាចទាស់នឹងឯងបានឡើយ»* (អេសាយ ៥៤:១៧)។

ម្យ៉ាងវិញទៀត ព្រះជាម្ចាស់បានសម្រេចជ្រើសរើសប្រើវិធីដែលខ្សោយ ហើយមិនទំនង ដើម្បីបង្កើតជំនឿគ្រីស្ទបរិស័ទនៅលើសកលលោក។ ព្រះគ្រីស្ទមិនបាន

ជ្រើសរើសមនុស្សដែលមានសិទ្ធិអំណាច នៅក្នុងរាជវាំងរបស់ព្រះមហាក្សត្រទេ ប៉ុន្តែព្រះអង្គបានជ្រើសរើសមនុស្សធម្មតា១២នាក់ ហើយពួកគេភាគច្រើនជាអ្នកនេសាទ។ ព្រះអង្គបានចាត់គេឲ្យចេញទៅដោយឡែកៗពីគ្នា គឺខ្លះចេញទៅប្រទេសមួយ ហើយខ្លះទៅប្រទេសមួយផ្សេងទៀត ក៏ប៉ុន្តែក្នុងរយៈពេលដ៏ខ្លី ដំណឹងល្អបានផ្សាយចេញទៅ ហើយពួកទាំង១២នាក់នោះ បានបង្កើតក្រុមជំនុំនៅប្រទេសផ្សេងៗក្នុងពិភពលោកនេះ ចាប់តាំងពីពេលនោះរហូតមកដល់បច្ចុប្បន្នកាលនេះ ព្រះតម្រិះសម្រេចដ៏ពិសេសក៏បានមើលថែរក្សាដល់គ្រីស្ទបរិស័ទនៅវេលាដែលមានគ្រោះថ្នាក់ ហើយការពាររាល់ការប៉ុនប៉ងបំផ្លាញពួកគ្រីស្ទបរិស័ទដែរ។

## ៤• *ប្រសិនបើបុព្វហេតុធម្មជាតិគ្រប់គ្រងកាលៈទេសៈព្រមទាំងសម្ភារៈគ្រប់យ៉ាងនោះ តើមនុស្សអាចប្រែចិត្តពីអំពើអាក្រក់ដែលគេបានប្រព្រឹត្តយ៉ាងដូចម្ដេចទៅ?*

លោកប៉ុលកំពុងតែធ្វើដំណើរទៅកាន់ទីក្រុងដាម៉ាស ដើម្បីសម្លាប់គ្រីស្ទបរិស័ទ ប៉ុន្តែនៅពេលដែលពន្លឺពីស្ថានសួគ៌ចាំងមកលើគាត់ ស្រាប់តែធ្វើឲ្យគាត់ដួលចុះដល់ដី នៅពេលនោះ គាត់បានប្រែចេញពីគោលបំណងរបស់គាត់ ហើយបានផ្លាស់ប្រែក្លាយទៅជាសាវករបស់ព្រះយេស៊ូវគ្រីស្ទវិញ (កិច្ចការ ៩:១-១៨)។ បន្ទាប់មក ពេលដែលពួកយូដារកល្បិចនឹងសម្លាប់គាត់ ខណៈដែលគេនាំគាត់ជាអ្នកទោសពីក្រុងសេសារាទៅកាន់ក្រុងយេរូសាឡិម តែចៅហ្វាយក្រុងឈ្មោះលោកភេស្ទុស *(គាត់មិនដឹងពីផែនការសម្ងាត់ទេ)* បានសម្រេចចិត្តកាត់ក្ដីលោកប៉ុលនៅក្រុងសេសារា មិនមែនក្រុងយេរ៉ូសាឡិមទេ ដូច្នេះផែនការរបស់គេក៏មិនបានសម្រេចវិញ (កិច្ចការ ២៥:១-៨)។

លោកអ័គូស្ទីនដែលជាអ្នកដឹកនាំដ៏អស្ចារ្យរបស់ក្រុមជំនុំដំបូង បានទៅទីក្រុងមួយ ដើម្បីបង្រៀនប្រជាជននៅទីនោះ ហើយក៏បាននាំយកអ្នកមគ្គុទេសក៍ម្នាក់ទៅ

ជាមួយដើម្បីបង្ហាញផ្លូវ។ អ្នកមគ្គទេសក៍នោះបានវង្វេងផ្លូវដែលគាត់ធ្លាប់ដើរ តែបានទៅដល់ទីក្រុងនោះដោយសុវត្ថិភាព ដោយសារធ្វើដំណើរតាមផ្លូវផ្សេង។ បន្ទាប់មកគេក៏ឮថា ពួកគេបានផុតពីសេចក្ដីស្លាប់របស់ពួកសត្រូវ ដែលបានស្ទាក់ពួនដើម្បីសម្លាប់អ័គូស្ទីននៅតាមផ្លូវនោះ។

តើអ្នកណាមិនអាចមើលឃើញពីព្រះហស្តរបស់ព្រះជាម្ចាស់ ចំពោះកិច្ចការទាំងអស់នេះ?

**៥•** *ប្រសិនបើពុំមានព្រះតម្រិះសម្រេចគ្រប់គ្រង ដើម្បីរៀបចំគ្រប់យ៉ាងទាំងអស់ដែលល្អដល់រាស្ត្រទ្រង់ទេ តើការល្អ ឬអាក្រក់ ដែលបានកើតឡើងដល់ពួកគេនៅក្នុងផែនដីនេះ ត្រូវសងដល់អ្នកណាដែលនាំសេចក្ដីល្អ ឬអាក្រក់មកដល់ពួកគេយ៉ាងដូចម្ដេច?*

ពេលដែលស្ដេចផារ៉ោនបញ្ជាឲ្យសម្លាប់កូនប្រុសៗរបស់អ៊ីស្រាអែល ដែលទើបនឹងកើតទាំងអស់ នោះពួកឆ្មបបានបដិសេធមិនធ្វើតាមការបង្គាប់របស់ទ្រង់ទេ។ ចំពោះហេតុផលរបស់ពួកឆ្មបនេះ ព្រះជាម្ចាស់បានប្រទានពរដល់ពួកគេ (និក្ខមនំ ១:២១)។ រីឯនាងរ៉ាហាបបានលាក់ពួកស៊ើបការណ៍ ដែលពួកអ៊ីស្រាអែលបានបញ្ជូនចូលទៅក្នុងក្រុងយេរីខូរ ហើយនាងក៏បានទទួលសុវត្ថិភាពខណៈដែលមនុស្សទាំងអស់នៅក្នុងទីក្រុងនោះបានវិនាស (យ៉ូស្វេ ៦:២៥)។ ស្ត្រីនៅក្រុងស៊ូណែម មានចិត្តសន្ដោសចំពោះហោរាអេលីសេ ហើយបានរៀបចំឲ្យមានបន្ទប់មួយសម្រាប់គាត់សម្រាកគ្រប់ពេលវេលា ហើយព្រះជាម្ចាស់បានប្រទានឲ្យនាងមានក្ដីអំណរ ដោយឲ្យនាងមានកូនប្រុសមួយ (២ពង្សាវតារក្សត្រ ៤:៩-១៧)។ ពូព្លាស ជាអ្នកមេកោះមេលីត បានផ្ដល់កន្លែងស្នាក់អាស្រ័យដល់លោកប៉ុល បន្ទាប់ពីសំពៅរបស់គាត់លិច។ ព្រះអម្ចាស់បានសង

ដល់លោកពូព្លីសភ្លាមៗចំពោះសេចក្ដីសន្ដោសនោះ ដោយការប្រោសឪពុកគាត់ឲ្យជាពីជំងឺ (កិច្ចការ ២៨:៧, ៨)។

ដូចគ្នានឹងវិធីនោះដែរ សេចក្ដីអាក្រក់ដែលបានមកដល់រាស្ត្ររបស់ព្រះ នោះបានត្រឡប់ទៅលើសត្រូវរបស់ពួកគេវិញ។ ដូចជាយើងបានឃើញមកហើយ ស្ដេចផារ៉ោនមានបំណងសម្លាប់កូនចៅអ៊ីស្រាអែលដែលមិនមានទោសសោះ តែព្រះជាម្ចាស់បានសងដល់ស្ដេចផារ៉ោនវិញ ដោយការសម្លាប់កូនច្បងរបស់ពួកអេស៊ីព្ទក្នុងរយៈពេលតែមួយយប់ (និក្ខមនំ ១២:២៩)។ ហាម៉ានបានដំឡើងឈើយ៉ាងខ្ពស់សម្រាប់ព្យួរកម៉ាដេកាយដែលជាមនុស្សល្អ ប៉ុន្តែព្រះជាម្ចាស់បានសម្រេចឲ្យហាម៉ាន និង កូនប្រុសទាំង១០របស់គាត់ ត្រូវព្យួរកនៅលើឈើនោះទៅវិញ (អេសធើរ ៧:១០)។ អ័ហ៊ីថូផែលមានផែនការប្រឆាំងនឹងស្ដេចដាវីឌ ហើយបានឲ្យការណែនាំពីរបៀបទំលាក់ស្ដេចដាវីឌផង តែការណែនាំនោះបានធ្លាក់មកលើខ្លួនគាត់ គឺនាំឲ្យគាត់ទទួលការវិនាសទៅវិញ (២សាំយូអែល ១៧:២៣)។

បន្ទាប់ពីអធិរាជរ៉ូមដ៏សាហាវយង់ឃ្នងឈ្មោះម៉ាស៊ីមីនុស បានបង្គាប់ឲ្យលុបបំបាត់ចោលជំនឿគ្រីស្ទបរិស័ទទាំងស្រុងនោះ គាត់ក៏បានទទួលជំងឺដ៏ធ្ងន់ធ្ងរ ដូចជាស្ដេចហេរ៉ូឌក្នុងសម័យពួកសាវ័កដែរ (កិច្ចការ ១២:២៣)។ ជួនកាល ការសងចំពោះអំពើអាក្រក់ ក៏ចំនឹងអ្នកធ្វើការអាក្រក់នោះ ដូចជានៅពេលដែលគេយកណាបោតទៅសម្លាប់ ស្ដេចអ័ហាប់ក៏បានទទួលដំណឹងថា *«នៅកន្លែងដែលឆ្កែបានលិទ្ធឈាមរបស់ណាបោត នោះនឹងលិទ្ធឈាមរបស់ឯងដែរ»* នេះគឺជាហេតុការណ៍ដែលពិតជាបានកើតឡើងមែន (១ពង្សាវតារក្សត្រ ២១:១៩ និង ២២:៣៨)។

ដូច្នេះ ព្រះតម្រិះសម្រេចបានបំពេញខគម្ពីរនេះ *«អ្នកណាដែលជីករណ្ដៅ អ្នកនោះនឹងធ្លាក់ទៅក្នុងរណ្ដៅនោះឯង ហើយអ្នកណាដែលប្រមៀលថ្ម ថ្មនោះនឹងរមៀលត្រឡប់មកកិនខ្លួនវិញ»* (សុភាសិត ២៦:២៧) ហើយនិងខនេះ *«ដ្បិតអ្នករាល់*

*គ្នាថ្កោលទោសគេយ៉ាងណា នោះគេនឹងថ្កោលអ្នកវិញយ៉ាងនោះដែរ ហើយគេនឹងវាល់ឲ្យអ្នករាល់គ្នា តាមរង្វាល់ដែលអ្នកវាល់ឲ្យគេផង»* (ម៉ាថាយ ៧:២)។

**៦.** *ប្រសិនបើការទាំងអស់គ្រាន់តែជារឿងចៃដន្យនោះតើការទាំងនោះត្រូវគ្នាយ៉ាងជាក់ច្បាស់ និង ល្អិតល្អន់ជាមួយនឹងខគម្ពីរយ៉ាងដូចម្តេច?*

តើព្រះជាម្ចាស់ព្យួរអំណាចនៃបុព្វហេតុធម្មជាតិយ៉ាងអស្ចារ្យនោះឬទេ? នេះមិនមែនជារឿងចៃដន្យទេ គឺកើតឡើងទៅតាមព្រះបន្ទូលដែលបានចែងមកថា *«កាលណាឯងដើរកាត់ទឹកធំ នោះអញនឹងនៅជាមួយ កាលណាដើរកាត់ទន្លេ នោះទឹកនឹងមិនលិចឯងឡើយ កាលណាឯងលុយកាត់ភ្លើង នោះឯងនឹងមិនត្រូវរលាក ហើយអណ្តាតភ្លើងក៏មិនឆាបឆេះឯងដែរ»* (អេសាយ ៤៣:២)។ តើបុព្វហេតុធម្មជាតិកើតឡើងដើម្បីសម្រេចការល្អសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់ឬ? គំនិតនេះត្រូវនឹងព្រះបន្ទូលដែលបានសំដែងមកថា *«ដ្បិតគ្រប់ទាំងអស់ជារបស់ផងអ្នករាល់គ្នា... តែឯអ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទវិញ»* (១កូរិនថូស ៣:២០-២៣)។

ពេលដែលព្រះតម្រិះសម្រេច ទប់ស្កាត់មនុស្សល្អមិនឲ្យធ្លាក់ទៅក្នុងអំពើអាក្រក់ ឬទប់មនុស្សអាក្រក់មិនឲ្យប្រព្រឹត្តអំពើអាក្រក់ នោះសេចក្តីពិត និង ការប្រាកដច្បាស់នៃព្រះបន្ទូលខាងក្រោមនេះ ក៏បានលេចឡើងយ៉ាងជាក់ស្តែងថា *«ផ្លូវរបស់មនុស្សមិនស្រេចនៅខ្លួនគេទេ ហើយដែលដំរង់ជំហានរបស់ខ្លួន នោះក៏មិនស្រេចនៅមនុស្សដែលដើរដែរ»* (យេរេមា ១០:២៣) ហើយខមួយទៀតសំដែងថា *«ចិត្តរបស់មនុស្សរមែងគិតសម្រេចផ្លូវរបស់ខ្លួន តែគឺព្រះយេហូវ៉ាដែលទ្រង់ដំរង់ជំហានគេវិញ»* (សុភាសិត ១៦:៩)។ កណ្ឌទំនុកដំកើង ៩:១៦ បានសំដែងថា *«ពួកមនុស្សអាក្រក់បានជាប់អន្ទាក់ ដោយការដែលដៃគេធ្វើ»* នេះបញ្ជាក់ពីគំនិតមួយដែលថា អំពើអាក្រក់

ដែលមនុស្សធ្វើ នឹងវិលត្រឡប់មកកាន់ពួកគេវិញ។ ស្តេចស៊ីរូសដែលជាអធិរាជពើស៊ី បានអនុញ្ញាតឲ្យរាស្ត្ររបស់ព្រះជាម្ចាស់មានសេរីភាព ពីព្រោះព្រះបន្ទូលបានចែងថា គាត់ត្រូវតែធ្វើយ៉ាងដូច្នេះ ទោះបីជាការនោះប្រឆាំងនឹងគោលបំណងរបស់គាត់ក៏ដោយ (អេសាយ ៤៥:១៣)។ មនុស្សទាំងអស់លើពិភពលោក តែងតែបំពេញគោលបំណង របស់ព្រះជាម្ចាស់ ទោះបីជាគេមិនចង់ធ្វើដូច្នេះក៏ដោយ។

**៧. *ប្រសិនបើកិច្ចការទាំងអស់នេះកើតឡើងដោយចៃដន្យ តើការទាំងអស់បាន កើតឡើងចំពេលដ៏ត្រឹមត្រូវដូចម្តេចទៅ?***

នៅក្នុងគម្ពីរសញ្ញាចាស់ មានឧទាហរណ៍ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍បែបនេះ ជាច្រើន។ នាងហាកាបានឮដំណឹងថាមានអណ្តូងទឹក នៅពេលនាងដើរចេញទៅដោយ ទុកចោលកូនតូចអ៊ីសម៉ាអែល ដែលកំពុងតែស្រែករកទឹកផឹក (លោកុប្បត្តិ ២១:១៦,១៩) ទេវតាបានហៅលោកអ័ប្រាហាំ ហើយបង្ហាញឲ្យគាត់ឃើញកូនចៀមមួយសម្រាប់ធ្វើ ជាយញ្ញបូជា ខណៈពេលដែលគាត់ហៀបនឹងសម្លាប់អ៊ីសាកជាកូនរបស់គាត់ទៅហើយ នោះ (លោកុប្បត្តិ ២២:១០-១៤)។ ស្តេចសូលបានទទួលដំណឹងថា ពួកភីលីស្ទីនបាន ចូលមកលុកលុយក្នុងស្រុក ខណៈពេលដែលទ្រង់កំពុងដេញតាមសម្លាប់ដាវីឌ (១សាំ យូអែល ២៣:២៧)។ មានដំណឹងពីការវាយប្រហារមកពីទិសម្ខាងទៀត ដែលធ្វើឲ្យពួក ទាហានរបស់ពួកអាសស៊ើរដកថយពីទីក្រុងយេរូសាឡិម ខណៈដែលគេរៀបទៅច្បាំង នឹងទីក្រុងនោះ (អេសាយ ៣៧:៧, ៨)។ នៅពេលដែលផែនការប្រឆាំងនឹងពួកយូដា របស់ហាម៉ានរួចរាល់ ដើម្បីបំពេញកិច្ចសហប្រតិបត្តិការ *«នៅវេលាយប់ថ្ងៃនោះឯង ស្តេចទ្រង់ផ្ទុំមិនលក់ទេ»* (នាងអេសធើរ ៦:១)។ មានហេតុការណ៍កើតឡើងចំពោះ រាស្ត្ររបស់ព្រះជាម្ចាស់ ដែលស្រដៀងនេះជាច្រើននៅក្នុងឆ្នាំក្រោយៗនោះមកទៀត នោះជាភស្តុតាងថែមទៀត ពីរបៀបដែលព្រះតម្រិះសម្រេចធ្វើចំសម្រាប់ពួកគេ។

៨. *ប្រសិនបើកិច្ចការទាំងអស់នេះគ្រាន់តែជារឿងថៃដន្យ តើការទាំងនេះកើតឡើងទៅតាមសំណូមអធិស្ឋានរបស់មនុស្សបរិសុទ្ធ ដែលដឹងថាពួកគេបានទទួលចម្លើយយ៉ាងច្បាស់ពីសំណូមពររបស់គេយ៉ាងដូចម្តេច (១យ៉ូហាន ៥:១៥)?*

អ្នកបម្រើអ័ប្រាហាំបានអធិស្ឋានសុំជ័យជំនះ នៅពេលដែលគាត់ធ្វើដំណើរទៅស្វែងរកប្រពន្ធឲ្យអ៊ីសាក។ ព្រះជាម្ចាស់បានឆ្លើយតបទៅនឹង ការអធិស្ឋានតាមពាក្យចំៗរបស់គាត់ (លោកុប្បត្តិ ២៤:១៤,៤៦)។ កូនចៅអ៊ីស្រាអែលបានស្រែកអំពាវនាវដល់ព្រះយេហូវ៉ា ខណៈដែលស្តេចផារ៉ោន និង ពួកអេស៊ីព្ទដេញតាមពួកគេ នោះសមុទ្រក្រហមក៏បានញែកចេញពីគ្នានៅខាងមុខពួកគេ (និក្ខមនំ ១៤:១០)។ ស្តេចអេសាប្រឈមមុខនឹងពួកទាហានរាប់ពាន់នាក់ ដែលមានចំនួនច្រើនជាងពួកទាហានរបស់ទ្រង់ ហើយទ្រង់ស្រែកអំពាវនាវដល់ព្រះយេហូវ៉ាជាព្រះរបស់ទ្រង់ ដោយបន្ទូលថា *«ឱព្រះយេហូវ៉ាអើយ ការជួយឲ្យមានជ័យជំនះដល់ពួកមានគ្នាច្រើន ឬដល់ពួកកំសោយ នោះស្រេចនៅលើទ្រង់ទេ ឱព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នាអើយ សូមជួយយើងខ្ញុំផង ដ្បិតយើងខ្ញុំផ្អែកលើទ្រង់ជាទីពឹង គឺដោយនៅតែព្រះនាមទ្រង់ប៉ុណ្ណោះ»* ហើយព្រះជាម្ចាស់បានឆ្លើយតបចំពោះស្តេចអេសា ដោយឲ្យទ្រង់ទទួលជ័យជំនះដ៏អស្ចារ្យ (២របាក្សត្រ ១៤:១១)។ ពេលដែលពេត្រុសជាប់គុក នោះក្រុមជំនុំបានអធិស្ឋានឲ្យគាត់ទាំងយប់ទាំងថ្ងៃ។ នៅក្នុងកណ្ឌកិច្ចការ ១២:១-១២ យើងអាចឃើញពីរបៀបដែលព្រះជាម្ចាស់បានឆ្លើយតបនឹងសំណូមពរអធិស្ឋានរបស់ពួកគេ។

តើអ្នកណាអាចនិយាយបានថា ព្រះតម្រិះសំរេចរបស់ព្រះមិនបង្ហាញថា ទ្រង់ជាព្រះដែលស្តាប់ និង ឆ្លើយតបការអធិស្ឋានរបស់មនុស្សនោះទេ? *«ដ្បិតព្រះនេត្រនៃព្រះយេហូវ៉ាចេះតែទតច្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីនឹងសំដែងព្រះចេស្តាជួយដល់អស់អ្នកណាដែលមានចិត្តស្មោះត្រង់ចំពោះទ្រង់»* (២របាក្សត្រ ១៦:៩)។

# ជំពូក ២

## របៀបដែលព្រះជាម្ចាស់ប្រព្រឹត្តតាមព្រះតម្រិះសម្រេចរបស់ទ្រង់ នៅក្នុងជីវិតយើង

### ១. ការប្រព្រឹត្តតាមព្រះតម្រិះសម្រេចរបស់ទ្រង់ នៅពេលយើងចាប់កំណើត

ដាវីឌបានសរសើរដំកើងដល់ការប្រព្រឹត្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ នៅពេលគាត់គិតពីលក្ខណៈដែលព្រះអង្គបានបង្កើតរូបគាត់ ហើយជ្រាបគ្រប់ទាំងអស់នៅក្នុងសព៌ាង្គកាយយ៉ាងលំអិតរបស់គាត់ សូម្បីតែនៅមុនពេលដែលគាត់បានកើតមក ក៏ទ្រង់ជ្រាបដែរ (ទំនុកដំកើង ១៣៩:១៣-១៦) ប៉ុន្តែ រូបកាយគ្រាន់តែជាផ្នែកខាងក្រៅនៃរូបមនុស្សពិតប្រាកដប៉ុណ្ណោះ។ ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យចេះគិត ស្រឡាញ់ ហើយនៅក្នុងលក្ខណៈបែបនេះ យើងអាចដឹងថា ព្រះបានបង្កើតយើងឲ្យមានរូបដូចអង្គទ្រង់។ សូមគិតមើលពីរបៀបដែលព្រះតម្រិះសម្រេចបានធ្វើការយ៉ាងពូកែសម្រាប់យើង តាំងពីថ្ងៃដំបូងនៃជីវិតរបស់យើងដែលបានកើតនៅលើផែនដីនេះ ហើយបន្ទាប់មក ក៏នាំយើងដោយសុវត្ថិភាពទៅទីកន្លែងរបស់យើង ដែលត្រូវនឹងបំណងព្រះហឫទ័យរបស់ព្រះអង្គ។

### ២. ការប្រព្រឹត្តតាមព្រះតម្រិះសម្រេចរបស់ទ្រង់ កំឡុងពេល និង ទីកន្លែងដែលយើងកើតមក *(នៅត្រង់នេះ បានបញ្ចូលផ្នែកទី២ និង ទី៣ របស់លោកហ្វាវែលជាមួយគ្នា)*

ព្រះជាម្ចាស់ បានសម្រេចពេលវេលា និង ទីកន្លែងសម្រាប់ឲ្យអ្នកចាប់កំណើត។ គ្រប់ប្រទេសជាតិទាំងអស់ មិនមែនជាទីកន្លែងដែលសប្បាយដូចគ្នាក្នុងការរស់នៅទេ ហើយមនុស្សដែលរស់នៅលើទឹកដីមួយ ក៏មិនមែនសុទ្ធតែជាអ្នកថ្វាយបង្គំព្រះជាម្ចាស់ពិតប្រាកដដែរ។ ដូចគ្នានឹងដំណឹងល្អនៃសេចក្ដីសង្គ្រោះតាមរយៈបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទដែរ គេបានឮសុសសាយ ហើយព្រះតម្រិះសម្រេចក៏បានលំអៀងទៅគេជាខ្លាំងផង។ [១]យើងអាចឃើញភាពល្អរបស់ព្រះតម្រិះសម្រេចបាន បើសិនជាឪពុកម្ដាយរបស់អ្នកជាគ្រីស្ទបរិស័ទ ដោយព្រោះការអធិស្ឋាន ការបង្រៀន និង គំរូរបស់គាត់បានលើកទឹកចិត្តដល់អ្នក ឲ្យស្វែងរកការយល់ដឹងអំពីព្រះជាម្ចាស់ និង អំពីជីវិតអស់កល្បជានិច្ច។ ប៉ុន្តែ ទោះបើឪពុកម្ដាយរបស់អ្នកមិនមែនជាគ្រីស្ទបរិស័ទក៏ដោយ ក៏នេះជាព្រះតម្រិះសម្រេចដ៏ពិសេសដែរ នៅពេលអ្នករកឃើញថាព្រះគុណារបស់ព្រះជាម្ចាស់ ផ្ដល់ឲ្យអ្នកចង់ដឹង ចង់ស្គាល់ទ្រង់ ខណៈដែលមនុស្សគ្រប់គ្នានៅជុំវិញអ្នក មិនមានចំណាប់បែបនោះ ពីព្រោះគំនិតរបស់គេផ្ទុយពីព្រះហឫទ័យព្រះជាម្ចាស់ និង ផ្លូវរបស់ទ្រង់ផង។

## ៣. ការប្រតិបត្តិតាមព្រះតម្រិះសម្រេចរបស់ទ្រង់ នៅពេលយើងកើតជាថ្មី

យើងអាចមើលឃើញកិច្ចការនៃព្រះតម្រិះសម្រេចយ៉ាងច្បាស់បំផុតបាន នៅក្នុងរបៀបដែលព្រះជាម្ចាស់បំផ្លាស់បំប្រែមនុស្សប្រុស-ស្រី ចេញពីការគិតតែពីខ្លួនគេផ្ទាល់ ហើយផ្ដល់ការយល់ដឹងពិតប្រាកដអំពីទ្រង់ដល់ពួកគេ។ នេះជាអត្ថប្រយោជន៍ដ៏ធំបំផុត ដែលអ្នកទទួលបានពីព្រះតម្រិះសម្រេច ហើយអ្នកនឹងពេញចិត្តក្នុងការគិត និង និយាយអំពីការនេះ។ បទពិសោធន៍របស់យ៉ាកុប នៅឯបេត-អែល តែងតែដក់ជាប់នៅក្នុងគំនិតរបស់គាត់ (លោកុប្បត្តិ ២៨:១០-២២)។ ពួកបរិសុទ្ធផ្សេងទៀតក៏មានបទពិសោធន៍នៅបេត-អែលដែរ ជាកន្លែងដែលព្រះជាម្ចាស់ធ្វើឲ្យអារម្មណ៍របស់គេបានដក់ជាប់យ៉ាងជ្រៅនៅក្នុងចិត្ត ដែលមិនអាចភ្លេចបានឡើយ។

១. នៅក្នុងសតវត្សនេះ ដំណឹងល្អអាចឮតាមរយៈវិទ្យុ ស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។ នេះជាព្រះតម្រិះសម្រេចមួយរបស់ព្រះជាម្ចាស់ ដែលលោក ចន ហ្វាវែល មិនដែលនឹកស្រម៉ៃឡើយ។

របៀបដែលចម្លែកហើយអស្ចារ្យ ដែលព្រះតម្រិះសម្រេចធ្វើនៅក្នុងការនាំមនុស្ស ឲ្យយល់ដឹងពីព្រះជាម្ចាស់នោះ យើងក៏ឃើញមាននៅក្នុងបទគម្ពីរជាច្រើនកន្លែងដែរ។ ក្មេងស្រីម្នាក់ដែលគេបានចាប់ជាឈ្លើយនៅក្នុងទឹកដីអ៊ីស្រាអែល រួចនាំយកទៅឲ្យបំរើប្រពន្ធលោកណាម៉ាន់ ដែលជាអនុសេនីយឯកនៃកងទ័ពរបស់ស្តេចស៊ីរី។ នាងបានប្រាប់ចៅហ្វាយស្រីរបស់នាង ពីអំណាចរបស់ព្រះជាម្ចាស់តាមរយៈហោរាអេលីសេ ហើយដោយសារការនោះ ព្រះបានប្រោសឲ្យណាម៉ាន់បានជាពីជំងឺឃ្លង់របស់គាត់ (២ពង្សាវតារក្សត្រ ៥:៣)។ ព្រះគ្រីស្ទបានយាងឆ្លងកាត់ទឹកដីសាម៉ារី ហើយនៅពេលថ្ងៃត្រង់ ទ្រង់ឈប់សម្រាកនៅអណ្តូងទឹករបស់យ៉ាកុប។ មានព្រះតម្រិះសម្រេចដ៏អស្ចារ្យហើយល្អមួយចំនួន កើតចេញពីព្រឹត្តិការណ៍ដ៏ «សាមញ្ញ»នេះ គឺដំបូងស្ត្រីសាសន៍សាម៉ារី ហើយបន្ទាប់មកមានមនុស្សជាច្រើននាក់ទៀតនៅក្នុងទីក្រុងនោះ បានជឿដល់ព្រះយេស៊ូវគ្រីស្ទ (យ៉ូហាន ៤:៤-៤២)។ ភីលីពឡើងជិះលើរទេះចម្បាំងជាមួយបុរសសាសន៍អេធីយ៉ូពី ចំនឹងពេលដែលព្រះជាម្ចាស់បានធ្វើឲ្យបុរសកំរៀវនោះ ត្រៀមគំនិតដើម្បីទទួលព្រះគ្រីស្ទ ខណៈដែលគាត់កំពុងអានកណ្ឌគម្ពីរអេសាយ (កិច្ចការ ៨:២៦-៣៥)។

ចាប់តាំងពីដើមដំបូង ព្រះតម្រិះសម្រេចបានប្រើវិធីច្រើនយ៉ាងដើម្បីបំផ្លាស់បំប្រែមនុស្សឲ្យត្រឡប់ទៅរកព្រះយេស៊ូវគ្រីស្ទវិញ។ ទំព័រមួយពីសៀវភៅដ៏ល្អ ដែលគេយកមកខ្ចប់របស់ដែលបានទិញមកពីផ្សារ ជាវិធីមួយនៅក្នុងការបំផ្លាស់បំប្រែគ្រូអធិប្បាយម្នាក់នៅប្រទេសវេលស៍ (Wales)។ ជាញឹកញយ ការអានសៀវភៅដែលល្អ ជាវិធីដែលនាំមនុស្សទៅកាន់ព្រះយេស៊ូវគ្រីស្ទ។ ជួនកាល ទោះជាហេតុផលណាក៏ដោយគ្រូអធិប្បាយបានផ្លាស់ប្តូរប្រធានបទនៃការអធិប្បាយរបស់គាត់ នៅនាទីចុងក្រោយ ហើយអ្នកណាដែលស្តាប់ក៏កាន់តែស្គាល់ខ្លួនគេ នឹងស្គាល់ពីព្រះសង្គ្រោះដែរ។ អ្នកយាមគុកក៏បានផ្លាស់ប្រែតាមរយៈពាក្យសម្តីមកពីមនុស្សល្អៗដែលជាប់គុក ដូចជាអ្នក

យាមគុកនៅក្រុងភីលីព ក្នុងសម័យរបស់លោកប៉ុល (កិច្ចការ ១៦:២៥-៣១)។ មនុស្សអាក្រក់ខ្លះបានទៅស្តាប់គ្រូអធិប្បាយដើម្បីសើចចំអក ហើយធ្វើទុក្ខទោសដល់គាត់ ប៉ុន្តែព្រះជាម្ចាស់បានជួបពួកគេ ព្រមទាំងបង្ហាញឲ្យគេឃើញពីអំពើបាបរបស់គេ ហើយនៅពេលនោះពួកគេក៏ស្វែងរក និង ទទួលការអត់ទោស។

ខ្ញុំស្គាល់កម្លោះម្នាក់ដែលធ្វើដំណើរតាមកប៉ាល់ ពីប្រទេសអាមេរិកទៅប្រទេសអង់គ្លេស។ នៅព្រឹកមួយ ខ្ញុំបានជួបកម្លោះម្នាក់នោះ បន្ទាប់ពីគាត់បានព្យាយាមធ្វើអត្តឃាតខ្លួនឯង ហើយពេលនោះគាត់ស្ទើរតែបាត់បង់ជីវិតទៅហើយ នោះខ្ញុំបាននាំគាត់ឲ្យឃើញថា ជាការចាំបាច់ដែលគាត់ត្រូវតែផ្លាស់ប្រែពីគំនិតមិនត្រឹមត្រូវរបស់គាត់ចេញ ហើយជឿដល់ព្រះគ្រីស្ទដើម្បីបានជីវិតអស់កល្បជានិច្ច។ កម្លោះនោះបានសូមដល់ព្រះជាម្ចាស់ ដើម្បីឲ្យការទាំងអស់នេះបានដោះស្រាយនៅក្នុងព្រលឹងរបស់គាត់។ ខ្ញុំ បានចេញទៅវិញ ដោយពុំមានសង្ឃឹមថានឹងបានជួបគាត់ម្តងទៀតទេ ប៉ុន្តែនៅយប់ដដែលនោះ គាត់នៅតែមានជីវិតរស់នៅឡើយ។ គាត់និយាយថា ព្រះអម្ចាស់បានជួយឲ្យគាត់ផ្លាស់ប្រែចេញពីការធ្វើបាប ប៉ុន្តែការមួយដែលធ្វើឲ្យគាត់ខ្វល់នោះគឺ តើព្រះយេស៊ូវគ្រីស្ទបានខ្ចាយព្រះលោហិតរបស់ទ្រង់សម្រាប់គាត់ដែរឬទេ បើគាត់បានអារសាច់ខ្លួនឯងបង្ហូរឈាមនោះ? ខ្ញុំប្រាប់គាត់ថា ព្រះគ្រីស្ទបានខ្ចាយព្រះលោហិតរបស់ទ្រង់សម្រាប់អ្នកមានដៃអាក្រក់ដែលបានសម្លាប់ទ្រង់ ហើយការនោះក៏អាក្រក់ជាងអ្វីដែលកម្លោះម្នាក់នោះបានធ្វើទៅទៀត។ បន្ទាប់មក កម្លោះនោះនិយាយថា *«ខ្ញុំនឹងត្រឡប់មកឯព្រះគ្រីស្ទ ហើយអនុញ្ញាតឲ្យទ្រង់ធ្វើអ្វីដែលទ្រង់ចង់ធ្វើចំពោះខ្ញុំ»*។ ព្រឹកស្អែកឡើង គ្រប់គ្នាមានការភ្ញាក់ផ្អើលមែនទែន នៅពេលឃើញគាត់បានគ្រាន់បើជាងមុនច្រើន។ គាត់ក៏មានសុខភាពល្អបរិបូរណ៍ឡើងវិញ រួចត្រឡប់ទៅកាន់ប្រទេសអាមេរិកវិញ ហើយខ្ញុំក៏ទទួលសំបុត្រមួយពីមិត្តសម្លាញ់ម្នាក់ ដែលបាននិយាយថា ប្រសិនបើព្រះជាម្ចាស់ដែលធ្វើកិច្ចការដ៏អស្ចារ្យ កិច្ចការនោះគឺបានធ្វើនៅក្នុងជីវិតរបស់កម្លោះ

ម្នាក់នេះហើយ។ មើល របៀបដែលព្រះតម្រិះសំរេចធ្វើនៅក្នុងការនាំមនុស្សទៅកាន់ព្រះគ្រីស្ទ ចម្លែកណាស់ន៍!

ដោយសារព្រះតម្រិះសម្រេច ដាស់តឿនព្រលឹងវិញ្ញាណដោយព្រឹត្តិការណ៍ដ៏ចម្លែកៗ កិច្ចការនោះក៏បន្តរហូតដល់ព្រលឹងវិញ្ញាណបានទទួលការសង្គ្រោះយ៉ាងពេញលេញ។ ខ្ញុំនឹកចាំរឿងអំពីបុរសម្នាក់ ដែលបានបែរចេញពីជីវិតដ៏សែនអាក្រក់ និងចេញពីមិត្តភក្ដិដែលអាក្រក់ៗរបស់គាត់ដែរ ប៉ុន្តែ បន្ទាប់ពីបានកន្លងផុតមួយរយៈមក គាត់ក៏មានសេចក្ដីល្បួងឲ្យបែរទៅធ្វើតាមការអាក្រក់វិញ។ ព្រះតម្រិះសម្រេចបាននាំឲ្យគាត់មើលទៅលក្ខណៈរបស់គាត់ ដោយទាញគាត់ឲ្យនឹកចាំពីកណ្ឌសុភាសិត ១:២៤-២៦ នោះក៏ធ្វើឲ្យគាត់ខ្វល់ ហើយគិតថា គាត់មិនអាចទទួលការអភ័យទោសសម្រាប់អំពើបាបរបស់គាត់ឡើយ ប៉ុន្តែព្រះជាម្ចាស់បានបង្ហាញខគម្ពីរនៅក្នុងកណ្ឌលូកា ១៧:៤ ហើយខគម្ពីរនោះក៏បាននាំឲ្យគាត់មានសន្តិភាពនៅក្នុងគំនិត និង ក្នុងចិត្តរបស់គាត់។ មានស្ត្រីចិត្តសប្បុរសម្នាក់បានគិតថា ព្រះជាម្ចាស់បានចាកចេញពីរូបគាត់ហើយ ដោយសារគំនិតនោះ គាត់ក៏អស់សង្ឃឹមក្នុងជីវិត ហើយបដិសេធមិនទទួលការកំសាន្តចិត្តពីអ្នកណាឡើយ។ នៅថ្ងៃមួយ មានគ្រូគង្វាលម្នាក់បានទៅសួរសុខទុក្ខគាត់ គាត់ទាញយកកែវពីលើតុមក ហើយនិយាយថា *«ខ្ញុំដឹងថា ខ្ញុំជាអ្នកដែលគេដាក់បណ្ដាសាដូចជាកែវនេះ ដែលនឹងបែកទៅដែរ»* រួចគាត់ក៏បោកកែវនោះទៅលើដី អស់មួយទំហឹងរបស់គាត់ ប៉ុន្តែអ្នកទាំងពីរមានការភ្ញាក់ផ្អើលមែនទែន ដោយសារកែវនោះមិនបែក! គ្រូគង្វាលនោះក៏លើកកែវឡើងបង្ហាញដល់គាត់ រួចនិយាយថា នេះហើយជាកិច្ចការរបស់ព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់ ហើយចាប់តាំងពីពេលនោះមក គំនិតរបស់គាត់ ក៏បានគ្រាន់បើឡើងយ៉ាងខ្លាំង។

ឥឡូវនេះ តើអ្នកគួរតែអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះរាល់ជំនួយដ៏អស្ចារ្យរបស់ទ្រង់ឬទេ? មានសេចក្ដីមេត្តាករុណាច្រើនយ៉ាងដែលបានផ្ដល់មកមនុស្ស ដោយ

សារព្រះហស្តនៃព្រះតម្រិះសម្រេច ប៉ុន្តែមិនដូចគ្នាទេ។ សូមគិតមើលពីរបៀបដែលព្រះតម្រិះសម្រេចមានបំណងព្រះហឫទ័យសម្រាប់ការល្អរបស់អ្នកជារឿងរហូត តែនោះជាពេលដែលអ្នកមិនយល់សោះ។ គំនិតរបស់ព្រះជាម្ចាស់ មិនមែនដូចគំនិតរបស់យើងទេ ហើយដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះផ្លូវរបស់ទ្រង់ក៏ខ្ពស់ជាងផ្លូវរបស់យើង ហើយគំនិតរបស់ទ្រង់ ក៏ខ្ពស់ជាងគំនិតរបស់យើងដែរ (អេសាយ ៥៥:៨, ៩)។ លោកសាខេមិនបានដឹងថា នឹងមានរឿងអ្វីកើតឡើងនោះទេ នៅពេលដែលគាត់ឡើងទៅលើដើមឈើដើម្បីមើលព្រះគ្រីស្ទ ដែលកំពុងតែយាងកាត់ទីនោះ។ ព្រះគ្រីស្ទមានព្រះហឫទ័យស្រឡាញ់ដល់គាត់ ព្រះអង្គបានយាងទៅផ្ទះលោកសាខេទៅធ្វើជាភ្ញៀវ និង ធ្វើជាព្រះសង្គ្រោះរបស់គាត់(លូកា ១៩:២-១០) ហើយអ្នកមិនបានគិតប៉ុន្មានអំពីព្រះតម្រិះសម្រេច ពេលអ្នកទៅស្តាប់ការអធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះទេ តែកិច្ចការនោះបាននាំឲ្យអ្នកយល់ពីព្រះរាជសារនៃសេចក្តីសង្គ្រោះ។ កិច្ចការល្អៗជាច្រើនបានកើតមានឡើងចំពោះមនុស្ស ដោយសារព្រះហស្តរបស់ព្រះតម្រិះសម្រេច ប៉ុន្តែគ្មានអ្វីដូចជាការល្អខាងព្រលឹងវិញ្ញាណនេះទេ។ សេចក្តីល្អដែលកើតចេញពីសេចក្តីស្រឡាញ់ដ៏វិសេសរបស់ព្រះជាម្ចាស់នេះ នឹងប្រទានឲ្យទៅតែអ្នកដែលព្រះអង្គបានជ្រើសរើសប៉ុណ្ណោះ (១ថែស្សាឡូនីច ១:៤, ៥) ហើយព្រះទ្រង់ឲ្យសេចក្តីសង្គ្រោះនោះជាពិតប្រាកដ។ នៅពេលអ្នកបែរក្រោយមើល ចាប់តាំងពីពេលដែលអ្នកបែរត្រឡប់ទៅព្រះជាម្ចាស់ដែលបានជ្រើសរើសអ្នក មុនពេលទ្រង់បានបង្កើតផែនដីឡើង ដូច្នេះអ្នកក៏អាចនឹកគិតចំពោះសេចក្តីសង្គ្រោះ ដែលទ្រង់នឹងសំរេចឲ្យពេញលេញនៅថ្ងៃអនាគតដែរ។ សេចក្តីល្អខាងព្រលឹងវិញ្ញាណនេះ គ្មានទីបំផុតទេ គឺនឹងនៅជាមួយអ្នកនៅពេលឪពុកម្តាយ គ្រួសារ ទ្រព្យសម្បត្តិ សុខភាព និង ជីវិតរបស់អ្នកបានរលាយបាត់អស់ទៅហើយនោះ។

## ៤• ព្រះតម្រិះសម្រេចនៅក្នុងការប្រព្រឹត្តប្រចាំថ្ងៃ ក្នុងជីវិតរបស់យើង

ព្រះតម្រិះសម្រេច តែងគិតពីសេចក្តីល្អរបស់មនុស្សនៅលើផែនដីនេះ ក៏ដូចជានៅផែនដីដែលនឹងមកដល់នៅថ្ងៃអនាគតដែរ។ ការរស់នៅដោយខ្ជិលច្រអូស នោះមិនមែនជាការរស់នៅដោយស្មោះត្រង់ទេ ដូចជាព្រះគម្ពីរបានចែងយ៉ាងច្បាស់នៅក្នុងកណ្ឌ១ថែស្សាឡូនីច ៤:១១, ១២ នេះមិនមែនជាសេចក្តីមេត្តាតិចតួច ដើម្បីឲ្យមានការងារដែលស្មោះត្រង់ និង ស្របតាមច្បាប់នោះទេ ព្រះជាម្ចាស់បានត្រាស់ហៅមនុស្សជាច្រើនឲ្យធ្វើកិច្ចការសម្រាប់ទ្រង់ ខណៈពេលដែលពួកគេកំពុងតែបំពេញការងារធម្មតារបស់ពួកគេ។ ព្រះជាម្ចាស់បានផ្លាស់លោកអេម៉ុសឲ្យក្លាយជាហោរា និង ដាវីឌឲ្យក្លាយជាស្តេច ខណៈដែលលោកអេម៉ុស និង ដាវីឌ នៅជាអ្នកគង្វាលចៀម (អេម៉ុស ៧:១៤, ១៥ និង ទំនុកដំកើង ៧៨:៧០, ៧១)។ ព្រះគ្រីស្ទបានហៅពេត្រុស និង អនទ្រេឲ្យក្លាយទៅជា «អ្នកនេសាទមនុស្ស» វិញ ខណៈដែលពួកគេកំពុងនៅជាអ្នកនេសាទត្រី (ម៉ាថាយ ៤:១៨, ១៩)។

មនុស្សមួយចំនួនរអ៊ូរទាំថា ការងាររបស់គេធ្ងន់ពេក ហើយក៏ធ្វើឲ្យពួកគេចំណាយពេលវេលាច្រើនពេកដែរ។ ចម្លើយរបស់ខ្ញុំចំពោះគេគឺថា ព្រះតម្រិះសម្រេចបានជ្រាបជាមុនថា ការងារនេះសមរម្យហើយល្អបំផុត ឲ្យអ្នកបំរើដល់ព្រះជាម្ចាស់។ ប្រសិនបើជីវិតអ្នកមានការងាយស្រួល និង ការសម្រាកច្រើនទៀត ប្រហែលជាអ្នកអាចជួបសេចក្តីល្បួងជាច្រើន ហើយសុខភាពរបស់អ្នកក៏មិនសូវល្អប៉ុន្មានដែរ *«ការដេកលក់នៃមនុស្សដែលធ្វើការនឿយហត់ នោះស្រួលឆ្ងាញ់ ទោះបើបានបរិភោគតិច ឬច្រើនក្តី ប៉ុន្តែការបរិភោគហួសប្រមាណរបស់អ្នកមាន នោះមិនឲ្យគេដេកលក់បានទេ»* (សាស្តា ៥:១២)។ ប្រសិនបើអ្នកមានសេចក្តីប៉ងប្រាថ្នាខាងព្រលឹងវិញ្ញាណ នោះអ្នកប្រហែលជាអាចរីករាយជាមួយនឹងវត្តមានរបស់ព្រះជាម្ចាស់ ទោះបីជានៅកន្លែងធ្វើការរបស់អ្នកក៏ដោយ ក៏អ្នកអាចមានពេលវេលាទំនេរខ្លះក្នុងមួយថ្ងៃ ដើម្បីឲ្យអ្នកអធិស្ឋាន និង គិតអំពីព្រះបន្ទូលរបស់ទ្រង់បានដែរ។

ប្រសិនបើអ្នកជាគ្រីស្ទបរិស័ទ ព្រះជាម្ចាស់បានសន្យាថា នឹងមិនចាកចេញពីអ្នកឡើយ (ហេព្រើរ ១៣:៥)។ ព្រះតម្រិះសម្រេចបានរៀបចំឲ្យមានទំនាក់ទំនងនៅក្នុងផែនដីនេះ ដែលពិតជាល្អបំផុតសម្រាប់ការល្អរបស់អ្នកជារៀងរហូត។ ព្រះអង្គបានបង្គាប់ឲ្យយើងស្កប់ចិត្តនឹងអ្វីដែលយើងមាន ទោះបីយើងមានតែអាហារទទួលទាន និង សំលៀកបំពាក់ដែលចាំបាច់សម្រាប់យើងក៏ដោយ (១ធីម៉ូថេ ៦:៨)។

ការបង្គាប់ដល់អ័ដាមនៅក្នុងកណ្ឌលោកុប្បត្តិ ៣:១៩ ក៏ជាការបង្គាប់ដល់យើងនៅសព្វថ្ងៃនេះដែរ។ យើងត្រូវធ្វើការឲ្យអស់ពីកម្លាំងកាយ ទោះជាអ្វីដែលយើងធ្វើក៏ដោយ ក៏យើងត្រូវប្រុងប្រយ័ត្នមិនឲ្យដាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ឡើយ នៅពេលយើងចង់បានទ្រព្យសម្បត្តិនោះ។ ព្រះគម្ពីរសំដែងថា *«ពួកអ្នកដែលចង់ធ្វើជាអ្នកស្តុកស្តម្ភ នោះនឹងធ្លាក់ទៅក្នុងសេចក្តីល្បួង នឹងអន្ទាក់»* (១ធីម៉ូថេ ៦:៩) ដ្បិតគឺទ្រង់ហើយ ដែលប្រទានឲ្យឯងមានឥទ្ធិឫទ្ធិ ឲ្យបានទ្រព្យសម្បត្តិ (ចោទិយកថា ៨:១៨) ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងចិត្ត ចូរទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ាចុះ (ទំនុកដំកើង ៣៧:៤, ៥)។ ត្រូវស្កប់ចិត្តនឹងឋានៈ និង កិច្ចការដែលព្រះតម្រិះសម្រេចបានប្រទានមកដល់អ្នក។ ព្រះតម្រិះសម្រេចមានប្រាជ្ញាជាងអ្នកទៅទៀត ហើយក៏បានរៀបចំសព្វគ្រប់ទាំងអស់សម្រាប់ការល្អជារៀងរហូតរបស់អ្នក អ្នកអាចដឹងប្រាកដនៅក្នុងចិត្តចំពោះកិច្ចការនោះ។

## ៥• ព្រះតម្រិះសម្រេច នៅក្នុងជីវិតគ្រួសាររបស់យើង

ព្រះតម្រិះសម្រេចមានព្រះទ័យដ៏ពិសេសនៅក្នុងការស្វែងរកប្រពន្ធ ឬប្តី ហើយបន្ទាប់មក ក៏ប្រទានឲ្យគេមានកូន។ ការនេះយើងបានឃើញយ៉ាងច្បាស់នៅក្នុងករណីរបស់លោកអ័ប្រាហាំ ក្នុងការស្វែងរកប្រពន្ធឲ្យអ៊ីសាក (លោកុប្បត្តិ ជំពូក២៤) ហើយ និង ការប្រទានឲ្យនាងហាណាមានកូនមួយឈ្មោះសាំយូអែល (១សាំយូអែល ១:២០)

ព្រមទាំងការចាប់កំណើតរបស់លោកយ៉ូហាន-បាទីស្ទ នៅក្នុងគ្រួសារលោកសាការី និង អេលីសាបិត (លូកា ១:១៣,១៤)។ មានព្រះតម្រិះសម្រេចជាច្រើន ដែលយើងមើលឃើញនៅក្នុងការផ្តល់គូស្រករដ៏ស័ក្តិសមសម្រាប់យើង ដែលនាំឲ្យមានអពាហ៍ពិពាហ៍ដ៏រីករាយ និង មានសន្តិភាព ហើយនៅពេលដៃគូមួយរស់នៅក្នុងរបៀបដែលនាំការល្អខាងព្រលឹងវិញ្ញាណជារៀងរហូតទៅដល់ដៃគូមួយទៀត នោះជាចំណុចដ៏ពិសេសគួរឲ្យចាប់អារម្មណ៍។ *«ដ្បិតឱស្ត្រីអើយ ប្រហែលជានាងនឹងសង្គ្រោះប្តីបានទេដឹង ឬបុរសអើយ ប្រហែលជាអ្នកនឹងសង្គ្រោះប្រពន្ធបានដែរទេដឹង?»* (១កូរិនថូស ៧:១៦) ហើយនៅពេលដែលប្តីប្រពន្ធទាំងពីរក្លាយជាគ្រីស្ទបរិស័ទ នោះជាក្តីសប្បាយរីករាយនៃព្រះតម្រិះសម្រេច ដែលបាននាំពួកគេឲ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅលើផែនដីនេះ ហើយនឹងមានក្តីសង្ឃឹមថានឹងបានសេចក្តីសង្គ្រោះជារៀងរហូតនៅឯនគរស្ថានសួគ៌។

មនុស្សប្រុសស្រីជាច្រើន មិនអាចទទួលក្តីអំណរយ៉ាងដូច្នេះបានទេ ប្រសិនបើព្រះជាម្ចាស់ប្រទានពរនេះដល់អ្នក សូមកុំភ្លេចអរព្រះគុណដល់ទ្រង់ ហើយរស់នៅដើម្បីសរសើរដំកើងទ្រង់វិញ។ ព្រះអម្ចាស់រំពឹងទុកឲ្យអ្នកសរសើរដំកើងគ្រប់ពេលវេលាដែលអ្នកមានក្តីសុខសាន្ត ពីព្រោះមិនយូរប៉ុន្មានសេចក្តីស្លាប់នឹងបំបែកគ្រួសារ ដូច្នេះត្រូវរស់នៅតាមលក្ខណៈមួយដែលល្អ ក្នុងពេលដែលអ្នកមានជីវិតរស់នៅ ដើម្បីកាលណាថ្ងៃបំបែកមកដល់ នោះមិនសូវពិបាកទេ។

## ៦• គុណសម្បត្តិខាងព្រះតម្រិះសម្រេច សម្រាប់គ្រួសាររបស់យើង

អ្នកដឹងពីសេចក្តីសន្យាដែលព្រះជាម្ចាស់បានសន្យាដល់រាស្ត្ររបស់ទ្រង់ថា *«ឯអស់ទាំងសិង្ហស្ទាវ វាតែងតែខ្វះ ហើយក៏ឃ្លាន តែអស់អ្នកដែលស្វែងរកព្រះយេហូវ៉ា នោះនឹងមិនខ្វះអ្វីដែលល្អឡើយ»* (ទំនុកដំកើង ៣៤:១០)។ ប្រាកដណាស់ «ទ្រង់បាន

*ប្រទានអាហារដល់អស់អ្នកដែលកោតខ្លាចទ្រង់ ក៏នឹងនឹកចាំពីសេចក្តីសញ្ញាទ្រង់ជានិច្ចដែរ»* (ទំនុកដំកើង ១១១:៥) ហើយសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ *«ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច»* (បរិទេវ ៣:២៣)។ លោកយ៉ាកុបបានហៅទ្រង់ថា *«ជាព្រះដែលបានចិញ្ចឹមអញគ្រប់មួយជីវិតដរាបដល់សព្វថ្ងៃនេះ»* (លោកុប្បត្តិ ៤៨:១៥)។

ខ្ញុំសូមឲ្យអ្នកកត់សំគាល់មើល ពីវិធីដែលព្រះតម្រិះសម្រេចមកគង់នៅតាំងពីថ្ងៃដំបូងនៅក្នុងជីវិតរបស់អ្នក ដើម្បីអ្នកអាចមើលឃើញពីអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់អ្នក។ ជួនកាល ព្រះជាម្ចាស់ប្រទានពរបន្តិចដោយសំងាត់ តែល្មមគ្រប់គ្រាន់សម្រាប់យើង និង គ្រួសារយើង។ ព្រះពរនេះ ក៏បានកើតឡើងដល់លោកអេលីយ៉ា (១ពង្សាវតារក្សត្រ ១៧:៨-១៦)។ មនុស្សដទៃផ្សេងទៀត នៅសម័យកាលថ្មីៗនេះយល់ឃើញថា ព្រះជាម្ចាស់បានបញ្ជូនលុយ ឬអាហារនៅពេលដែលគេត្រូវការជាបន្ទាន់បំផុត។ យើងអាចមើលឃើញបញ្ញាដែលចេញពីព្រះតម្រិះសម្រេច នៅក្នុងការផ្គត់ផ្គង់ដល់សេចក្តីត្រូវការពិតប្រាកដរបស់យើង ហើយមិនប្រទានអ្វីៗដែលយើងចង់បាននោះទេ *«ព្រះនៃខ្ញុំ ទ្រង់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ»* (ភីលីព ៤:១៩)។ យើងអាចឃើញប្រាជ្ញានៃព្រះតម្រិះសម្រេច នៅក្នុងរបៀបដែលទ្រង់ផ្គត់ផ្គង់សេចក្តីត្រូវការទាំងអស់របស់អ្នកដែរ។ ព្រះជាម្ចាស់មិនប្រទានឲ្យនូវអ្វីដែលយើងត្រូវការទាំងអស់នៅពេលតែមួយនោះទេ យើងត្រូវអធិស្ឋានដោយមានជំនឿដើម្បីយើងអាចមើលឃើញភាពល្អរបស់ព្រះជាម្ចាស់កាន់តែច្បាស់ឡើង ពេលដែលទ្រង់ចាក់បំពេញសេចក្តីត្រូវការទាំងនោះ។

សូមអ្នកកុំភ្លេចពីការថែរក្សា និង សេចក្តីសប្បុរសរបស់ព្រះតម្រិះសម្រេច ដែលអ្នកធ្លាប់ពិសោធជាច្រើនរួចមកហើយ។ កុំឲ្យមិនទុកចិត្តព្រះតម្រិះសម្រេច នៅពេលអនាគតកាលឡើយ! នេះជាអ្វីដែលកូនចៅអ៊ីស្រាអែលបានធ្វើ។ ពួកគេនិយាយថា *«មើល ទ្រង់បានវាយថ្មដា ឲ្យមានទឹកផុលចេញ ហើយឲ្យជ្រោះមានទឹកជន់លិចច្រាំង*

*ដូច្នេះ តើទ្រង់អាចនឹងប្រទាននំបុ័ងដែរឬ? តើទ្រង់នឹងផ្គត់ផ្គង់ឲ្យរាស្ត្រទ្រង់មានសាច់បរិភោគឬអី?»* (ទំនុកដំកើង ៧៨:២០)។ នោះជាការមិនជឿទុកចិត្តសោះទោះបីជាពួកគេបានមើលឃើញពីអំណាចរបស់ព្រះជាម្ចាស់ ធ្វើការល្អសម្រាប់ពួកគេតាមវិធីដ៏អស្ចារ្យយ៉ាងនោះក៏ដោយ! ដូច្នេះចូរស្កប់ចិត្តនឹងឋានៈដែលព្រះតម្រិះសម្រេចបានប្រទានមកឲ្យអ្នក ហើយបើសិនជួបការលំបាក សូមអធិស្ឋានដល់ព្រះនៅពេលដែលអ្នកត្រូវការ ព្រះអង្គមិនបំភ្លេចអ្នកឡើយ (អេសាយ ៤១:១៧ និង ភីលីព ៤:៦)។ សត្វស្លាបហើរលើអាកាស មិនដឹងពីកន្លែងដែលវាត្រូវទៅ ដើម្បីស្វែងរកអាហារនោះទេ ប៉ុន្តែព្រះបានផ្គត់ផ្គង់ដល់ពួកវា (ម៉ាថាយ ៦:២៦)។ សូមនឹកចាំពីទំនាក់ទំនងរបស់អ្នកជាមួយព្រះគ្រីស្ទ និង ការសន្យារបស់ទ្រង់ចំពោះអ្នក ហើយអ្នកនឹងស្កប់ចិត្តពីអ្វីៗដែលអ្នកមាន។

## ៧• ព្រះតម្រិះសម្រេចបានញែកយើងចេញពីសេចក្តីអាក្រក់

ព្រះតម្រិះសម្រេចថែរក្សាយើងឲ្យមានសុវត្ថិភាព រួចពីការប្រហារយ៉ាងសាហាវរបស់សាតាំង មកលើព្រលឹងយើង។ ព្រះជាម្ចាស់បានសន្យាថា *«នៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន»* (១កូរិនថូស ១០:១៣)។ នៅក្នុងពិភពលោកដែលពេញដោយអំពើបាបនេះ ព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យអំពើអាក្រក់រីកសាយដូចជាទឹកជំនន់ ចេញពីនិស្ស័យនៃអំពើបាបរបស់យើងទេ។ ពេលដែលពួកមនុស្សនៅក្នុងក្រុងសូដុំម កំពុងតែប្រព្រឹត្តអំពើបាបយ៉ាងពេញទំហឹង នោះនៅខាងក្រៅផ្ទះរបស់ឡុត ព្រះតម្រិះសម្រេចបានធ្វើឲ្យពួកគេងងឹតភ្នែក (លោកុប្បត្តិ ១៩:១១)។ ព្រះតម្រិះសម្រេច បានកកូរកកាយនាងអ័ប៊ីកែលឲ្យជួបនឹងដាវីឌចំពេល ដើម្បីឃាត់ដាវីឌមិនឲ្យសម្លាប់ណាបាល និងមនុស្សរបស់គាត់ (១សាំយូអែល ២៥:៣៤)។ នៅពេលដែលស្តេចល្អ យ៉ូសាផាត មាន

ចិត្តចង់សាងមិត្តភាពជាមួយនឹងស្តេចអាក្រក់ អ័ហាស៊ីយ៉ា ព្រះជាម្ចាស់បានបញ្ឈប់ស្តេចយ៉ូសាផាតមិនឲ្យធ្វើដូច្នោះទេ ដោយព្រះអង្គធ្វើឲ្យនាវាដែលស្តេចយ៉ូសាផាតសង់នោះបានបាក់បែកទៅ (២របាក្សត្រ ២០:៣៥-៣៧)។

សូមគិតឲ្យបានល្អិតល្អន់មួយភ្លែតសិន។ និស្ស័យអាក្រក់របស់អ្នក បានទាញអ្នកឲ្យឈានទៅរកអំពើបាប ប៉ុន្តែព្រះតម្រិះសម្រេចបានរក្សាអ្នកមិនឲ្យទទួលបរាជ័យឡើយ ដូចជាពួកសាវ័កបាននិយាយថា *«តែដែលគ្រប់គ្នាកើតមានសេចក្តីល្បួង នោះគឺដោយសារតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយល្បួងលោមទេ»* (យ៉ាកុប ១:១៤)។ អ្នកយល់ឃើញហើយថា អ្នកមានលក្ខណៈដូចជាស្លាបសត្វនៅក្នុងខ្យល់នៃសេចក្តីល្បួង ដូចជាអ្នកនិពន្ធកណ្ឌទំនុកដំកើងបានសរសេរថា *«តែឯជើងទូលបង្គំបានកន្លែកចេញហៀបនឹងផុតទីហើយ ជំហាននៃទូលបង្គំបានហៀបនឹងរឥលភ្លាត់ទៅ»* (ទំនុកដំកើង ៧៣:២)។ ប្រសិនបើព្រះអម្ចាស់ មិនបានសង្គ្រោះអ្នកពីសេចក្តីល្បួងជាច្រើនដោយមេត្តាករុណាទេ នោះជាការគួរឲ្យសោកសង្រេងណាស់។ ខ្ញុំសូមប្រាប់អ្នកថា អ្នកមិនអាចរាប់សេចក្តីមេត្តាករុណា ដែលអ្នកទទួលបានពីសកម្មភាពរបស់ព្រះតម្រិះសម្រេចនោះទេ ដូច្នេះត្រូវតែអរព្រះគុណដល់ព្រះជាម្ចាស់ ហើយកុំគិតថាការគេចចេញពីអំពើបាបនោះ កើតឡើងដោយថៃដន្យ ឬដោយសារតែការដឹងខ្លួន ឬប្រាជ្ញារបស់អ្នកឡើយ *«ចូររក្សាខ្លួនក្នុងសេចក្តីស្រឡាញ់របស់ព្រះចុះ»* (យូដាស ខ.២០) ហើយ «ចូររក្សាចិត្ត ដោយអស់ពីព្យាយាម» (សុភាសិត ៤:២៣)។

## ៨• ព្រះតម្រិះសម្រេចរក្សាយើងមិនឱ្យមានជំងឺ និង គ្រោះថ្នាក់

នៅក្នុងលោកិយនេះ មានគ្រោះថ្នាក់ជាច្រើននៅជុំវិញយើង។ ក្នុងកណ្ឌ២កូរិនថូស ១១:២៣-២៧ សាវ័កប៉ុលប្រាប់យើងពីចំនួនប៉ុន្មានដងដែលគាត់ស្ទើរតែបាត់បង់ជីវិត ឬមានគ្រោះថ្នាក់នោះ។ ព្រះតម្រិះសម្រេចបានថែរក្សាយើងឲ្យមានជីវិតរស់នៅ ទោះបី

ជាយើងតែងតែមានជំងឺក៏ដោយ។ ភ្នែកជាផ្នែកតូចមួយនៃរាងកាយ តែមានជំងឺជាច្រើនមុខដែលអាចធ្វើទុក្ខបុកម្នេញ ប៉ុន្តែព្រះអាទិករបានប្រទានឲ្យមានគំរបបាំងផ្សេងៗពីកំណើតមក ដូចជារោមភ្នែកដែលអាចការពារភ្នែកនោះបាន។ ស្ដេចដាវីឌបានអធិស្ឋានថា *«សូមការពារទូលបង្គំ ដូចជាប្រស្រីភ្នែក»* (ទំនុកដំកើង ១៧:៨)។

មនុស្សជាច្រើនបានឃើញកិច្ចការដ៏អស្ចារ្យរបស់ព្រះតម្រិះសម្រេច ពេលដែលគេជិះទូកចេញទៅឯសមុទ្រ ឬធ្វើជាកម្មករនាវា។ អ្នកនិពន្ធកណ្ឌទំនុកដំកើងបាននិយាយពីពួកនោះនៅក្នុងកណ្ឌទំនុកដំកើង ១០៧:២៣-៣០ ថា អស់អ្នកណាដែលចំណាយពេលជាច្រើនឆ្នាំនៅឯសមុទ្រ ក៏មានគ្រោះថ្នាក់យ៉ាងធំ ហើយស្ទើរតែលាលោកិយនេះជារៀងរាល់ថ្ងៃ។ គេមានមូលហេតុដែលត្រូវសរសើរដំកើងដល់ព្រះ សម្រាប់ភាពល្អ និងសម្រាប់ការប្រព្រឹត្តដ៏អស្ចារ្យរបស់ទ្រង់ចំពោះមនុស្ស!

ប្រវត្តិសាស្ត្របានផ្ដល់នូវឧទាហរណ៍ច្រើនរាប់មិនអស់ពីជីវិត ដែលព្រះជាម្ចាស់បានថែរក្សាដោយសេចក្ដីសប្បុរសរបស់ទ្រង់ ហើយខ្ញុំគិតថា យើងភាគច្រើនអាចស្គាល់ព្រះតម្រិះសម្រេចទាំងនោះពីបទពិសោធន៍របស់យើង។ សូមពិចារណាពីអ្វីដែលអ្នកគួរជំពាក់ព្រះតម្រិះសម្រេច សម្រាប់ការដែលទ្រង់ការពារអ្នករហូតដល់សព្វថ្ងៃនេះ សូមគិតពីរបៀបគ្រប់ផ្នែកទាំងអស់នៃរាងកាយរបស់អ្នក ដែលព្រះអង្គបានការពារមិនឲ្យមានគ្រោះថ្នាក់ ទោះបីមុនពេលអ្នកស្គាល់ព្រះជាម្ចាស់ជាព្រះអង្គសង្គ្រោះរបស់អ្នក អ្នកបានប្រើរាងកាយនោះ សម្រាប់គោលបំណងរបស់អំពើបាបក៏ដោយ ក៏ព្រះអង្គមានសេចក្ដីសប្បុរស និង សេចក្ដីអត់ធ្មត់ដ៏ធំធេងណាស់ចំពោះយើងដែរ។

ចុះហេតុអ្វីបានជាព្រះតម្រិះសម្រេច បង្ហាញពីការថែរក្សានេះដល់អ្នកដូច្នេះ? គឺដើម្បីឲ្យអ្នកប្រើប្រាស់រូបកាយរបស់អ្នកសម្រាប់បម្រើព្រះអង្គ។ បើអ្នកជាគ្រីស្ទបរិស័ទ រូបកាយរបស់អ្នកគឺជាផ្នែកមួយនៃការទិញរបស់ព្រះគ្រីស្ទ។ រូបកាយនោះ ស្ថិតក្រោមការថែរក្សាពីពួកទេវតា ហើយនិងចូលរួមជាមួយភាពរុងរឿង និង សុភមង្គលរបស់

ផែនដី ដែលនឹងមកនៅថ្ងៃអនាគត (១កូរិនថូស ៦:២០, ហេព្រើរ ១:១៤ ភីលីព ៣:២១)។ ដូច្នេះ នោះជាការសមហេតុផលណាស់ដែលថា រូបកាយរបស់យើងគួរតែប្រើនៅក្នុងកិច្ចការរបស់ព្រះ ទោះបីជាមានការហត់ល្ហើយក៏ដោយ!

## ៩. ព្រះតម្រិះសម្រេចជួយយើងឱ្យបានបរិសុទ្ធឡើង

ព្រះជាម្ចាស់បានប្រាប់រាស្ត្រទ្រង់ថា ពួកគេគួរតែរាប់ខ្លួនគេ *«ទុកជាស្លាប់ខាងឯបាបដែរ តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»* (រ៉ូម ៦:១១)។ ព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងយើង បានប្រទានឲ្យយើងមានចិត្ត ចង់ធ្វើឲ្យអំពើបាបនៅក្នុងរូបកាយរបស់យើងវិនាស ហើយក៏ជួយយើងឲ្យធ្វើការនោះផង។ព្រះជាម្ចាស់ដែលមានបញ្ញាញាណជាទីបំផុតនោះបានបង្គាប់ព្រះតម្រិះសម្រេចឲ្យធ្វើកិច្ចការជាមួយព្រះវិញ្ញាណ ដើម្បីឲ្យបានលទ្ធផលដូចគ្នា។

លោកប៉ុលបានរអ៊ូរទាំពីច្បាប់នៃអំពើបាប ដែលមានក្នុងអវៈយវៈរបស់រូបកាយគាត់ (រ៉ូម ៧:២៣) ហើយអ្នកជឿព្រះអង្គគ្រប់រូប ក៏បានឃើញការទាំងនេះកើតឡើងជារៀងរាល់ថ្ងៃ ចំពោះភាពសោកសៅរបស់លោកប៉ុល។ ប៉ុន្តែ ព្រះវិញ្ញាណដែលនៅក្នុងអ្នកជឿបានបដិសេធនឹងការទោរទន់ឲ្យធ្វើបាបពីខាងក្នុងមក ហើយព្រះតម្រិះសម្រេចបានបិទផ្លូវរបស់យើងនៅខាងក្រៅ ដើម្បីមិនឲ្យយើងធ្លាក់ទៅក្នុងអំពើបាប (ហូសេ ២:៦ និង ២កូរិនថូស ១២:៧)។ ជាញឹកញាប់ ព្រះជាម្ចាស់ឲ្យយើងធ្លាក់ទៅក្នុងបញ្ហាដូចជាមានជំងឺ ដើម្បីឲ្យយើងអាចមើលឃើញ និង ដឹងពីកម្លាំងរបស់អំពើបាបនៅក្នុងយើង ហើយឲ្យការទាំងនោះនាំយើងត្រឡប់ទៅកាន់ទ្រង់វិញ។ អ្នកនិពន្ធកណ្ឌទំនុកដំកើងនិយាយថា *«កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ នោះទូលបង្គំបានវង្វេងទៅ តែឥឡូវនេះទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់វិញ»* (ទំនុកដំកើង ១១៩:៦៧) ជួនកាល សេចក្តីស្រឡាញ់របស់រាស្ត្រនៃព្រះជាម្ចាស់ បានផ្ទង់ទៅការល្អនៅលើផែនដី

នេះ។ ទឹកចិត្តរបស់ស្តេចហេសេគាបានផ្ចង់ទៅលើទ្រព្យសម្បត្តិរបស់ទ្រង់ ហើយបន្ទាប់ពីបង្ហាញទ្រព្យសម្បត្តិដោយអំនួតទាំងនោះ ទៅមនុស្សមកពីក្រុងបាប៊ីឡូនហើយ នោះហោរាអេសាយបានប្រាប់ទ្រង់ថា មិនយូរប៉ុន្មានទេ ពួកអ្នកទាំងនោះនឹងយកទ្រព្យសម្បត្តិទាំងអស់នោះទៅស្រុកបាប៊ីឡូន (អេសាយ ជំពូក៣៩)។ ស្តេចដ៏ល្អ គឺស្តេចដាវីឌ ទ្រង់ស្រឡាញ់អាប់សាឡុំមជាបុត្ររបស់ទ្រង់ដែលមានរូបរាងសង្ហា តែល្ងីល្ងើដោយសេចក្តីស្រឡាញ់ជាខ្លាំងណាស់។ ព្រះជាម្ចាស់បានប្រើការស្លាប់ភ្លាមៗ និងយ៉ាងសាហាវរបស់អាប់សាឡុំម ដើម្បីជួយឲ្យស្តេចដាវីឌមើលឃើញពីអ្វីដែលទ្រង់បានធ្វើខុសប៉ុណ្ណោះ (២សាំយូអែល ជំពូក១៥-១៩)។

អំពើបាបដែលមានសល់នៅក្នុងខ្លួនយើង បានបង្ហាញខ្លួនវាជាអំនួត។ នៅពេលដែលគេលើកសរសើរយើង អំនួតនៅក្នុងចិត្តនោះក៏កាន់តែរីកធំឡើង ដូច្នេះហើយបានជាមានមនុស្សល្អម្នាក់និយាយថា *«អ្នកណាដែលសរសើរខ្ញុំ នោះគឺធ្វើឲ្យខ្ញុំមានរបួសវិញ»*។ ចិត្តដែលពេញដោយអំពើបាបរបស់យើង ក៏បាននាំឲ្យយើងសង្ឃឹមថាមានសុភមង្គល និង មានក្តីអំណរនៅក្នុងទ្រព្យលើផែនដីនេះដែរ ដូចជាលោកយ៉ូបនិយាយថា *«ខ្ញុំនឹងស្លាប់ក្នុងសំបុកខ្ញុំ ហើយនឹងចំរើនថ្ងៃអាយុខ្ញុំដូចជាខ្សាច់»* (យ៉ូប ២៩:១៨)។ សេចក្តីសង្ឃឹមទាំងនោះ មិនយូរប៉ុន្មានស្រាប់តែដល់ទីបញ្ចប់ ដោយសារសកម្មភាពនៃព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់។ មនុស្សប្រុសដែលល្អបំផុត ពឹងនៅលើអ្វីដែលគេទទួលបានសម្រាប់ការកំសាន្តចិត្តរបស់គេ ជំនួសឲ្យការពឹងដល់ព្រះជាម្ចាស់វិញ ដូចជាកូនចៅអ៊ីស្រាអែលបានពឹងលើពួកអេស៊ីព្ទ ប៉ុន្តែព្រះជាម្ចាស់បានធ្វើឲ្យពួកអេស៊ីព្ទបរាជ័យ ហើយមានរបួសផង (អេសេគាល ២៩:៦-៨)។ ជួនកាល ព្រះជាម្ចាស់បានអនុញ្ញាតឲ្យមានសេចក្តីស្លាប់ កើតមានដល់សមាជិកគ្រួសារដែលជាទីស្រឡាញ់របស់យើង ហើយតាមវិធីនេះ ទ្រង់បានបំផ្លាស់សេចក្តីស្រឡាញ់នៃចិត្តរបស់យើង ឲ្យចេញឆ្ងាយពីមនុស្សនោះ ដើម្បីឲ្យបានសម្រាកនៅក្នុងព្រះជាម្ចាស់វិញ។

ដូច្នេះ ដើម្បីសរុបសេចក្តីនៅក្នុងជំពូកទីពីរនេះ ខ្ញុំសូមអ្នកគិតឲ្យបានស៊ីជម្រៅទៅលើភាពអស្ចារ្យរបស់ព្រះជាម្ចាស់ ក្នុងកិច្ចការទ្រង់ចំពោះយើងរាល់គ្នា។ ស្តេចដាវីឌបានសរុបគំនិតខ្ញុំ នៅក្នុងទំនុកដំកើង ១៤៤:៣ ដែលសំដែងថា *«ឱព្រះយេហូវ៉ាអើយ តើមនុស្សជាអ្វី បានជាទ្រង់យកចិត្តទុកដាក់នឹងគេ ឬកូនមនុស្ស បានជាទ្រង់រាប់អានដូច្នេះ!»* រីឯស្តេចសាឡូម៉ូនបានគិតពីភាពធំឧត្តមរបស់ព្រះ ហើយមានបន្ទូលថា *«...ដ្បិតផ្ទៃមេឃ នឹងអស់ទាំងជាន់នៃផ្ទៃមេឃ មិនល្មមឲ្យទ្រង់គង់ចុះទៅហើយ...»* (២របាក្សត្រ ២:៦)។ ហោរាអេសាយបានប្រកាសថា *«មើល អស់ទាំងសាសន៍ប្រៀបដូចជាទឹកមួយដំណក់នៅក្នុងថាំង... អស់ទាំងសាសន៍រាប់ដូចជាទទេសោះនៅចំពោះទ្រង់»* (អេសាយ ៤០:១៥, ១៧)។ ប៉ុន្តែ មនុស្សគ្រប់រូបមានអំពើបាបយ៉ាងខ្លាំង ហើយមិនគួរនឹងទទួលអ្វី ទោះបីជាមានលក្ខណៈដ៏ល្អយ៉ាងណាក៏ដោយ។ ជីវិតរបស់គាត់ហាក់ដូចជានៅទទេ ហើយឆ្នាំរបស់គាត់ហាក់ដូចជាគ្មានអ្វីសោះនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។

ជាការអស្ចារ្យដែលព្រះដ៏ធំនេះបានគិតគូរជាច្រើនដល់យើង ហើយក៏ធ្វើកិច្ចការសម្រាប់យើង ដោយព្រះតម្រិះសម្រេចទាំងអស់របស់ទ្រង់ផង! ព្រះអង្គមិនត្រូវការយើងទេ ទ្រង់ស្កប់ព្រះទ័យដោយទ្រង់ផ្ទាល់ មិនចាំបាច់មានយើងឡើយ។ យើងមិនអាចបន្ថែមអ្វីទៅចំពោះទ្រង់បានទេ ទ្រង់ជ្រើសរើសយើងឲ្យធ្វើជារាស្ត្រព្រះអង្គ ដោយឥតគិតថ្លៃ ហើយដោយសារព្រះគុណ និង សេចក្តីស្រឡាញ់ដ៏នៅអស់កល្បរបស់ទ្រង់។ បើស្តេចដាវីឌអាចមានបន្ទូលនៅក្នុងកណ្ឌទំនុកដំកើង ៨:៣,៤ ថា *«កាលណាទូលបង្គំពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ គឺទាំងខែនឹងផ្កាយ ដែលទ្រង់បានប្រតិស្ឋានទុក នោះតើមនុស្សជាអ្វី?»* នោះយើងក៏អាចនិយាយបានច្រើនជាងនេះទៀតថា «កាលដែលយើងគិតពីព្រះរាជបុត្រានៃទ្រង់ គឺពីបុត្រជាទីស្រឡាញ់តែមួយអង្គគត់ ដែលទ្រង់អស្ចារ្យ ហើយល្អហួសពីគំនិតយើងអាច

គិតដល់ទៅទៀត ឱព្រះអម្ចាស់អើយ តើមនុស្សជាអ្វីទៅ ដែលព្រះគ្រីស្ទត្រូវរងទុក្ខ របួតដល់សុគតសម្រាប់មនុស្ស?»

សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់គឺ «ថ្មីជារៀងរាល់ព្រឹក» *(សូមមើលក្នុងទំនុកដំកើង ៩០:៥, បរិទេវ ៣:២៣)*។ ព្រះតម្រិះសម្រេចមានលក្ខណៈដូចជាប្រភពទឹកដែលមានភាពល្អរបស់ព្រះជាម្ចាស់ ហូរចេញតាមរយៈការដែលទាក់ទងទៅនឹងជីវិតនេះ ហើយជីវិតដែលនឹងមកនៅពេលអនាគតកាល តាមរបៀបជាសាធារណៈ និង ផ្ទាល់ខ្លួននៅក្នុងព្រឹត្តិការណ៍សាមញ្ញ និង វិសាមញ្ញ ដែលមិនអាចរៀបរាប់បាន ហើយគ្រប់ការទាំងអស់ដែលបានកើតឡើងចំពោះអ្នកជឿព្រះអង្គ នោះទេវតានឹងមើលថែរក្សាយើង (ហេព្រើរ ១:១៤)។

# ជំពូក ៣

## ហេតុអ្វីបានជាយើងត្រូវគិតយ៉ាងជ្រៅពីព្រះតម្រិះសម្រេចដ៏វិសេសនោះ

ដោយសារយើងបានឃើញវិធីដែលព្រះជាម្ចាស់ថែរក្សារាស្ត្រទ្រង់ ដោយព្រះតម្រិះសម្រេចដ៏វិសេសនោះយើងក៏ដឹងថា ព្រះអង្គបានបង្គាប់ឲ្យយើងគិតយ៉ាងប្រាកដប្រជា អំពីការប្រព្រឹត្តរបស់ទ្រង់ ជាពិសេសនៅពេលដែលមានបញ្ហាលំបាក។ បើយើងធ្វើតាម ការនោះនឹងពង្រឹងជំនឿរបស់យើង (ម៉ាថាយ ៦:២៨)។ បើសិនជាមិនធ្វើដូច្នេះនោះមិនបានធ្វើឲ្យព្រះអង្គសព្វព្រះហឫទ័យទេ (ទំនុកដំកើង ២៨:៤, ៥)។ ប្រសិនបើយើងមិនបានសង្កេតមើលការប្រព្រឹត្តនៃព្រះតម្រិះសម្រេចឲ្យបានត្រឹមត្រូវទេ នោះយើងមិនអាចសរសើរដំកើងថ្វាយព្រះជាម្ចាស់សម្រាប់កិច្ចការនោះបានទេ។ នៅកណ្ឌទំនុកដំកើង ជំពូក១០៧ បានប្រាប់ពីការថែរក្សានៃព្រះតម្រិះសម្រេចរបស់ទ្រង់ ចំពោះរាស្ត្រព្រះអង្គនៅពេលដែលមានសេចក្តីវេទនា (ខ.៤-៧) និង ការថែរក្សាដល់ពួកអ្នកជាប់គុក (ខ.១០-១៤) និង ដល់ពួកមនុស្សដែលមានជំងឺ (ខ.១៧-២០) ដល់ពួកអ្នកជិះទូកនៅឯសមុទ្រក្នុងពេលដែលមានខ្យល់ព្យុះ(ខ.២៣-៣០)និងដល់មនុស្សនៅពេលគេអត់មានអាហារ (ខ.៣៣-៤០)។ ព្រះអង្គត្រាស់ហៅឲ្យសរសើរដំកើងព្រះជាម្ចាស់សម្រាប់កិច្ចការនៃព្រះតម្រិះសម្រេចទាំងនេះ ហើយនៅក្នុងខ.៤៣ អ្នកនិពន្ធកណ្ឌទំនុកដំកើងនិយាយថា *«បើអ្នកណាមានប្រាជ្ញា នោះនឹងរក្សាទុកនូវសេចក្តីទាំងនេះ ហើយនឹងពិចារណាពីសេចក្តីសប្បុរសរបស់ព្រះយេហូវ៉ា»*។

តាមរយៈការសង្កេតទាំងនេះ ជំនឿរបស់យើងបានរឹងមាំឡើង។ ការប្រព្រឹត្តនៃព្រះតម្រិះសម្រេចពីអតីតកាល បានលើកទឹកចិត្តស្តេចដាវីឌឲ្យឈានទៅរកជ័យជំនះនៅក្នុងថ្ងៃអនាគត។ *«ព្រះយេហូវ៉ា ជាព្រះដែលបានជួយទូលបង្គំ ឲ្យរួចពីក្រចកសិង្ហ នឹងខ្លាឃ្មុំ ទ្រង់ក៏នឹងជួយឲ្យរួចពីកណ្តាប់ដៃសាសន៍ភីលីស្ទីននោះដែរ»* (១សាំយូអែល ១៧:៣៧)។ លោកប៉ុលបាននិយាយអំពីព្រះជាម្ចាស់ថា *«ទ្រង់បានប្រោសយើងខ្ញុំ ឲ្យរួចពីសេចក្តីស្លាប់យ៉ាងសំបើមនោះហើយ ក៏ចេះតែប្រោសឲ្យរួចតទៅ ហើយយើងខ្ញុំសង្ឃឹមថា ទ្រង់នឹងប្រោសឲ្យរួចទៅមុខទៀតដែរ»* (២កូរិនថូស ១:១០)។ ពួកសាវ័កបានទទួលការស្តីបន្ទោសពីព្រះយេស៊ូវ ពីព្រោះពួកគេមិនបានចងចាំ ឬយល់ពីការអស្ចារ្យដែលទ្រង់បានចំអែតហ្វូងមនុស្សដោយសារតែនំប៉័ង និង ត្រីខ្លះប៉ុណ្ណោះ (ម៉ាថាយ ១៦:៩, ១០)។

# ជំពូក ៤

## យើងគួរតែគិតពីព្រះតម្រិះសម្រេចដ៏វិសេសនេះយ៉ាងដូចម្ដេច

### ១• គួរគិតយ៉ាងល្អិតល្អន់ពីព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់

អេសាភនិយាយថា *«ទូលបង្គំនឹងរឭកពីអស់ទាំងការនៃព្រះយេហូវ៉ា ដ្បិតទូលបង្គំនឹកឃើញអស់ទាំងការអស្ចារ្យ ដែលទ្រង់បានធ្វើកាលពីដើម ទូលបង្គំនឹងរំពឹងគិតពីគ្រប់ទាំងការរបស់ទ្រង់ ហើយពិចារណាពីកិច្ចដែលទ្រង់ធ្វើទាំងប៉ុន្មាន»* (ទំនុកដំកើង ៧៧:១១, ១២)។ នៅពេលអ្នកនឹកចាំពីអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់អ្នកតាំងពីដើមរហូតមកដល់ពេលនេះ ចិត្តរបស់អ្នកនឹងបន្ទន់ទៅមុននឹងអ្នកនឹកចាំដល់ពាក់កណ្ដាលនៃអ្វីដែលទ្រង់បានធ្វើសម្រាប់អ្នកនោះ។ ប្រសិនបើចិត្តរបស់អ្នកមិនដូច្នេះទេ ចិត្តនោះគឺជាចិត្តរឹងមែនហើយ។ គ្មានប្រវត្តិរឿងដ៏គួរឲ្យសប្បាយរីករាយដូច្នេះ ឲ្យអ្នកអានគ្រប់កាលៈទេសៈបាន ដូចជាប្រវត្តិជីវិតរបស់ខ្លួនអ្នកផ្ទាល់នោះទេ។

សូមនៅតែសម្លឹងមើលទៅផ្លូវរបស់ព្រះជាម្ចាស់ ដែលទ្រង់បានដឹកនាំអ្នករហូតដល់អ្នកយល់ពីវិធីនោះបានច្បាស់លាស់។ អ្នកបម្រើលោកអេលីយ៉ា នៅតែសម្លឹងមើលទៅផ្ទៃមេឃ រហូតដល់គាត់មើលឃើញដុំពពកតូចមួយ ដែលភ្លាមនោះបានបាំងផ្ទៃមេឃបាត់។ ដូច្នេះ ជាដំបូងអ្នកអាចមើលឃើញព្រះតម្រិះសម្រេចខ្លះ ហើយមើលឃើញនៅក្នុងព្រះតម្រិះសម្រេចនោះបន្តិចបន្តួច ឬមិនឃើញអ្វីសោះ ប៉ុន្តែសូមមើលឲ្យបាន «៧ដង» នោះអ្នកនឹងមើលឃើញសិរីល្អរបស់ព្រះតម្រិះសម្រេចចម្រើនឡើង ដូចជាការកើនឡើងនៃដុំពពកអ៊ីចឹងដែរ។ មានការជាច្រើនដែលត្រូវយកមកពិចារណា

មុនពេលដែលអ្នកវាយតម្លៃពីព្រះតម្រិះសម្រេច។ មានការកំណត់ពីព្រឹត្តិការណ៍ដែលកើតឡើង មានលក្ខណៈផ្ទាល់ខ្លួននៃអ្វីដែលកើតឡើងជាពិសេស មានវិធីនៃការសំដែងរបស់សេចក្តីសប្បុរស ដែលអាចនាំទៅកាន់វិធីដទៃផ្សេងៗជាច្រើនទៀត ហើយនិងវិធីមិនគិតថាព្រះតម្រិះសម្រេចអាចប្រើបាន។ បន្ទាប់មក យើងត្រូវគិតពីគោលបំណងរបស់ព្រះតម្រិះសម្រេចចំពោះអ្វីដែលបានកើតឡើងនៅក្នុងជីវិតយើង *«តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់»* (រ៉ូម ៨:២៨)។

ទីបំផុត ព្រះតម្រិះសម្រេចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការអធិស្ឋាន។ នៅពេលដែលព្រះជាម្ចាស់ប្រទានឲ្យនូវអ្វីដែលអ្នកសូម នោះដូចជាច្បាស់ណាស់ គឺព្រះតម្រិះសម្រេចបានមក ដោយសារការអធិស្ឋានរបស់អ្នក។

## ២. គួរគិតពីរបៀបដែលព្រះតម្រិះសម្រេចបំពេញព្រះបន្ទូល

លោកយ៉ូស្វេនិយាយទៅកាន់កូនចៅអ៊ីស្រាអែលថា *«អស់ទាំងសេចក្តីល្អដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់បានមានបន្ទូលសន្យាហើយ នោះគ្មានខ្វះណាមួយសោះ»* (យ៉ូស្វេ ២៣:១៤) ការសន្យានេះ មានជាពិតប្រាកដចំពោះរាស្ត្រទ្រង់ទាំងអស់។ បើសិនជាយើងមានការពិបាកនឹងអ្វីដែលកើតឡើងនៅជុំវិញយើង សូមមើលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹងថាទ្រង់មានបន្ទូលដូចម្តេចចំពោះការទាំងនោះ ហើយមិនយូរប៉ុន្មាន យើងនឹងមានសន្តិភាពនៅក្នុងចិត្តយើង។ អ្នកនិពន្ធកណ្ឌទំនុកដំកើងយល់ថាការនេះកើតឡើងជាពិតប្រាកដ នៅពេលគាត់ចូលទៅក្នុងទីបរិសុទ្ធរបស់ព្រះជាម្ចាស់ គាត់សរសេរថា *«ហើយបានពិចារណាពីចុងបំផុតរបស់គេ»* (ទំនុកដំកើង ៧៣:១៧)។

ដើម្បីផលប្រយោជន៍របស់យើងផ្ទាល់ យើងត្រូវរក្សាសេចក្តីពិតរបស់ព្រះបន្ទូល បើសិនយើងមិនបានរក្សាទុកទេ កិច្ចការរបស់ព្រះតម្រិះសម្រេចនឹងបង្ហាញយើងពី

ចំណុចដែលយើងកំពុងតែប្រព្រឹត្តមិនត្រឹមត្រូវ ដូចជាបានបង្ហាញដល់ស្តេចដាវីឌនៅពេលដែលទ្រង់ប្រព្រឹត្តអំពើបាបយ៉ាងអាក្រក់ (២សាំយូអែល ១២:១១, ១២)។ ព្រះបន្ទូល បានប្រាប់យើងថា ជាការល្អដែលយើងត្រូវជឿទុកចិត្តនៅក្នុងព្រះអម្ចាស់ ជាជាងទុកចិត្តដល់មនុស្ស។ ពិតណាស់ ព្រះបន្ទូលបានដាក់បណ្តាសាដល់អស់អ្នកណាដែលទុកចិត្តដល់មនុស្ស ជាជាងទុកចិត្តព្រះអង្គ (ទំនុកដំកើង ១១៨:៨ និង យេរេមា ១៧:៥)។ ព្រះបន្ទូលបានសន្យាយ៉ាងច្បាស់ថា ព្រះតម្រិះសម្រេចនឹងថែរក្សាយើងសម្រាប់ព្រះអង្គ! ព្រះបន្ទូលសំដែងថា មិនដែលមានអ្នកណាបាត់អ្វី នៅពេលបានលះបង់ចោលផ្ទះសំបែង ឬទ្រព្យសម្បត្តិ ដើម្បីតែដំណឹងល្អនោះទេ (ម៉ាកុស ១០:២៩, ៣០)។ លោកសាវកប៉ុលបានធ្វើការនេះមែន គាត់បាននិយាយថា *«ដូចជាគ្មានអ្វីសោះ តែមានគ្រប់ទាំងអស់វិញ»* (២កូរិនថូស ៦:១០)។ ចាប់តាំងពីសម័យលោកប៉ុល មានមនុស្សរាប់ពាន់នាក់យល់ឃើញថា ពួកគេទទួលការផ្គត់ផ្គង់ច្រើនជាងពួកគេធ្លាប់មានតាំងពីមុនមក ដោយព្រោះពួកគេស្តាប់បង្គាប់ និង ទុកចិត្តទៅក្នុងសេចក្តីសន្យារបស់ព្រះជាម្ចាស់។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បញ្ជាក់ថា ទោះបីជាមនុស្សបរិសុទ្ធរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ព្រះរបស់គេមិនចាកចេញពីគេ ឬលះបង់គេចោលឡើយ(ហេព្រើរ ១៣:៥) ព្រះអង្គគង់ជាមួយគេ ទោះជាគេស្ថិតនៅក្នុងកាលៈទេសៈលំបាកក៏ដោយ (ទំនុកដំកើង ៩១:១៥)។ សូមសួរខ្លួនអ្នកផ្ទាល់ថា ព្រះជាម្ចាស់ដែលធ្លាប់ចាកចេញពីអ្នក ទុកឲ្យអ្នកដួលក្រោមបន្ទុករបស់អ្នកឬទេ អ្នកប្រហែលជាមានអារម្មណ៍ដូចជាដាវីឌដែរ ខណៈដែលគាត់និយាយថា *«មានថ្ងៃណាមួយអញនឹងស្លាប់ ដោយសារដៃសូលជាមិនខាន»* (១សាំយូអែល ២៧:១) ប៉ុន្តែដូចជាដាវីឌដែរ គឺអ្នកបានចេញពីការលំបាក ហើយការសន្យារបស់ព្រះក៏បានចាក់បំពេញគ្រប់យ៉ាង។ អ្នកបានអានមកហើយថា ព្រះបន្ទូលជាជំនួយ និង ជាការកំសាន្តចិត្តតែមួយគត់ នៅពេលដែលអ្នក

ស្ថិតក្នុងស្ថានភាពមានជំងឺដ៏ធ្ងន់ធ្ងរនោះ (ទំនុកដំកើង ១១៩:៥០, ៩២) ហើយក៏មានការសរសេរកត់ត្រាទុកសម្រាប់ផែនការនេះ (រ៉ូម ១៥:៤)។ តើនេះប្រាកដជាកើតចេញពីបទពិសោធន៍នៅក្នុងមនុស្សរាប់ពាន់នាក់ឬអី? ប្រសិនបើព្រះតម្រិះសម្រេចបានបង្ហាញការសន្យាយ៉ាងដូច្នេះដល់អ្នក និង បញ្ជាក់ដល់អ្នកថា ព្រះអម្ចាស់ស្រឡាញ់អ្នក ហើយនៅជាមួយអ្នក នោះបន្ទុករបស់អ្នកនឹងស្រាលជាងមុន! ព្រះតម្រិះសម្រេចក៏មានលក្ខណៈដូចគ្នានឹងព្រះបន្ទូលដែលសំដែងថា វិធីតែមួយគត់ដែលបង្កើនទ្រព្យសម្បត្តិរបស់អ្នក គឺការឲ្យទៅអ្នកដទៃដោយក្តីអំណរ ដូចជាឲ្យទៅព្រះជាម្ចាស់ដែរ (សុភាសិត ១១:២៤, ២៥, ១៩:១៧)។ វិធីដែលល្អបំផុត ដើម្បីឲ្យបានសេចក្តីសុខសាន្តក្នុងគំនិតនោះ គឺត្រូវធ្វើតាមព្រះបន្ទូលដែលបានសរសេរទុក និង ប្តេជ្ញានឹងថ្វាយខ្លួនយើងផ្ទាល់ ព្រមទាំងគ្រប់យ៉ាងដែលធ្វើឲ្យយើងមានការខ្វល់ខ្វាយនោះ ទៅព្រះអង្គវិញ (ទំនុកដំកើង ៣៧:៥-៧ សុភាសិត ១៦:៣)។

ខ្ញុំមិនមែននិយាយថា អ្នកជឿព្រះអង្គមិនដែលឈឺចាប់នោះទេ ហើយខ្ញុំក៏មិននិយាយថា ព្រះជាម្ចាស់តែងតែដាក់ទោសភ្លាមៗ ដល់អ្នកដែលប្រព្រឹត្តអំពើបាបនោះដែរ *(ប្រសិនបើទ្រង់ធ្វើមែន តើអ្នកអាចទ្រាំបានទេ? (ទំនុកដំកើង ១៣០:៣)*។ ប៉ុន្តែខ្ញុំនិយាយដូច្នេះថា ពេលដែលព្រះអង្គឈឺចាប់ចំពោះកូនៗរបស់ទ្រង់ នោះសេចក្តីសប្បុរសក៏កើតមានឡើងដែរ ហើយដោយសារតែព្រះតម្រិះសម្រេចទាំងនោះហើយបានជាព្រះអង្គចាក់បំពេញការព្រមាន ដូចជាចាក់បំពេញការសន្យារបស់ព្រះបន្ទូលដែរ។

## ៣• ចូរដឹងប្រាកដថា អ្នកមើលឃើញព្រះអង្គជាអ្នកបណ្តាល និង បង្គាប់ឱ្យមានព្រឹត្តិការណ៍នៃព្រះតម្រិះសម្រេចទាំងអស់នោះកើតឡើង

ព្រះជាម្ចាស់ ជា *«ព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូក»* (២កូរិនថូស ១:៣) ហើយ *«ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌*

*ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ»* (ម៉ាថាយ ៦:៣២)។ អ្នកគ្រាន់តែទូលសូមដល់ទ្រង់ពីអ្វីដែលអ្នកត្រូវការ ដើម្បីឲ្យបានរួចពីការថប់បារម្ភ (ភីលីព ៤:៦)។ សូមមើលពីប្រាជ្ញានៃព្រះគុណរបស់ព្រះជាម្ចាស់ ដែលប្រទានឲ្យទទេ ជារបៀបដែលអ្នកទទួលសេចក្តីមេត្តាករុណា ហើយអ្នកបានសេចក្តីមេត្តាករុណាទាំងនោះ តាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទ និង ការសន្យានៃព្រះគុណ (១កូរិនថូស ៣:២២, ២៣)។

សូមកុំភ្លេចថា ព្រះអង្គទ្រង់ជាមហាក្សត្រ ទ្រង់ជាមួយអង្គដែលប្រសើរជាងអ្នករាល់គ្នាឆ្ងាយណាស់ ទ្រង់មានគ្រប់ព្រះចេស្តា ដែលធ្វើអ្វីតាមព្រះហឫទ័យទ្រង់ (ទំនុកដំកើង ១១៥:៣)។ មិនច្រើនឆ្នាំប៉ុន្មានមុននេះ អ្នកមិនទាន់កើតនៅឡើយទេ នៅពេលណាដែលព្រះអង្គសព្វព្រះហឫទ័យនាំអ្នកមកក្នុងលោកិយនេះ នោះអ្នកមិនមានជំរើសអ្វីថាត្រូវទៅទីណា ឬរស់នៅក្នុងស្ថានភាពបែបណា ពេលដែលអ្នកកើតមកនោះទេ។

យើងអាចឃើញព្រះជាម្ចាស់ នៅក្នុងការព្រួយព្រះទ័យខាងព្រះតម្រិះសម្រេចផងដែរ។ សូមមើលពីព្រះគុណ និង ភាពល្អរបស់ព្រះជាម្ចាស់ នៅក្នុងហេតុការណ៍ដែលមានទុក្ខព្រួយកើតឡើងទាំងប៉ុន្មានផង ដែលទោះបីជាស្ថិតនៅក្នុងសភាពដ៏ពិបាកបំផុតក៏ដោយ ក៏យើងមើលឃើញភាពល្អពីរយ៉ាង គឺសេចក្តីមេត្តាករុណាដែលនៅតែមានក្នុងផែនដីនេះ និង សេចក្តីមេត្តាករុណាក្នុងការសង្គ្រោះរាស្ត្រទ្រង់សម្រាប់ផែនដីដែលនឹងមកនៅថ្ងៃអនាគត។ ដូច្នេះ សូមសម្លឹងមើលប្រាជ្ញារបស់ព្រះជាម្ចាស់ នៅក្នុងគ្រប់ទាំងការលំបាករបស់អ្នក! ពេលវេលា និង ចំនួននៃការឈឺចាប់ នោះមានន័យថា ព្រះជាម្ចាស់មិនមែនមិនជួយយើងនោះទេ។ សូមមើលការទាំងនេះ ហើយសួរខ្លួនអ្នកពីសំណួរដែលព្រះជាម្ចាស់បានសួរទៅលោកយ៉ូណាសថា*«ការដែលឯងខឹង...តើគួរឬ?»* (យ៉ូណាស ៤:៩)។ សេចក្តីស្មោះត្រង់របស់ព្រះអម្ចាស់ គឺមានន័យថា ទ្រង់នឹងដាក់ទោសនៅពេលណាដែលចាំបាច់ ហើយទ្រង់មិនបោះបង់រាស្ត្រទ្រង់ចោល នៅពេល

ដែលទ្រង់ដាក់ទោសពួកគេទេ (១ពេត្រុស ១:៦ និង ២កូរិនថូស ៩:៩)។ តើអ្នកអាចមើលឃើញអ្វីនៅក្នុងព្រះជាម្ចាស់ ច្រើនជាងអ្វីដែលអ្នកឃើញនៅក្នុងមនុស្ស ឬក្នុងអ្វីដែលអ្នកបានបាត់បង់ទៅឬទេ? ព្រះអង្គជាថ្មដាដ៏រឹងមាំ និង មិនប្រែប្រួល ដូចជាព្រះគម្ពីរសំដែងថា *«ទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ»* (ហេព្រើរ ១៣:៨)។ នៅក្នុងស្ថានភាពរបស់អ្នក ប្រហែលក្នុងរយៈពេលតែ២-៣ថ្ងៃ នោះក៏មានការផ្លាស់ប្តូរទៅហើយ ប៉ុន្តែព្រះជាម្ចាស់ទ្រង់មិនប្រែប្រួលសោះ គឺពេលវេលាមិនអាចធ្វើឲ្យទ្រង់មានការផ្លាស់ប្តូរឡើយ *«ស្មៅក៏ស្វិតក្រៀម ហើយផ្ការោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប»* (អេសាយ ៤០:៨)។

## ៤• សូមបើកចិត្តរបស់អ្នក ដើម្បីបានយល់ពីវិធីផ្សេងៗនៃព្រះតម្រិះសម្រេច របស់ព្រះជាម្ចាស់ (សាស្តា ៧:១៤)

មានសេចក្តីកំសាន្តចិត្តពីរយ៉ាង គឺខាងសាច់ឈាម និង ខាងព្រលឹងវិញ្ញាណ។ មានពេលដែលគ្រីស្ទបរិស័ទគួរតែទទួលការកំសាន្តចិត្តទាំងពីរប្រភេទនេះ (អេសធើរ ៩:២២) ហើយមានពេលដែលយើងមិនអាចទទួលការកំសាន្តចិត្តខាងធម្មជាតិបានដែរ (ទំនុកដំកើង ១៣៧:២)។ ប៉ុន្តែ គ្មានពេលណាដែលសេចក្តីអំណរ និង ការកំសាន្តចិត្តខាងព្រលឹងវិញ្ញាណនៅក្នុងព្រះជាម្ចាស់ មិនគួរនឹងមានបទពិសោធនោះទេ (១ថែស្សាឡូនីច ៥:១៦ និង ភីលីព ៤:៤)។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត ដែលអាចកើតឡើងចំពោះគ្រីស្ទបរិស័ទក៏ដោយ យើងគួរតែសួរសំណួរមួយចំនួនដូចមានខាងក្រោមនេះ ៖

**ក.** តើហេតុអ្វីបានជាការលំបាកទាំងនោះ ធ្វើឲ្យយើងភ្លេចពីសេចក្តីកំសាន្តចិត្តក្នុងព្រះជាម្ចាស់ ខណៈដែលការលំបាកនោះគ្រាន់តែនៅតែមួយភ្លែត រីឯសុភមង្គលរបស់យើងក្នុងព្រះជាម្ចាស់ នោះមានអស់កល្បជានិច្ចវិញដូច្នេះ?

**ខ.** តើហេតុអ្វីបានជាយើងកើតទុក្ខព្រួយ ទោះជាទ្រង់នៅជាមួយយើង ទាំងក្នុងពេលដែលយើងមានទុក្ខលំបាកផងនោះ? ពាក្យសន្យាដែលថា *«អញនឹងនៅជាមួយនឹងវាក្នុងគ្រាទុក្ខលំបាក»* (ទំនុកដំកើង ៩១:១៥) គួរតែកំសាន្តចិត្តយើង នៅក្នុងគ្រប់ទាំងបន្ទុកដែលយើងជួប។

**គ.** ក្នុងនាមយើងជាគ្រីស្ទបរិស័ទ តើហេតុអ្វីបានជាយើងត្រូវព្រួយបារម្ភ បើយើងជឿប្រាកដថា គ្មានកិច្ចការរបស់ព្រះតម្រិះសម្រេចណាមួយដែលអាក្រក់កើតឡើង ជាសញ្ញានៃការសម្អប់របស់ព្រះជាម្ចាស់នោះឡើយ? ព្រះទ័យរបស់ព្រះជាម្ចាស់ពោរពេញដោយសេចក្តីស្រឡាញ់ចំពោះកូនៗរបស់ទ្រង់ ទោះបីជាព្រះតម្រិះសម្រេចមានពេញដោយការមិនយល់ព្រមក៏ដោយ។

**ឃ.** ហេតុអ្វីបានជាយើងត្រូវអស់សង្ឃឹម នៅពេលដែលយើងប្រាកដថា ព្រះជាម្ចាស់ទ្រង់នឹងធ្វើឲ្យមានការល្អកើតឡើងចំពោះយើង ទោះជាតាមវិធីរបស់ព្រះតម្រិះសម្រេចទាំងនេះក៏ដោយ? (រ៉ូម ៨:២៨)។

**ង.** ហេតុអ្វីបានជាយើងមិនគិតពីក្តីអំណររបស់យើងនៅក្នុងព្រះជាម្ចាស់ ខណៈដែលពេលវេលានោះជិតមកដល់ ឯការសោកសង្រេងនឹងផុតទៅ ហើយយើងក៏លែងមានការឈឺចាប់ទៀតនោះ? *«ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ»* (វិវរណៈ ៧:១៧)។

បន្ទាប់មក ប្រសិនបើអ្នករក្សាសេចក្តីអំណរ និង ការកំសាន្តចិត្តនៅក្នុងព្រះជាម្ចាស់ក្នុងគ្រប់កាលៈទេសៈទាំងអស់ នោះសូមប្រយ័ត្នកុំស្រឡាញ់របស់នៅលើផែនដីជ្រុលពេក។ សូមគិតពីការយាងមកជាលើកទី២របស់ព្រះអម្ចាស់ នោះរបស់នៅលើផែនដីនឹងហាក់ដូចជាមិនសំខាន់សម្រាប់អ្នកទៅវិញ។ សូមតាំងចិត្តរបស់អ្នកនៅលើអ្វីដែលនៅអស់កល្បជានិច្ច ហើយសូមកុំប្រថុយឲ្យបាត់បង់សេចក្តីអំណរបែបនោះ ដែល

អ្នកមានក្នុងការប្រកបជាមួយព្រះអង្គ ដើម្បីឲ្យបានតែសុភមង្គលនៅលើផែនដីនេះឡើយ ទោះជាយើងបានរបស់នៅលើផែនដីនេះច្រើនឬតិចក៏ដោយ សូមឲ្យយើងរៀនឲ្យមានសេចក្តីសន្តោសក្នុងគ្រប់សណ្ឋានវិញ (ភីលីព ៤:១១, ១២)។

ខ្ញុំបានសូមឲ្យអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ បានគិតពីបញ្ហាទាំងនេះដោយយកចិត្តទុកដាក់ដែរ។ ព្រះបន្ទូលសំដែងថា ស្ថាននរកជាទិសដៅអស់កល្បរបស់អ្នកដែលមិនជឿព្រះ។ ហេតុដែលអ្នកនៅតែមានជីវិតរស់នៅ នោះបានបង្ហាញពីសេចក្តីអត់ធ្មត់ និង សេចក្តីសប្បុរសយ៉ាងធំរបស់ព្រះជាម្ចាស់ចំពោះយើងរាល់គ្នា។ អ្នកមិនមានសិទ្ធិទទួលសេចក្តីសប្បុរសណាឡើយ ប៉ុន្តែព្រះតម្រិះសម្រេចបានបន្លាយជីវិតរបស់អ្នក។ តើការទទួលដំណឹងល្អដែលអ្នកអាចចៀសផុតពីស្ថាននរកនោះ មានប្រយោជន៍ចំពោះអ្នកដែរឬទេ? តើពួកអ្នកដែលបាត់បង់ជារៀងរហូត នឹងនិយាយដូចម្តេច ប្រសិនបើអាចនៅស្ថានដែលអ្នកនៅម្តងទៀតនោះ?

ការងាកទៅរករាស្ត្ររបស់ទ្រង់ម្តងទៀតនោះ ខ្ញុំសូមឲ្យអ្នកគិតពិចារណាពីសេចក្តីមេត្តាករុណា និង ព្រះពរខាងព្រលឹងវិញ្ញាណ ដែលអ្នកបានទទួលពីព្រះយេស៊ូវគ្រីស្ទ។ សេចក្តីសប្បុរសតែម៉្យាង នោះល្មមគ្រប់គ្រាន់ដើម្បីនឹងជួយអ្នកនៅក្នុងគ្រាទុក្ខលំបាកនៅលើផែនដីនេះបានហើយ *«ព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់»* (អេភេសូរ ១:៣)។ សូមគិតពីអ្វីដែលអំពើបាបរបស់អ្នកសមនឹងទទួលពីព្រះជាម្ចាស់ ហើយសូមគិតពីអ្វីដែលតម្រូវឲ្យអ្នកលាងសំអាតអំពើបាបរបស់អ្នកនោះ។ អំពើបាបរបស់អ្នកសមនឹងទទួលសេចក្តីវិនាសជារៀងរហូត ប៉ុន្តែអ្នកនៅតែបានទទួលសេចក្តីមេត្តាករុណាដ៏ច្រើន! ទុក្ខលំបាកដែលកើតឡើងចំពោះអ្នកតាមរយៈព្រះតម្រិះសម្រេចជាសេចក្តីត្រូវការដើម្បីបង្ក្រាបអំពើបាបដែលមាននៅក្នុងខ្លួនអ្នក។ ទោះបីព្រះជាម្ចាស់ប្រើការទុក្ខលំបាកនោះនៅក្នុងជីវិតរបស់អ្នកក៏ដោយ តើអ្នកឃើញថា អ្នកនៅតែមាន

ចិត្តអំនួតដដែលឬ? ប៉ុន្តែចូរពិចារណាថា តើអ្នកនៅជិតនឹងនគរស្ថានសួគ៌ប៉ុណ្ណា សូមឲ្យមានភាពអត់ធ្មត់បន្តិច ហើយសេចក្តីអត់ធ្មត់នោះនឹងមានភាពសុខសាន្តនៅក្នុងចិត្តអ្នក លុះត្រាតែចិត្តរបស់អ្នកប្រាថ្នាចង់បានដែរ *«ដ្បិតឥឡូវនេះ សេចក្តីសង្គ្រោះបានមកជិតបង្កើយ ជាជាងកាលយើងទើបនឹងជឿនោះ»* (រ៉ូម ១៣:១១)។

## ៥• បើព្រះតម្រិះសម្រេចពន្យារព្រះពរដែលអ្នកបានអធិស្ឋានសូម និង រង់ចាំ នោះសូមកុំឱ្យល្ហើយនឹងអធិស្ឋានទៅព្រះជាម្ចាស់ឡើយ

យើងតែងតែចង់បានអ្វីៗឆាប់ៗ ប៉ុន្តែព្រះតម្រិះសម្រេចព្រួយ ដោយព្រោះមិនទាន់មានលទ្ធផលនៅក្នុងចិត្តយើងនៅឡើយ យើងខុស បើយើងមិនអត់ធ្មត់។ កាលណាយើងរង់ចាំ និង អធិស្ឋានកាន់តែយូរ នោះចម្លើយនឹងកាន់តែប្រសើរឡើង នៅពេលដែលចម្លើយនោះលេចមក *«មើល នេះគឺជាព្រះនៃយើងរាល់គ្នា យើងបានរង់ចាំទ្រង់ ហើយទ្រង់នឹងជួយសង្គ្រោះយើង នេះគឺជាព្រះយេហូវ៉ាហើយ យើងបានរង់ចាំទ្រង់ យើងនឹងមានចិត្តរីករាយ ហើយត្រេកអរដោយសេចក្តីសង្គ្រោះរបស់ទ្រង់»* (អេសាយ ២៥:៩)។ ក្មេងដែលល្ងីល្ងើ វាយកផ្លែប៉ោមដែលមិនទាន់ទុំញុាំ ប៉ុន្តែពេលដែលផ្លែប៉ោមទុំ ហើយជ្រុះមក នោះមានរសជាតិឆ្ងាញ់ណាស់។

ព្រះពរតែងតែនៅជិតយើងបំផុត នៅពេលដែលសេចក្តីសង្ឃឹមរបស់រាស្ត្រព្រះជាម្ចាស់ ធ្លាក់ដល់កំរិតទាបបំផុត។ ការរំដោះរាស្ត្ររបស់ទ្រង់ចេញពីស្រុកអេស៊ីព្ទ និង ពីស្រុកបាប៊ីឡូន ក៏មានលក្ខណៈដូច្នេះដែរ (និក្ខមនំ ២:២៣ និង អេសេគាល ៣៧:១១) ហើយនៅក្នុងការព្រួយបារម្ភរបស់យើង ប្រហែលជាព្រះជាម្ចាស់បានពន្យារព្រះពរដោយព្រោះយើងមិនមានលក្ខណៈសមរម្យដើម្បីនឹងទទួលព្រះពរនោះ ទោះជាអ្វីកើតឡើងក៏ដោយ ក៏យើងមិនសមនឹងទទួលព្រះពរនោះដែរ។ ព្រះពរតែងតែជាផលផ្លែនៃព្រះគុណទាំងស្រុងរបស់ព្រះជាម្ចាស់។ ដូច្នេះហើយ យើងមានហេតុផលត្រឹមត្រូវដើម្បីរង់ចាំព្រះពរនោះដោយសេចក្តីអត់ធ្មត់ និង ដោយចិត្តអរព្រះគុណទ្រង់ផង។

## ៦• សូមកុំសួរ ឬកាត់ក្ដីពីវិធីនៃកិច្ចការរបស់ព្រះតម្រិះសម្រេចឡើយ

មានការជាច្រើនដែលពិបាកយល់ នៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ក៏ដូចជានៅក្នុងព្រះបន្ទូលព្រះដែរ។ យើងមិនគួរប្រើហេតុផលអំនួតរបស់លោកិយ នៅពេលដែលយើងពិចារណាកិច្ចការរបស់ព្រះជាម្ចាស់នោះទេ។ អេសាភបានព្យាយាមយ៉ាងខ្លាំងដើម្បីសម្លឹងមើលទៅវិធីអាថ៌កំបាំងរបស់ព្រះតម្រិះសម្រេច។ បន្ទាប់មក គាត់និយាយថា «*កាលណាទូលបង្គំបានពិចារណា ដើម្បីចង់ដឹងច្បាស់ពីសេចក្ដីនេះ នោះក៏ពិបាកដល់ទូលបង្គំណាស់*» (ទំនុកដំកើង ៧៣:១៦)។ លោកយ៉ូបក៏ទទួលអារម្មណ៍ថាខុសចំពោះការនេះដែរ (យ៉ូប ៤២:៣)។ ខ្ញុំដឹងថា គ្មានអ្វីនៅក្នុងព្រះបន្ទូល ឬនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ដែលប្រឆាំងនឹងហេតុផលត្រឹមត្រូវនោះទេ ប៉ុន្តែមានការមួយចំនួនដែលហួសពីហេតុផលរបស់មនុស្ស។ ជាឧទាហរណ៍ ហេតុផលរបស់មនុស្សមើលមិនឃើញអ្វីដែលល្អនៅក្នុងព្រឹត្តិការណ៍ដែលសោកសៅ ហើយការនោះអាចធ្វើឲ្យយើងមិនទុកចិត្តដល់ព្រះតម្រិះសម្រេចវិញ។ ដូច្នេះ សូមប្រយ័ត្នកុំឲ្យពឹងផ្អែកទៅលើហេតុផល និង ការយល់ដឹងរបស់អ្នកឡើយ។ ជាធម្មតា យើងមើលមនុស្ស ហើយវាយតម្លៃតាមខ្នាតគំរូរបស់មនុស្ស ប៉ុន្តែនោះជាការគ្រោះថ្នាក់បំផុត។

# ជំពូក ៥

## ភាពរីករាយ និង ប្រយោជន៍ដែលបានមកពីការសម្លឹងមើលអ្វីដែលព្រះជាម្ចាស់ធ្វើនៅក្នុងព្រះតម្រិះសម្រេច

ឥឡូវនេះ ខ្ញុំត្រូវតែបង្ហាញដល់អ្នកអំពីភាពសប្បាយរីករាយដ៏ធំក្រៃលែង ក្នុងការដើរជាមួយព្រះជាម្ចាស់ និង ការសម្លឹងមើលយ៉ាងហ្មត់ចត់ចំពោះព្រះតម្រិះសម្រេចរបស់ទ្រង់ជាប្រចាំថ្ងៃ។

### ១. តាមវិធីបែបនេះ អ្នកអាចមានការប្រកបគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងព្រះ ពីមួយថ្ងៃទៅមួយថ្ងៃ

កណ្ឌទំនុកដំកើង ជំពូក១០៤ ជាការសញ្ជឹងគិតពីកិច្ចការរបស់ព្រះតម្រិះសម្រេច។ អ្នកនិពន្ធកណ្ឌទំនុកដំកើងបាននិយាយថា *«សូមឲ្យសេចក្តីនឹកជញ្ជឹងរបស់ទូលបង្គំបានផ្អែមត្រចៀកដល់ទ្រង់»* (ខ.៣៤)។ ការប្រកបគ្នាកើតចេញពីការពីរយ៉ាងគឺ ព្រះជាម្ចាស់បានធ្វើឲ្យព្រលឹងយើងស្គាល់ទ្រង់ ហើយព្រលឹងយើងក៏ឆ្លើយតបទៅកាន់ព្រះជាម្ចាស់វិញ។ យើងអាចមើលឃើញលទ្ធផលរបស់យើងដែលចេញពីការប្រកបគ្នានេះ មានតាមវិធី៤យ៉ាង ៖

**ក.** ដូចជា យ៉ាកុប និង ពួកបរិសុទ្ធមួយចំនួនទៀតដែរ ដែលតាំងពីបុរាណមកយើងមានអារម្មណ៍ថា យើងមិនសមនឹងទទួលសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ និង សេចក្តីពិតដែលទ្រង់បង្ហាញដល់យើងទេ សូម្បីតែបន្តិចក៏មិន

សមផង។ ព្រះអង្គនាំយើងមកដើម្បីឲ្យនិយាយថា «*ទូលបង្គំមិនគួរឲ្យបានអស់ទាំងសេចក្តីសប្បុរស នឹងអស់ទាំងសេចក្តីស្មោះត្រង់ដែលទ្រង់បានផ្តល់មកទូលបង្គំជាអ្នកបំរើទ្រង់ទេ*» (លោកុប្បត្តិ ៣២:១០)។

**ខ.** សេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ អាចនឹងមានកាន់តែច្រើនឡើងតាមរយៈការចងចាំពីសេចក្តីសប្បុរសរបស់ទ្រង់។ គ្រប់មនុស្សទាំងអស់ស្រឡាញ់សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ ប៉ុន្តែពួកបរិសុទ្ធស្រឡាញ់ព្រះជាម្ចាស់ដែលជាម្ចាស់នៃសេចក្តីសប្បុរសនោះវិញ។

**គ.** ការប្រកបជាមួយព្រះជាម្ចាស់ ដែលកើតឡើងដោយសារការសញ្ជឹងគិតទៅលើព្រះតម្រិះសម្រេចរបស់ទ្រង់ នោះបានធ្វើឲ្យយើងការពារខ្លួនពីអំពើបាបដែលប្រឆាំងនឹងព្រះជាម្ចាស់។

**ឃ.** ការប្រកបជាមួយព្រះ ធ្វើឲ្យងាយស្រួលក្នុងការស្តាប់បង្គាប់ និង បំរើព្រះអម្ចាស់។ ស្តេចដាវីឌ និង ស្តេចយ៉ូសាផាត យល់ថា ពិតជាយ៉ាងដូច្នេះមែន (ទំនុកដំកើង ១១៦:១២; ២របាក្សត្រ ១៧:៥, ៦)។

ដូច្នេះអ្នកមើលឃើញថា ព្រលឹងអាចមានការប្រកបដ៏អស្ចារ្យជាមួយនឹងព្រះជាម្ចាស់ ដោយសិក្សាពីព្រះតម្រិះសម្រេចរបស់ទ្រង់។ អូហ៍ ខ្ញុំសង្ឃឹមថា អ្នកនឹងដើរជាមួយទ្រង់យ៉ាងដូច្នោះដែរ! នៅពេលមានលទ្ធផលដូច្នេះកើតនៅក្នុងចិត្តរបស់អ្នក នោះព្រះអម្ចាស់នឹងមានបន្ទូលថា «ជំនួយដែលអ្នកបានទទួល ក៏បានប្រទានមកអ្នករាល់គ្នាយ៉ាងល្អ!» ព្រះអង្គសព្វព្រះហឫទ័យនឹងធ្វើការល្អសំរាប់អ្នកជារៀងរហូត។

**២. បំណែកនៃក្តីអំណរដ៏អស្ចារ្យក្នុងជីវិតគ្រីស្ទបរិស័ទ ចេញមកពីការសម្លឹងមើលទៅអ្វីដែលព្រះជាម្ចាស់ធ្វើនៅក្នុងព្រះតម្រិះសម្រេច** «*អស់ទាំងស្នាដៃនៃព្រះយេហូវ៉ាសុទ្ធតែធំវិសេស គួរឲ្យអស់អ្នកណាដែលចូលចិត្តនឹងការទាំងនោះបានស្វែងរកតាម*» (ទំនុកដំកើង ១១១:២)។

**ក.** យើងនឹងមើលឃើញរបៀប ដែលផ្នែកនៃបុគ្គលិកលក្ខណៈផ្សេងៗរបស់ព្រះជាម្ចាស់ ធ្វើជាមួយគ្នានៅក្នុងព្រះតម្រិះសម្រេច។ ជួនកាលផ្នែកនោះអាចមានការប្រឆាំងគ្នា ប៉ុន្តែទីបំផុតក៏ចូលរួមជាមួយគ្នាវិញ ដូចជាបទគម្ពីរបានសំដែងថា «*សេចក្តីសប្បុរស នឹងសេចក្តីពិតត្រង់ បានជួបគ្នា សេចក្តីសុចរិត នឹងសេចក្តីមេត្រី បានថើបគ្នា*» (ទំនុកដំកើង ៨៥:១០)។ ព្រះបន្ទូលទាំងនេះសំដៅទៅលើពួកអ៊ីស្រាអែល ដែលវិលត្រឡប់មកពីទាសភាពនៅស្រុកបាប៊ីឡូនវិញ។ ឥឡូវនេះ ពួកអ៊ីស្រាអែល ដែលកំពុងតែចាកចេញពីទាសភាពបានឃើញសេចក្តីពិត និង សេចក្តីសុចរិតរបស់ព្រះជាម្ចាស់ នៅក្នុងសេចក្តីសន្យាដែលទ្រង់បានសន្យាតាំងពី៧០ឆ្នាំមុន។ ពាក្យសន្យាដែលកើតឡើងជាច្រើនឆ្នាំមុន និង ការបំពេញនៅ៧០ឆ្នាំក្រោយមក បានយកមកពណ៌នាដូចជាសម្លាញ់ពីរនាក់ដែលញញឹម និង ថើបគ្នា នៅពេលគេជួបគ្នាបន្ទាប់ពីបានបែកគ្នាអស់រយៈពេលយ៉ាងយូរ។ នៅវេលាដែលគ្រីស្ទបរិស័ទបានឃើញការសន្យារបស់ព្រះអង្គ និង លទ្ធផលនៃសេចក្តីសន្យានោះបានកើតឡើង នោះគេនឹងទទួលយកដោយសប្បាយរីករាយ។

**ខ.** នៅពេលអ្នកសម្លឹងមើលទៅកិច្ចការរបស់ព្រះតម្រិះសម្រេច ជាញយដង អ្នកអាចមើលឃើញការអធិស្ឋាន និង សេចក្តីសង្ឃឹមរបស់អ្នកលេចឡើងម្តងទៀត ដូចជាងើបឡើងពីស្លាប់អ៊ីចឹង។ ព្រះជាម្ចាស់ទ្រង់បានពន្យារចម្លើយសំរាប់ការអធិស្ឋានរបស់យើង ហើយយើងអាចនិយាយថា «*សេចក្តីសង្ឃឹមរបស់ខ្ញុំ ក៏ផុតចាកពីព្រះយេហូវ៉ាហើយ*» (បរិទេវ ៣:១៨)។ ប៉ុន្តែ បន្ទាប់មកតើយើងពេញដោយការកំសាន្តចិត្តយ៉ាងណាទៅ ដែលព្រះអង្គបានឆ្លើយតបនឹងការអធិស្ឋានរបស់យើង នៅពេលដែលយើងមានសេចក្តីសង្ឃឹមយ៉ាងតិចតួចថានឹងទទួលចម្លើយពីការអធិស្ឋាននោះ។ ជីវិតរបស់លោកយ៉ូប យ៉ាកុប

និង ស្តេចដាវីឌ ជួនកាលបានបង្ហាញថា គេអស់សង្ឃឹមពីជីវិតរបស់គេ ប៉ុន្តែ បន្ទាប់ពីព្រះតម្រិះសម្រេចធ្វើការដោយចម្លែក និង ដោយស្មានមិនដល់មក ពួកគេក៏មានជីវិតរស់ ហើយថែមទាំងមើលឃើញសេចក្តីសង្ឃឹម និង សេចក្តី កំសាន្តចិត្តឡើងវិញ ទាំងទទួល «ជីវិតពីសេចក្តីស្លាប់» មកវិញ។

**គ.** ជាព្រះពរអស្ចារ្យដែលព្រះជាម្ចាស់បានប្រទានមកយើង ចេញពីការទាំងអស់ ដែលយើងគិតថា អាចនឹងនាំសេចក្តីវិនាស ឬភាពសោកសង្រេងមក។ លោក យ៉ូសែបក៏មិនដឹងដែរថា ការដែលពួកបងៗរបស់គាត់ បានលក់គាត់ទៅស្រុក អេស៊ីព្ទ នោះជាប្រយោជន៍សំរាប់គាត់ទៅវិញនោះទេ ប៉ុន្តែគាត់រស់នៅដើម្បី មើលឃើញថា កិច្ចការនោះមានគោលបំណងល្អ (លោកុប្បត្តិ ៥៥:៥)។ តើប៉ុន្មានដង ដែលយើងនិយាយដូចជាស្តេចដាវីឌថា *«នោះគឺជាប្រយោជន៍ ដល់ទូលបង្គំហើយ ដើម្បីឲ្យទូលបង្គំបានរៀនយកបញ្ញត្តរបស់ទ្រង់»* (ទំនុក ដំកើង ១១៩:៧១)។ ដំបូង យើងជួបនឹងបញ្ហាដោយដកដង្ហើមធំ ហើយបង្ហូរ ទឹកភ្នែក ប៉ុន្តែក្រោយមកយើងមើលទៅបញ្ហានោះដោយសេចក្តីអំណរ និង អរព្រះគុណដល់ព្រះជាម្ចាស់ សំរាប់បញ្ហាទាំងនោះវិញ!

**ឃ.** អ្នកណាដែលមើលឃើញសេចក្តីអាក្រក់នៅក្នុងខ្លួនឯង ប៉ុន្តែនៅពេលព្រម គ្នានោះ បានមើលឃើញថា ព្រះជាម្ចាស់មានព្រះតម្រិះដ៏ខ្ពស់ចំពោះខ្លួនដែរ នោះជាសេចក្តីកំសាន្តចិត្តដ៏មហិមា សំរាប់អ្នកនោះហើយ។ ដោយសារតែ ព្រះតម្រិះសម្រេចមើលថែរក្សាដល់គាត់ មនុស្សនោះអាចមើលឃើញភាព ល្អ និង សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ចំពោះគាត់ គ្រប់ថ្ងៃនៃជីវិត (ទំនុក ដំកើង ២៣:៦)។ មនុស្សដទៃទៀត គេស្វែងរកសេចក្តីល្អ ប៉ុន្តែសេចក្តីនេះក៏ បានរត់ចេញពីពួកគេទៅវិញ តែភាពល្អ និង សេចក្តីសប្បុរស នោះនឹងមក សំរាប់រាស្ត្រព្រះអង្គ ហើយពួកគេមិនអាចចៀសវាងមិនឲ្យការនេះមកតាម

គេបានទេ ទោះបីជាពេលខ្លះពួកគេធ្វើបាប ហើយដើរចេញពីផ្លូវត្រូវក៏ដោយ។ ពិតប្រាកដណាស់ រាស្ត្ររបស់ព្រះគឺជារតនសម្បត្តិរបស់ទ្រង់ ហើយ *«ទ្រង់មិនដកព្រះនេត្រ ចេញពីមនុស្សសុចរិតឡើយ»* (យ៉ូប ៣៦:៧)។

**ង.** នៅក្នុងលោកនេះ មានចំណេះដឹងពីគ្រប់យ៉ាងទាំងអស់ ដូច្នេះតើអ្វីអាចផ្តល់សេចក្តីអំណរ និង ការកំសាន្តចិត្ត ដែលអាចជួយយើងតាមផ្លូវទៅកាន់នគរស្ថានសួគ៌? ទោះបើមានជំនោរ និង លំនាចដ៏ច្រើននៃព្រះតម្រិះសម្រេចដែលហាក់ដូចជាប្រឆាំងនឹងយើងនៅពេលខ្លះៗក៏ដោយ ក៏យើងដឹងពិតប្រាកដថា ការទាំងអស់នោះនឹងនាំយើងឲ្យចូលទៅកាន់តែជិតព្រះជាម្ចាស់ និង ថ្ងៃយើងឲ្យសមនឹងទទួលសិរីរុងរឿងរបស់ទ្រង់វិញ។

## ៣• ការសិក្សាពីអ្វីដែលព្រះជាម្ចាស់ធ្វើនៅក្នុងព្រះតម្រិះសម្រេច នឹងកែប្រែភាពគ្មានជំនឿនៅក្នុងចិត្តអ្នក

មាននិស្ស័យចាស់ដែលមិនគោរពប្រតិបត្តិដល់ព្រះជាម្ចាស់ នៅក្នុងចិត្តដែលជឿពិតប្រាកដ ហើយនិស្ស័យនោះធ្វើឲ្យគំនិតគិតអ្វីដែលខុស ទៅជាត្រូវវិញ។ នៅពេលយើងគិតមិនត្រឹមត្រូវអំពីកិច្ចការរបស់ព្រះតម្រិះសម្រេច ហើយយើងប្រហែលជាមានចិត្តចង់និយាយដូចជាអេសាភថា *«នេះហើយដែលហៅថាមនុស្សអាក្រក់ ហើយដោយព្រោះគេចេះតែនៅដោយសុខស្រួល បានជាទ្រព្យសម្បត្តិគេចំរើនឡើង»* (ទំនុកដំកើង ៧៣:១២)។ ប៉ុន្តែបើសិន យើងសង្កេតមើលដោយប្រុងប្រយ័ត្ន ចំពោះវិធីដែលព្រះជាម្ចាស់ដាក់ទោសដល់មនុស្សអាក្រក់ គឺមួយចំនួនក្នុងចំណោមពួកគេនៅលើផែនដីនាពេលបច្ចុប្បន្ននេះ និង ទាំងអស់នៅក្នុងផែនដីដែលនឹងមកនៅថ្ងៃអនាគត ការនោះនឹងបញ្ជាក់ជំនឿរបស់យើង។ ព្រះតម្រិះសម្រេចទាំងនោះ បានបង្ហាញយ៉ាងច្បាស់លាស់ពីប្រាជ្ញា អំណាច សេចក្តីស្រឡាញ់ និង សេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់

ក្នុងការថែរក្សា និង រំដោះរាស្ត្រ ទ្រង់ពីគ្រប់គ្រោះថ្នាក់ សេចក្តីភ័យខ្លាច និង ការលំបាកទាំងឡាយ! ព្រះអម្ចាស់បានបង្ហាញអង្គទ្រង់ផ្ទាល់ទៅកាន់រាស្ត្ររបស់ទ្រង់ នៅក្នុងការទាំងនេះ (ទំនុកដំកើង ៩៩:១)។ សូមគិតពីបទពិសោធន៍របស់អ្នកផ្ទាល់ ហើយសួរទៅខ្លួនអ្នកថា នៅពេលមានទុក្ខលំបាក អ្នកណាបានផ្តល់ឲ្យសម្រាប់គ្រប់តំរូវការរបស់អ្នកគឺព្រះជាម្ចាស់ តើមែនដែរឬទេ? *«ទ្រង់បានប្រទានអាហារដល់អស់អ្នកដែលកោតខ្លាច ទ្រង់ក៏ នឹងនឹកចាំពីសេចក្តីសញ្ញាទ្រង់ជានិច្ចដែរ»* (ទំនុកដំកើង ១១១:៥)។ តើអ្នកបានរស់ផុត ពីភាពគ្រោះថ្នាក់ ជំងឺ និង ឧបទ្ទវហេតុជាច្រើនដោយរបៀបណាទៅ? មិនបាច់ឆ្ងល់អីទេ គឺដោយសារព្រះជាម្ចាស់គង់នៅក្នុងកាលៈទេសៈទាំងអស់នេះ ហើយដោយសារតែការថែរក្សារបស់ទ្រង់ នោះអ្នកបានរួចផុតពីគ្រោះថ្នាក់។ អ្នកក៏អាចឃើញព្រះហស្តរបស់ព្រះជាម្ចាស់ នៅក្នុងចម្លើយចំពោះការអធិស្ឋានរបស់អ្នក ដូចជាបទគម្ពីរសំដែងថា*«ខ្ញុំបានស្វែងរកព្រះយេហូវ៉ា ហើយទ្រង់ក៏ឆ្លើយតបមកខ្ញុំ ក៏ប្រោសឲ្យខ្ញុំរួចពីអស់ទាំងសេចក្តីភិតភ័យរបស់ខ្ញុំ។ ខ្ញុំជាមនុស្សវេទនានេះ បានអំពាវនាវទៅ នោះព្រះយេហូវ៉ាទ្រង់បានស្តាប់តាម ហើយជួយសង្គ្រោះឲ្យរួចពីសេចក្តីលំបាកទាំងប៉ុន្មានរបស់ខ្លួន»* (ទំនុកដំកើង ៣៤:៤, ៦)។ តើអ្នកមិនធ្លាប់រកឃើញព្រះហស្តរបស់ទ្រង់ ដែលដឹកនាំ និង តម្រង់ផ្លូវរបស់អ្នក ដើម្បីឲ្យបានព្រះពរដែលអ្នកមិនដែលគិតថាអ្នកនឹងបានទេឬ? រាស្ត្ររបស់ព្រះជាម្ចាស់គួរជាទីស្រឡាញ់ដល់ទ្រង់ ព្រះអង្គធ្វើគ្រប់ការទាំងអស់សំរាប់ពួកគេ (ទំនុកដំកើង ៥៧:២)។

## ៤• ការកត់ត្រាពីអ្វីដែលព្រះតម្រិះសម្រេចបានធ្វើ នឹងក្លាយទៅជាការលើកទឹកចិត្តដល់ជំនឿ ក្នុងពេលដ៏លំបាកនៅថ្ងៃអនាគត

ធ្វើដំណើរក្នុងផ្លូវដែលបានស្គាល់ច្រើន នោះមានលក្ខណៈងាយស្រួលសម្រាប់ជំនឿ ជាជាងទៅតាមផ្លូវថ្មីដែលយើងមើលមិនឃើញជំហាននៅខាងមុខទៀត។ នៅ

ពេលយើងជឿជាក់លើព្រះគ្រីស្ទជាលើកដំបូង នោះការប្រព្រឹត្តតាមជំនឿមានការពិបាកបំផុត។ ការប្រព្រឹត្តតាមជំនឿទាំងអស់ក្រោយមកទៀត មានលក្ខណៈងាយស្រួលជាងមុន ដោយសារតែយើងមានបទពិសោធន៍ពីមុនមក។ ពេលយើងឈានចូលទៅកាន់ការលំបាកថ្មី នោះជាជំនួយដ៏ប្រសើរសំរាប់យើងដែលអាចនិយាយបានថា *«នេះមិនមែនជាលើកទី១ ដែលខ្ញុំធ្លាក់ទៅក្នុងជំរៅនេះទេ ហើយខ្ញុំធ្លាប់រួចផុតពីនោះ តាំងពីមុនមកដែរ»*។ នៅពេលពួកសាវកគ្មាននំបុ័ង ព្រះគ្រីស្ទក៏រំលឹកពួកគេពីការអស្ចារ្យដែលព្រះអង្គបានធ្វើកាលពីមុន (ម៉ាថាយ ១៦:៨-១១)។ ព្រះអង្គហៅពួកគេថា ជា *«មនុស្សមានជំនឿតិច»* ពីព្រោះថា ពួកគេគួរតែជឿដល់ទ្រង់ ក្រោយពីបានឃើញអ្វីដែលទ្រង់ធ្វើតាំងពីមុនមក។ មានវិធីពីរយ៉ាង ដែលយើងអាចបង្ហាញពីភាពគ្មានជំនឿរបស់យើង គឺយើងសង្ស័យពីអំណាចរបស់ព្រះអង្គ និង សង្ស័យពីព្រះហឫទ័យរបស់ទ្រង់ក្នុងការជួយយើង។កូនចៅអ៊ីស្រាអែលគិតថា មានការមួយចំនួនដែលព្រះជាម្ចាស់ធ្វើមិនបានសោះគឺ *«តើព្រះទ្រង់អាចនឹងចាត់ចែងឲ្យមានអាហារបរិភោគ នៅទីរហោស្ថាននេះបានឬ?តើទ្រង់អាចនឹងប្រទានឲ្យមាននំបុ័ងដែរឬ?តើទ្រង់នឹងផ្គត់ផ្គង់ឲ្យរាស្ត្រទ្រង់មានសាច់បរិភោគឬអី?»* (ទំនុកដំកើង ៧៨:១៩, ២០)។ ដោយព្រោះតែយើងមើលមិនឃើញ ពីវិធីដែលសេចក្តីស្រោកស្រាន្តអាចនឹងកើតមានបាននោះហើយ បានជាយើងគិតថា គ្មានអ្វីជាទីសង្ឃឹមសោះ។ ប្រសិនបើយើងគិតពីបទពិសោធន៍ពីមុននេះរបស់យើង នោះយើងអាចយកឈ្នះលើហេតុផលដែលមិនជឿទាំងអស់នេះបាន។ ព្រះជាម្ចាស់ធ្លាប់ជួយយើង ដូច្នេះព្រះអង្គក៏អាចជួយយើងបានដែរ ទ្រង់មានអំណាច និង សមត្ថភាពគ្រប់យ៉ាងដែលទ្រង់ធ្លាប់មានតាំងពីមុនមក រហូតដល់សម័យនេះ។

ពួកអ្នកមិនជឿក៏ពិចារណាផងដែរថា ព្រះជាម្ចាស់បានប្រទានព្រះគុណរបស់ទ្រង់តាំងពីមុនមកម្ល៉េះ ដូច្នេះទ្រង់គួរតែប្រទានព្រះគុណរបស់ទ្រង់នៅពេលសព្វថ្ងៃនេះដែរ។

ស្តេចដាវីឌ និង លោកប៉ុល បានលើកហេតុផលពីអ្វីដែលព្រះជាម្ចាស់បានធ្វើហើយ ទៅនឹងអ្វីដែលទ្រង់នឹងធ្វើនៅសព្វថ្ងៃនេះ (១សាំយូអែល ១៧:៣៦; ២កូរិនថូស ១:១០) តើយើងអាចមានសំណួរអ្វីទៀត ក្រោយពីយើងបានឃើញភស្តុតាងជាបន្តបន្ទាប់ពីភាពល្អរបស់ព្រះជាម្ចាស់ កាលពីអតីតកាលមកនោះ?

ពួកអ្នកមិនជឿប្រហែលជាសួរថា តើអ្នកដែលមានបាប ហើយធ្វើតែអំពើអាក្រក់ដូចជាខ្ញុំនេះ សង្ឃឹមថាព្រះជាម្ចាស់គួរធ្វើនេះ ឬធ្វើនោះសំរាប់ខ្ញុំឬទេ? អ្នកប្រហែលជាឆ្លើយថា សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ បានកើតឡើងចំពោះខ្ញុំ មុនពេលដែលខ្ញុំនៅក្នុងលក្ខណៈអាក្រក់ជាងឥឡូវនេះផង ដូច្នេះហើយ ខ្ញុំនៅតែសង្ឃឹមថា ភាពល្អរបស់ព្រះអង្គនឹងបន្តកើតមានចំពោះខ្ញុំ ទោះបីជាខ្ញុំមិនសមនឹងទទួលក៏ដោយ «*ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ*» (រ៉ូម ៥:១០)។

## ៥• ការចងចាំនូវព្រះតម្រិះសម្រេចពីអតីតកាល នោះនឹងក្លាយទៅជាប្រភពនៃការសរសើរដំកើង និង ការអរព្រះគុណជាបន្តបន្ទាប់ ដែលជាកិច្ចការរបស់ពួកទេវតាមកពីស្ថានសួគ៌ ហើយក៏ជាផ្នែកមួយនៃការសប្បាយជាទីបំផុត នៅក្នុងជីវិតរបស់យើងនៅលើផែនដីនេះដែរ

មានការរៀបរាប់អំពីរាស្ត្រទ្រង់ពីមុនមកថា «*តែមិនយូរប៉ុន្មាន ក៏ភ្លេចកិច្ចការរបស់ទ្រង់ទៅ*» (ទំនុកដំកើង ១០៦:១៣)។ ទោះបីជាព្រះតម្រិះសម្រេចចំអែតដល់ពួកគេនៅឯវាលរហោស្ថានតាមលក្ខណៈដែលគួរឲ្យចាប់អារម្មណ៍ក៏ដោយ តែពួកគេមិនបានសរសើរដល់ព្រះជាម្ចាស់ ដែលបានយកព្រះទ័យទុកដាក់ចំពោះពួកគេនោះទេ

(ជនគណនា ១១:៦)។ ឯស្ដេចដាវីឌវិញ បានប្រើកម្លាំងទាំងអស់របស់ទ្រង់ ដើម្បីអរព្រះគុណ និង ថ្វាយពរដល់ព្រះជាម្ចាស់ សំរាប់សេចក្ដីសប្បុរសរបស់ព្រះចំពោះទ្រង់ *«ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ហើយគ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ ចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ»* (ទំនុកដំកើង ១០៣:១)។ មនុស្សដែលមានចិត្តដឹងគុណបានសរសើរដំកើងដោយសារភាពល្អ និង ចិត្តសប្បុរសរបស់ព្រះជាម្ចាស់ដែលប្រទានពរនោះ ច្រើនជាងព្រះពរដែលព្រះតម្រិះសម្រេចបានប្រទានឲ្យទៅទៀត។ ដូចជាស្ដេចដាវីឌបានមានបន្ទូលថា *«ដ្បិតសេចក្ដីសប្បុរសនៃទ្រង់ នោះវិសេសជាងជីវិត បបូរមាត់ទូលបង្គំនឹងសរសើរដល់ទ្រង់»* (ទំនុកដំកើង ៦៣:៣)។ ការប្រទានឲ្យមានជីវិត និង ការរក្សាជីវិត ជាសកម្មភាពដ៏មានតម្លៃរបស់ព្រះតម្រិះសម្រេច ប៉ុន្តែព្រះគុណដែលនាំឲ្យព្រះជាម្ចាស់ធ្វើកិច្ចការទាំងអស់នេះ មានលក្ខណៈប្រសើរជាងសកម្មភាពរបស់កិច្ចការព្រះតម្រិះសម្រេចទៅទៀត។ យើងទទួលសេចក្ដីសប្បុរសជារៀងរាល់ថ្ងៃ ហើយសេចក្ដីសប្បុរសទាំងនេះជាហេតុផលដ៏ឧត្តុង្គឧត្តមដើម្បីឲ្យមានការអរព្រះគុណដល់ទ្រង់ *«សូមឲ្យព្រះអម្ចាស់បានប្រកបដោយព្រះពរ ដែលទ្រង់ទទួលយកបន្ទុកយើងខ្ញុំរាល់ៗថ្ងៃ»* (ទំនុកដំកើង ៦៨:១៩)។ យើងឃើញភាពសុភាពទន់ភ្លន់នៃសេចក្ដីសប្បុរសរបស់ព្រះ នៅក្នុងព្រះតម្រិះសម្រេចរបស់ទ្រង់ដែលថា *«ព្រះយេហូវ៉ា ទ្រង់មានព្រះហឫទ័យអាណិតដល់អស់អ្នកដែលកោតខ្លាចទ្រង់ ដូចជាឪពុកមានចិត្តអាសូរដល់កូនរបស់ខ្លួនដែរ»* (ទំនុកដំកើង ១០៣:១៣)។ អារម្មណ៍ដ៏សង្វេគ របស់ទ្រង់នៅពេលកំសាន្តចិត្តដល់រាស្ត្រទ្រង់ មានលក្ខណៈដូចជាម្ដាយដែលធ្វើចំពោះកូនតូចរបស់ខ្លួនយ៉ាងដូច្នោះដែរ (អេសាយ ៤៩:១៥)។ ដូច្នេះការក្រាបនៅទាបព្រះបាទ ទ្រង់ដោយភាពអស្ចារ្យដ៏បរិសុទ្ធ ចំពោះវិធីដ៏សមសួនដែលទ្រង់បន្ទាបចុះមកគង់នៅជាមួយនឹងយើង ដើម្បីធ្វើការសំរាប់យើង នោះជាការគួរសប្បាយរីករាយបំផុតហើយ។

## ៦. ការសង្កេតមើលព្រះតម្រិះសម្រេចដោយប្រុងប្រយ័ត្ន នោះអ្នកនឹងឃើញថា ព្រះយេស៊ូវគ្រីស្ទមានតម្លៃកាន់តែខ្លាំង ចំពោះព្រលឹងវិញ្ញាណរបស់អ្នក

តាមរយៈព្រះគ្រីស្ទ សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់បានហូរមកដល់យើង ហើយការសរសើរដំកើងរបស់យើងនឹងត្រឡប់ទៅដល់ទ្រង់វិញ។ គ្រប់យ៉ាងទាំងអស់ជារបស់យើង ហើយយើងជារបស់ព្រះវិញ (១កូរិនថូស ៣:២១-២៣)។

**ក.** រាល់ព្រះពរដែលយើងមាននៅក្នុងជីវិតរបស់យើងនេះ ក៏ដូចជាសេចក្តីសប្បុរសខាងព្រលឹងវិញ្ញាណ និង អស់កល្បជានិច្ចដែរ គឺព្រះគ្រីស្ទបានទិញសម្រាប់យើងដោយសារព្រះលោហិតរបស់ទ្រង់ ហើយដោយសារការសុគតរបស់ទ្រង់ នោះព្រះគ្រីស្ទបានផ្ទេរផ្សាគ្រប់យ៉ាងដែលអំពើបាបបានប្លន់យកពីយើងទៅ។ *«ដោយសារព្រះគ្រីស្ទ»* ព្រះជាម្ចាស់បានប្រទានដល់យើងគ្រប់យ៉ាងទាំងអស់ ទាំងសេចក្តីសង្គ្រោះ និង គ្រប់យ៉ាងដែលចាំបាច់ក្នុងការនាំយើងទៅកាន់សេចក្តីសង្គ្រោះនោះ (រ៉ូម ៨:២៣)។ មិនថា សេចក្តីល្អដែលយើងទទួលពីព្រះហស្តរបស់ព្រះតម្រិះសម្រេចមកនោះទេ យើងត្រូវនិយាយថា សេចក្តីនោះបានមកពីការសុគតរបស់ព្រះគ្រីស្ទ។

**ខ.** ដោយសារយើងបានរួបរួមជាមួយនឹងព្រះគ្រីស្ទ នោះគ្រប់យ៉ាងដែលយើងទទួលពីព្រះតម្រិះសម្រេច បានក្លាយទៅជាព្រះពរសម្រាប់យើង។ នៅពេលយើងនៅក្នុងព្រះគ្រីស្ទ នោះយើងមានលើសពីអ្វីដែលយើងបានបាត់បង់ដោយសារការធ្លាក់ចុះរបស់អ័ដាមទៅទៀត។

**គ.** មានទេវតាបំរើនៅក្នុងនគរព្រះ ប៉ុន្តែព្រះគ្រីស្ទជាអ្នកប្រាប់អ្វីដែលពួកគេត្រូវធ្វើ។ អស់អ្នកណាដែលធ្វើការល្អមកកាន់អ្នក នោះគឺជាព្រះម្ចាស់យេស៊ូវទេដែលបង្គាប់ឲ្យកិច្ចការនោះបានសម្រេចឡើង។ ការថែរក្សារបស់ព្រះគ្រីស្ទចំពោះគ្រីស្ទបរិស័ទនៅក្នុងទីក្រុងដាម៉ាស នោះជាការបញ្ឈប់សុលពីការបំផ្លាញពួកបណ្តាជន (កិច្ចការ ជំពូក៩)។

**ឃ.** តាមរយៈការសុគតជំនួសអំពើបាបរបស់យើង នោះព្រះគ្រីស្ទបានបើកទ្វារនៃសេចក្តីសប្បុរស ហើយទ្រង់ក៏នៅតែបើកទ្វារនោះ ដោយទ្រង់គង់នៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ សម្រាប់យើងជារៀងរហូត (វិវរណៈ ៥:៦; ហេព្រើរ ៩:២៤)។ បើការនេះមិនពិតប្រាកដទេ នោះរាល់អំពើបាបដែលយើងធ្វើ នឹងបញ្ចប់សេចក្តីសប្បុរសដែលយើងនឹងទទួល។ ប៉ុន្តែ *«បើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយមួយអង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទជាព្រះដ៏សុចរិត»* (១យ៉ូហាន ២:១-២)។

**ង.** អ្នកបានទទួលចម្លើយចំពោះសេចក្តីអធិស្ឋានរបស់អ្នក ដោយសារព្រះយេស៊ូវគ្រីស្ទ។ ព្រះនាមរបស់ទ្រង់បានធ្វើឲ្យព្រះវរបិតា មិនអាចបដិសេធបាននូវអ្វីដែលអ្នកទូលសូមតាមព្រះហឫទ័យទ្រង់នោះទេ (យ៉ូហាន ១៥:១៦)។ សូមគិតថា តើអ្នកជំពាក់ព្រះអម្ចាស់យេស៊ូវគ្រីស្ទប៉ុន្មាន សម្រាប់អភ័យឯកសិទ្ធិដ៏អស្ចារ្យ និង ប្រកបដោយសិរីរុងរឿងនេះ!

**ច.** ការសន្យានៃព្រះគុណធានាព្រះពរដែលអ្នកទទួល សូម្បីតែអាហារបរិភោគប្រចាំថ្ងៃ (ទំនុកដំកើង ១១១:៥) ក៏ដូចជាសេចក្តីសប្បុរសខាងព្រលឹងវិញ្ញាណទាំងអស់នោះផងដែរ។ ការសន្យានេះ គឺជាសញ្ញាថ្មី (ការព្រមព្រៀង) ដែលព្រះអង្គសងតាមរយៈព្រះលោហិតរបស់ទ្រង់ (១កូរិនថូស ១១:២៥)។ ដូច្នេះអ្នកត្រូវតែអរគុណព្រះអម្ចាស់យេស៊ូវគ្រីស្ទ សម្រាប់ការល្អដែលអ្នកបានទទួលពីការសន្យានោះ។

## ៧. ការពិចារណាពីព្រះតម្រិះសម្រេចដោយប្រុងប្រយ័ត្ន មានអំណាចដ៏អស្ចារ្យ ដើម្បីធ្វើឱ្យចិត្តពេញដោយការអរព្រះគុណ

នៅពេលដែលអ្នកនៅក្មេង តើព្រះអម្ចាស់មិនបានដឹកនាំអ្នកដោយព្រះតម្រិះ

សម្រេចរបស់ទ្រង់ទេឬអី? ហើយតើទ្រង់មិនបានជួយឲ្យអ្នករួចផុតពីអំពើបាប និង ភាពសោកសង្រេងដែលមនុស្សជាច្រើនជួបប្រទះ នៅពេលអ្នកដឹកនាំជីវិតដោយខ្លួនឯងនោះទេឬអី? ចាប់ពីពេលនេះតទៅ តើអ្នកនឹងនិយាយថា *«ឱព្រះវរបិតានៃខ្ញុំម្ចាស់អើយ ទ្រង់ជាព្រះដ៏ដឹកនាំខ្ញុំម្ចាស់ពីកាលនៅក្មេង»* ទេឬអី? (យេរេមា ៣:៤)។ ដូច្នេះ សូមគិតពីការផ្លាស់ប្តូរនៅក្នុងជីវិតរបស់យើង ដែលទ្រង់បានសម្រេចឲ្យយើងរាល់គ្នា តើជីវិតនោះប្រសើរជាងជីវិតដែលយើងព្យាយាមរៀបចំសម្រាប់ខ្លួនឯងផ្ទាល់ទៅទៀតឬ។ គំនិតរបស់ព្រះ មិនដូចជាគំនិតរបស់យើងរាល់គ្នាទេ ហើយផ្លូវរបស់យើង ក៏មិនមែនជាផ្លូវរបស់ទ្រង់ដែរ (អេសាយ ៥៥:៨)។ គំនិតរបស់យើងត្រូវបើកផ្លូវសម្រាប់ភាពប្រសើរជាង ដែលព្រះតម្រិះសម្រេចបានធ្វើឲ្យយើងមានការភ្ញាក់ផ្អើល។ នៅពេលមានការចាំបាច់ នោះនឹងមានមិត្តម្នាក់ដែលចាំជួយអ្នក ឬក៏មានកន្លែងមួយបើកចំហរង់ចាំទទួលអ្នក។ ទោះជាព្រះតម្រិះសម្រេចយកការនោះចេញទៅហើយក៏ដោយ ក៏ទ្រង់បើកផ្លូវផ្សេងទៀតសម្រាប់អ្នកដែរ។ សូមគិតពីភាពសុភាពទន់ភ្លន់របស់ព្រះជាម្ចាស់ចំពោះរាស្ត្រទ្រង់ ដែលគ្មានអ្វីអាចស្មើបាន! សូមប្រៀបធៀបពីការប្រព្រឹត្តដែលព្រះតម្រិះសម្រេចបានធ្វើចំពោះអ្នក និង ធ្វើចំពោះអ្នកដទៃទៀត ប្រហែលជាគ្រួសាររបស់អ្នកផ្ទាល់ដែលមិនមែនជាគ្រីស្ទបរិស័ទ ហើយសូមចាប់អារម្មណ៍ពីព្រះគុណ ជាព្រះគុណដ៏អស្ចារ្យដែលធ្វើឲ្យអ្នកមានភាពខុសគ្នាពីអ្នកមិនជឿ ដូចជាព្រះបន្ទូលសំដែងថា *«ឯអេសាវ តើមិនមែនជាបងរបស់យ៉ាកុបទេឬអី?»* (ម៉ាឡាគី ១:២)។ សូមគិតពីវិធីដែលព្រះតម្រិះសម្រេចធ្វើចំពោះអ្នក ហើយប្រៀបធៀបវិធីនោះជាមួយនឹងវិធីដែលអ្នកប្រព្រឹត្តចំពោះព្រះអម្ចាស់វិញ។ អ្នកបានធ្វើកិច្ចការមិនល្អជាច្រើនកាលពីអតីតកាល ហើយមិនមែនមានពេលតែមួយទេ ដែលអ្នកអាចចងចាំថា អ្នកបានទទួលនូវគ្រប់យ៉ាងដែលល្អមកពីព្រះហស្តរបស់ព្រះជាម្ចាស់។ ជាចុងក្រោយ សូមប្រៀបធៀបពីគ្រោះថ្នាក់ និង សេចក្តីភ័យខ្លាចរបស់អ្នក ជាមួយនឹងវិធីដែលព្រះតម្រិះ

សម្រេចបានទាញអ្នកចេញពីទុក្ខលំបាករបស់អ្នក។ នៅពេលជីវិតរបស់អ្នក សេរីភាពរបស់អ្នក ឬអ្នកណាម្នាក់ដែលអ្នកស្រឡាញ់ កំពុងតែស្ថិតនៅក្នុងភាពគ្រោះថ្នាក់ នោះភាពអាប់អួនឹងមាននៅក្នុងជីវិតរបស់អ្នក។ អ្នកបានបែរទៅរកព្រះអង្គនៅពេលមានទុក្ខព្រួយ នោះទ្រង់បានប្រទានឲ្យមានផ្លូវដើម្បីចៀសផុត ហើយក៏រំដោះអ្នកឲ្យរួចផុតពីសេចក្តីភ័យខ្លាចដែរ (ទំនុកដំកើង ៣៤:៤)។

កុំរស់នៅដោយរបៀបប្រញាប់ប្រញាល់ពេក ក្រែងធ្វើឲ្យអ្នកគ្មានពេលវេលាដើម្បីអង្គុយចុះ ហើយគិតពីព្រះតម្រិះសំរេច។ សូមពិចារណានៅក្នុងចិត្តរបស់អ្នក ពីការរកឃើញអំណាចដ៏អស្ចារ្យ នៅក្នុងកិច្ចការនៃព្រះតម្រិះសម្រេចរបស់ព្រះម្ចាស់។

## ៨• ការសង្កេតមើលព្រះតម្រិះសម្រេចដោយប្រុងប្រយ័ត្ន នោះនឹងនាំឱ្យគំនិតរបស់អ្នក មានសន្តិភាពនៅក្នុងខ្លួន

អ្នកនិពន្ធកណ្ឌទំនុកដំកើងនិយាយថា *«ទូលបង្គំនឹងសំរាកកាយ ហើយដេកលក់ទៅដោយសេចក្តីស្ងប់ ដ្បិតឱព្រះយេហូវ៉ាអើយ មានតែទ្រង់ទេ ដែលប្រោសឲ្យទូលបង្គំនៅដោយសាន្តត្រាណបាន»* (ទំនុកដំកើង ៤:៨)។ គាត់បានប្តេជ្ញាថា សេចក្តីភ័យខ្លាចខាងអំពើបាប មិនអាចឆក់យកសេចក្តីសុខសាន្តពីគាត់បានទេ។ គាត់នឹងថ្វាយរាល់សេចក្តីកង្វល់ទៅព្រះហស្តព្រះវរបិតាដ៏ស្មោះត្រង់ ដែលបានធ្វើគ្រប់យ៉ាងសម្រាប់គាត់រហូតដល់ពេលនោះ ហើយគាត់មានបំណងមិនចង់ឲ្យបាត់ ឬខាតសេចក្តីសុខសាន្តនៃការសម្រាក នៅពេលតែមួយយប់ទាល់តែសោះ។ មានការពីរយ៉ាង ដែលអាចបំផ្លាញក្តីសុខសាន្តក្នុងជីវិតយើង គឺការគិតច្រើនពេកពីការខកចិត្តនៅអតីតកាល ឬខ្លាចមានការខកចិត្តទៀតនៅពេលអនាគត។ ខណៈដែលយើងគិតពីព្រះតម្រិះសម្រេច នោះមានការមួយចំនួនដែលនាំឲ្យមានសន្តិភាពដោយស្វ័យប្រវត្តិ និង មានលក្ខណៈជួយទៅដល់គំនិតរបស់គ្រីស្ទបរិស័ទ ទោះបីជាព្រឹត្តិការណ៍ដែលកើតឡើងជុំវិញគាត់មិនមានភាពពិតប្រាកដក៏ដោយ។ ជាឧទាហរណ៍ ៖

**ក.** ព្រះតម្រិះសម្រេច មានអំណាចដ៏ខ្ពង់ខ្ពស់បំផុត នៅលើគ្រប់ការទាំងអស់។ យើងអាចឃើញអំណាចនេះ មាននៅក្នុងជីវិតរបស់លោកយ៉ាកុប ដែលគាត់និយាយទៅយ៉ូសែបថា *«អញស្មានថា លែងឃើញមុខឯងហើយ តែមើលព្រះបានឲ្យអញឃើញទាំងពូជឯងផង»* (លោកុប្បត្តិ ៤៨:១១)។ គ្មានអ្វីមួយស្ថិតនៅក្រៅអំណាចរបស់ព្រះជាម្ចាស់ ក្នុងព្រះតម្រិះសម្រេចទេ។

**ខ.** ប្រាជ្ញាញាណដ៏ជ្រាលជ្រៅនៃព្រះតម្រិះសម្រេច ជានិច្ចកាលយើងស្វែងរកការល្អ ឲ្យកើតចេញពីអ្វីមួយដែលស្អាតល្អ ហើយបែរចេញពីអ្វីដែលមើលទៅហាក់ដូចជាការគំរាមកំហែងវិញ តែទីបំផុត ព្រះតម្រិះសម្រេចបានបង្ហាញយើងថា គ្រោះថ្នាក់មាននៅក្នុងអ្វីៗដែលមើលទៅស្អាតល្អនោះ ហើយមានការល្អនៅក្នុងអ្វីដែលយើងបារម្ភវិញ។

**គ.** ការប្រព្រឹត្តរបស់ព្រះតម្រិះសម្រេចសម្រាប់យើង កាលពីអតីតកាល *«ព្រះយេហូវ៉ាទ្រង់បានជួយយើងខ្ញុំ ដរាបដល់ឥឡូវនេះ»* (១សាំយូអែល ៧:១២) លក្ខណៈរបស់ព្រះជាម្ចាស់នៅអតីតកាល ដូចជាលក្ខណៈរបស់ទ្រង់នៅសព្វថ្ងៃនេះដែរ ហើយភាពស្មោះត្រង់របស់ទ្រង់មិនដែលបរាជ័យឡើយ។

**ឃ.** ពេលគ្រីស្ទបរិស័ទមិនមានការរីកចំរើនល្អ នៅក្នុងជីវិតខាងព្រលឹងវិញ្ញាណរបស់គាត់ ជាធម្មតា ព្រះជាម្ចាស់នឹងរៀបចំផ្លូវដើម្បីប្រដៅតម្រង់គាត់វិញ រហូតដល់ចិត្តគាត់បានបន្ទាប ហើយកាន់តែបរិសុទ្ធឡើង។ ព្រះបន្ទូលសំដែងថា បន្ទាប់មក ព្រះជាម្ចាស់ផ្លាស់ប្តូរសូរសៀងនៃព្រះតម្រិះសម្រេចរបស់ទ្រង់ ហើយមានបន្ទូលថា *«ឱអ៊ីស្រាអែល ជាពួករាថយអើយ ចូរវិលមកវិញចុះ អញនឹងមិនបំភ័យឯង ដោយទឹកមុខអញទេ ដ្បិតអញមានសេចក្តីមេត្តា... អញនឹងមិនក្រោធ ជាដរាបឡើយ»* (យេរេមា ៣:១២, ១៣)។

**ង.** នៅពេលយើងប្រៀបធៀបវិធីដែលព្រះជាម្ចាស់ធ្វើមកកាន់យើង ទៅនឹងវិធី

ដែលព្រះអង្គធ្វើទៅកាន់អ្វីផ្សេងទៀតដែលទ្រង់បានបង្កើត នោះនឹងធ្វើឲ្យយើងមានសេចក្តីសង្ឃឹមថ្មី។ ព្រះអង្គថែរក្សាសត្វស្លាបលើអាកាស និង ស្មៅនៅទីវាល ដែលមនុស្សមិនបានថែរក្សាសោះ។ តើយើងគិតថា ទ្រង់នឹងបំភ្លេចរាស្ត្រទ្រង់ ដែលមានតម្លៃខ្ពស់ជាងអ្វីៗទៀតនោះឬ? (ម៉ាថាយ ៦:២៦, ៣០) ការគិតពីការថែរក្សារបស់ព្រះតម្រិះសម្រេច ចំពោះសត្រូវរបស់ព្រះជាម្ចាស់ ទាំងការផ្តល់អាហារ សំលៀកបំពាក់ និង ការការពារដល់ពួកគេ ទោះពួកគេប្រឆាំងនឹងទ្រង់ក៏ដោយ ក៏នឹងនាំឲ្យគំនិតយើងមានសន្តិភាពដែរ។ ពិតប្រាកដណាស់ ទ្រង់មិនអាចភ្លេចប្រទានរបស់ទាំងអស់នេះ ដល់អស់អ្នកដែលទ្រង់បានផ្ទង់សេចក្តីស្រឡាញ់ទៅលើ ហើយជាអ្នកដែលព្រះជាម្ចាស់ប្រទានឲ្យព្រះរាជបុត្រាទ្រង់ និង ជាអ្នកដែលទ្រង់បានរៀបចំនគរស្ថានសួគ៌សម្រាប់គេ។

## ៩. ការពិចារណាដោយប្រុងប្រយ័ត្ន ពីរបៀបដែលព្រះជាម្ចាស់ប្រព្រឹត្តតាមព្រះតម្រិះសម្រេចចំពោះយើង អាចជួយបង្កើនភាពបរិសុទ្ធក្នុងជីវិតយើងបាន

*«ព្រះយេហូវ៉ាទ្រង់សុចរិតក្នុងគ្រប់ទាំងផ្លូវទ្រង់ ក៏សប្បុរសក្នុងគ្រប់ទាំងកិច្ចការរបស់ទ្រង់ដែរ»* (ទំនុកដំកើង ១៤៥:១៧)។

ជួនកាល ព្រះជាម្ចាស់ប្រើមនុស្សអាក្រក់ ដើម្បីធ្វើកិច្ចការដែលទ្រង់បានរៀបចំ ប៉ុន្តែគោលបំណងរបស់ទ្រង់នៅតែបរិសុទ្ធជានិច្ច។ អំពើបាបរបស់មនុស្សមិនអាចមានឥទ្ធិពលដល់ភាពបរិសុទ្ធរបស់ទ្រង់ទេ ដូចជាព្រះអាទិត្យដែលចាំងបញ្ចេញរស្មីទៅលើគំនរសំរាម ប៉ុន្តែមិនទទួលឥទ្ធិពលពីគំនរសំរាមទេ។ ព្រះតម្រិះសម្រេចរបស់ទ្រង់ បានបញ្ឈប់យើងមិនឲ្យធ្វើបាប ដើម្បីធ្វើឲ្យយើងបានបរិសុទ្ធឡើង។ ការទទួលភាពចំរើនច្រើនពេក អាចធ្វើឲ្យយើងមានអំនួត ដូច្នេះហើយបានជារបស់ខ្លះដែលយើងប្រាថ្នាចង់បាន ព្រះអង្គមិនប្រទានឲ្យទេ។ ប្រហែលជាយើងមានរូបកាយទន់ខ្សោយ ឬមិន

មានសុខភាពល្អ ហើយករណីនេះ ព្រះជាម្ចាស់ទ្រង់ការពារយើងមិនឲ្យធ្វើការអាក្រក់ ប្រសិនបើយើងមានកម្លាំងខ្លាំង ហើយមានសុខភាពល្អនោះ។

បើសិនយើងធ្វើបាប ព្រះវរបិតារបស់យើងនឹងខ្ញាល់ ពេលនោះទ្រង់នឹងប្រើព្រឹត្តិការណ៍នៃព្រះតម្រិះសម្រេច ដើម្បីនាំយើងត្រឡប់ទៅឯអង្គទ្រង់ផ្ទាល់វិញ។ អំណាចព្រះលោហិតរបស់ព្រះគ្រីស្ទ បានលាងសំអាតអំពើបាបរបស់យើង ប៉ុន្តែព្រះតម្រិះសម្រេច បាននាំយើងឲ្យអាចសារភាពពីកំហុសដែលយើងបានធ្វើ និង រៀបត្រឹមត្រូវប៉ុណ្ណាដែលព្រះជាម្ចាស់នឹងដំរង់យើងនោះ។ ស្តេចដាវីឌបានស្រែកឡើងថា *«ឱព្រះយេហូវ៉ាអើយ សូមកុំបន្ទោសទូលបង្គំក្នុងកាលដែលទ្រង់ខ្ញាល់ ក៏កុំវាយផ្ចាលទូលបង្គំដោយព្រះហឫទ័យក្តៅឡើយ ដ្បិតព្រួញរបស់ទ្រង់ជាប់គាំងនៅក្នុងខ្លួនទូលបង្គំ ហើយព្រះហស្តទ្រង់ក៏សង្កត់ទូលបង្គំខ្លាំងណាស់ផង»* (ទំនុកដំកើង ៣៨:១, ២)។ ដូច្នេះ ព្រះជាម្ចាស់ប្រើការនោះ ដើម្បីនាំយើងឲ្យមើលឃើញកាន់តែច្បាស់ឡើងពីសេចក្តីអាក្រក់របស់អំពើបាប ហើយព្រះអង្គព្រមានយើងមិនឲ្យធ្វើបាបនៅអនាគតទៀត *«ទូលបង្គំបានទ្រាំរងទោសហើយ ទូលបង្គំលែងធ្វើខុសទៀត»* (យ៉ូប ៣៤:៣១) នោះជាការសប្បាយរីករាយណាស់ ដែលព្រះតម្រិះសម្រេចធ្វើឲ្យមនុស្សមានការភ័យខ្លាចអំពើបាប ទោះជាព្រឹត្តិការណ៍ទាំងនោះនាំឲ្យយើងមានសេចក្តីសុខសាន្ត ឬមានការឈឺចាប់ក៏ដោយ ក៏ព្រឹត្តិការណ៍នោះបង្កើនឲ្យភាពបរិសុទ្ធរបស់យើងបានកើនឡើងដោយនាំយើងត្រឡប់ចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់វិញ។

## ១០• ទីបញ្ចប់ ការពិចារណាពីព្រះតម្រិះសម្រេច ក្លាយជាការប្រើប្រាស់ដ៏ល្អបំផុតសម្រាប់យើង នៅពេលយើងស្លាប់ទៅ

នៅពេលលោកយ៉ាកុបហៀបនឹងស្លាប់ គាត់បាននិយាយអំពីកិច្ចការរបស់ព្រះជាម្ចាស់ ដែលទ្រង់បានធ្វើនៅក្នុងជីវិតរបស់គាត់ តាមរយៈព្រះតម្រិះសម្រេចផ្សេងៗ

(លោកុប្បត្តិ ៤៨:៣, ៧, ១៥, ១៦)។ លោកយ៉ូស្វេក៏និយាយយ៉ាងដូច្នេះដែរ (យ៉ូស្វេ ជំពូក២៤)។ គ្រីស្ទបរិស័ទ! នាទីនៃសេចក្តីស្លាប់ នោះនឹងមានន័យ ប្រសិនបើអ្នកគិតអំពីវិធីផ្សេងៗដែលព្រះជាម្ចាស់បានបង្ហាញពីការថែរក្សា និង សេចក្តីស្រឡាញ់ដល់អ្នកតាមរយៈជីវិតរបស់អ្នក។

**ក.** ពេលវេលានៃសេចក្តីស្លាប់ គឺជាពេលវេលាដែលសាតាំងវាយប្រហារមនុស្ស ដោយប្រើសេចក្តីល្បួងដ៏អាក្រក់។ សាតាំងព្យាយាមធ្វើឲ្យមនុស្សគិតថា ព្រះជាម្ចាស់មិនស្រឡាញ់ពួកគេ ឬរវល់នឹងពួកគេឡើយ ប៉ុន្តែគ្រីស្ទបរិស័ទដែលចងចាំពីពេលដែលព្រះឆ្លើយតបទៅនឹងការអធិស្ឋានរបស់គេ និង ការដែលទ្រង់ប្រទានឲ្យនូវអ្វីដែលគេត្រូវការនៅពេញមួយជីវិតរបស់គេ នោះគេក៏មិនជឿរឿងព្រេងរបស់សាតាំងឡើយ។ គេនឹងនិយាយថា «ព្រះជាម្ចាស់ថែរក្សាខ្ញុំដោយស្រទន់ ចាប់តាំងពីខ្ញុំបានក្លាយជាកូនរបស់ទ្រង់មកម្ល៉េះ។ ព្រះអង្គមិនដែលខាននឹងឲ្យខ្ញុំឡើយ ហើយខ្ញុំក៏មិនជឿដែរថា ទ្រង់នឹងធ្វើកិច្ចការនោះទេឥឡូវនេះ»។ *«ដូច្នេះ ដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយនេះ នោះទ្រង់ក៏ចេះតែស្រឡាញ់គេ ដរាបដល់ចុងបំផុត»* (យ៉ូហាន ១៣:១)។ *«ដ្បិតព្រះនេះ ទ្រង់ជាព្រះនៃយើងខ្ញុំនៅអស់កល្បជានិច្ច ទ្រង់នឹងធ្វើជាអ្នកនាំមុខយើងខ្ញុំ ដរាបដល់អស់ជីវិតផង»* (ទំនុកដំកើង ៤៨:១៤)។

**ខ.** នៅឯសេចក្តីស្លាប់ ពួកបរិសុទ្ធថ្វាយជីវិតរបស់គេផ្ទាល់ទៅព្រះហស្តរបស់ព្រះជាម្ចាស់ ហើយនិងចូលទៅក្នុងសភាវថ្មី ដែលពេលនោះមានភាពខុសគ្នាស្រឡះ។ ព្រះគ្រីស្ទបានធ្វើជាគំរូដល់យើង ដូច្នេះថា *«ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ»* (លូកា ២៣:៤៦) ហើយស្ទេផាន នៅពេលដែលគាត់ហៀបនឹងស្លាប់ទៅ គាត់បាននិយាយថា *«ឱព្រះអម្ចាស់យេស៊ូវអើយ សូមទទួលវិញ្ញាណទូលបង្គំផង»* (កិច្ចការ ៧:៥៩)។

មានការសម្រេចដ៏លំបាកពីរយ៉ាងនៅក្នុងជំនឿ គឺការសម្រេចដំបូង និង ការសម្រេចចុងក្រោយបំផុត។ ការសម្រេចដំបូង គឺជាការធ្វើដំណើរជាមួយព្រះ នៅពេលដែលមនុស្សណាម្នាក់ បានដាក់ខ្លួនចូលទៅក្នុងសេចក្ដីមេត្តារបស់ព្រះគ្រីស្ទ ហើយការសម្រេចចុងក្រោយ ក៏ធ្វើដំណើរជាមួយព្រះដែរ នៅពេលដែលមនុស្សណាម្នាក់ បានទំលាក់ខ្លួនចូលទៅក្នុងមហាសមុទ្រដ៏នៅអស់កល្ប ដោយសារទុកចិត្តជឿលើការសន្យារបស់ព្រះគ្រីស្ទ។ ប៉ុន្តែ ការសម្រេចដំបូង មានការពិបាកជាងការសម្រេចចុងក្រោយ។ នៅចុងបំផុតនៃជីវិត អ្នកជឿក៏បានស្គាល់ព្រះគ្រីស្ទជាមិត្តដ៏ស្មោះត្រង់ ដែលពេញចិត្តបានមកលេងនឹងគេជាច្រើនលើក។ ដូច្នេះ ដោយមានការប្រាកដប្រជាយ៉ាងខ្លាំងក្នុងខ្លួន គ្រីស្ទបរិស័ទអាចនឹងដាក់ខ្លួនទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ដែលអ្នកនោះបាននិយាយ និង ដើរជាមួយអស់រយៈពេលយ៉ាងយូរនៅលើផែនដីនេះ!

**គ.** នៅពេលស្លាប់ទៅ រាស្ត្ររបស់ទ្រង់ទទួលសេចក្ដីសប្បុរសចុងក្រោយ ដែលពួកគេនឹងទទួលនៅក្នុងផែនដីនេះពីព្រះហស្តនៃព្រះតម្រិះសម្រេច។ យើងត្រូវរៀបរាប់ពីវិធី ដែលយើងប្រើប្រាស់រាល់ព្រះពរដែលទ្រង់បានប្រទានមក ហើយថា តើយើងអាចរៀបរាប់យ៉ាងណាបាន បើយើងមិនព្យាយាមរក្សាកំណត់ត្រាមួយចំនួនអំពីព្រះពរ ចាប់ពីពេលឥឡូវនេះទៅនោះ?

**ឃ.** នៅពេលស្លាប់ទៅ យើងគួរតែបន្សល់ទុកសម្រាប់អស់អ្នកដែលនៅរស់នូវការរៀបរាប់ល្អៗពីរបៀបដែលព្រះបានធ្វើនៅក្នុងជីវិតរបស់យើង ដូចជាលោកយ៉ូស្វេបាននិយាយក្នុងសំដីចុងក្រោយរបស់គាត់ ទៅកាន់ហ្វូងមនុស្សថា *«មើល នៅថ្ងៃនេះ អញនឹងទៅតាមផ្លូវរបស់មនុស្សលោកទាំងអស់ ឯនៅក្នុងចិត្ត ហើយក្នុងវិញ្ញាណរបស់ឯង នោះក៏ដឹងទាំងអស់គ្នាថា ឯអស់*

*ទាំងសេចក្តីល្អ ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់បានមានបន្ទូលសន្យាហើយ នោះគ្មានខ្វះណាមួយសោះ ទាំងអស់បានសំរេចគ្រប់ជំពូក ឥតមានខ្វះណាមួយឡើយ»* (យ៉ូស្វេ ២៣:១៤)។

**ង.** នៅពេលស្លាប់ទៅ យើងចាប់ផ្តើមជីវិតដែលរស់នឹងការសរសើរ និង អរព្រះគុណចំពោះព្រះជាម្ចាស់ ព្រមទាំងមានសេចក្តីអំណរជារៀងរាបដូចជាពួកទេវតាដែរ។ ខ្ញុំមិនសង្ស័យថា ព្រះតម្រិះសម្រេចដែលយើងមានការបារម្ភនៅក្នុងលោកនេះ នឹងក្លាយទៅជាផ្នែកមួយនៃចំរៀង ដែលយើងនឹងច្រៀងនៅក្នុងនគរស្ថានសួគ៌ឡើយ។ ដូច្នេះ សូមឲ្យយើងប្រគុំបទភ្លេងនៅក្នុងចិត្ត និង អណ្តាតយើង ខណៈដែលយើងនៅទីនេះ ដោយសញ្ជឹងគិតជារាល់ថ្ងៃពីព្រះជាម្ចាស់ថា ទ្រង់ជាអ្នកណាចំពោះយើង ហើយគិតពីអ្វីដែលទ្រង់ធ្លាប់ធ្វើសម្រាប់យើងដែរ។

# ជំពូក ៦

## ផលវិបាកនៃជំពូកមុនៗ

**១.** ជាកាតព្វកិច្ចរបស់អ្នក គឺត្រូវជឿជាក់ថា ព្រះទ្រង់គង់នៅគ្រប់កាលៈទេសៈដែលកើតឡើងចំពោះអ្នក។ ប្រសិនបើទ្រង់ប្រទានការកំសាន្តចិត្ត នោះជាការអាក្រក់បំផុត បើយើងមើលមិនឃើញព្រះហស្តទ្រង់នៅក្នុងការកំសាន្តចិត្តទាំងនោះ។ ប្រសិនបើទ្រង់បញ្ជូនសេចក្តីលំបាកមកកាន់អ្នក នោះអ្នកគួរតែដឹងថា បញ្ហាទាំងនោះមិនមែនកើតចេញមកដោយឯកឯងនោះទេ ប៉ុន្តែបានកើតចេញពីព្រះហស្តរបស់ទ្រង់វិញ។

**២.** ដោយសារតែព្រះជាម្ចាស់ទ្រង់ធ្វើគ្រប់យ៉ាងសម្រាប់អ្នករាល់គ្នា នោះការយកចិត្តទុកដាក់ថែរក្សារាស្ត្ររបស់ទ្រង់ ពិតជាអស្ចារ្យណាស់! ការថែរក្សាដ៏ស្រទន់របស់ទ្រង់ អស្ចារ្យណាស់ ទ្រង់មិនបានដកព្រះនេត្រចេញពីអ្នកឡើយ (យ៉ូប ៣៦:៧)។ បើមានអ្នកណាម្នាក់ធ្វើឲ្យអ្នកឈឺចាប់ នោះព្រះអង្គនឹងការពារ ហើយថែរក្សាអ្នកទាំងយប់ទាំងថ្ងៃ (អេសាយ ២៧:៣)។ អ្នករាល់គ្នាជាទីស្រឡាញ់របស់ទ្រង់ ហើយព្រះអង្គមិនព្រមទុកឲ្យអ្នកដទៃផ្សេងទៀតថែរក្សាអ្នក ក្រៅពីព្រះហស្តទ្រង់ឡើយ *«ពួកបរិសុទ្ធរបស់ទ្រង់ សុទ្ធតែនៅជាប់ក្នុងព្រះហស្តទ្រង់»* (ចោទិយកថា ៣៣:៣)។

៣. ដោយសារតែព្រះជាម្ចាស់ទ្រង់ធ្វើគ្រប់យ៉ាងសម្រាប់អ្នករាល់គ្នា តើអ្នកមិនមានតួនាទីអ្វីដើម្បីរស់នៅសម្រាប់ព្រះទេឬអី? យើងគួរមានសេចក្ដីប៉ងប្រាថ្នា ដូចជាមនុស្សម្នាក់និយាយថា «ឱព្រះយេហូវ៉ាអើយ ទូលបង្គំអាចធ្វើសម្រាប់ទ្រង់ ដូចជាដៃរបស់ទូលបង្គំ អាចធ្វើសម្រាប់ទូលបង្គំដែរ»។ គោលបំណងទាំងអស់របស់ព្រះជាម្ចាស់ ដែលបានធ្វើសម្រាប់អ្នករាល់គ្នា គឺដើម្បីឲ្យអ្នកក្លាយទៅជាទីបញ្ចេញព្រះពរ សម្រាប់មនុស្សផ្សេងទៀត។ អ្នកនិពន្ធទំនុកដំកើងនិយាយថា *«តើត្រូវឲ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា ចំពោះព្រះគុណដែលទ្រង់បានផ្ដល់មកខ្ញុំទាំងប៉ុន្មាន?»* (ទំនុកដំកើង ១១៦:១២)។ ព្រះជាម្ចាស់ តែងតែធ្វើការល្អសម្រាប់អ្នក ដូច្នេះ អ្នកគួរតែធ្វើជាអ្នកដែលសកម្មសម្រាប់ទ្រង់វិញ។ ទ្រង់តែងធ្វើការល្អគ្រប់នាទីសម្រាប់អ្នក!

៤. ដោយសារតែព្រះជាម្ចាស់ទ្រង់ធ្វើគ្រប់យ៉ាងសម្រាប់រាស្ត្រទ្រង់ ដូច្នេះ កុំឲ្យមិនទុកចិត្តដល់ព្រះអង្គ ពេលមានការលំបាកថ្មីៗកើតឡើងនោះឡើយ។ កាលពីអតីតកាល អ្នកមិនទុកចិត្តទ្រង់ជាញឹកញយ តែសូមកុំឲ្យធ្លាក់ចូលទៅក្នុងការមិនទុកចិត្តទ្រង់ទៀតឡើយ។សូមរៀនពីសេចក្ដីពិតដ៏អស្ចារ្យនេះថា ប្រសិនបើអ្នកទុកចិត្តព្រះជាម្ចាស់ ហើយរង់ចាំឲ្យទ្រង់ជួយសង្គ្រោះអ្នកពីការលំបាកដោយស្ងប់ស្ងាត់ នោះទ្រង់មិនអាចធ្វើ ហើយមិនធ្វើឲ្យអ្នកបរាជ័យឡើយ!

៥. ដោយសារព្រះជាម្ចាស់ទ្រង់ធ្វើគ្រប់យ៉ាងសម្រាប់អ្នករាល់គ្នា ដូច្នេះសូមអធិស្ឋានទៅកាន់ទ្រង់ពីគ្រប់យ៉ាងទាំងអស់។ អ្នកប្រាកដជាមិនអាចទទួលអ្វីដែលអ្នកប៉ងឬខំធ្វើឲ្យបាននោះឡើយ លើកតែព្រះជាម្ចាស់ទ្រង់ធ្វើការនោះសម្រាប់អ្នក។ ទោះជាទ្រង់មានគោលបំណងធ្វើអ្វី ជាសេចក្ដីប៉ងប្រាថ្នារបស់អ្នកក៏ដោយ ក៏ទ្រង់នៅ

តែសង្ឃឹមថា យើងនឹងទូលសូមដល់ទ្រង់អំពីការទាំងនោះដែរ រួចបន្ទាប់ពីពេលដែលអ្នកបានអធិស្ឋានរួចមក អ្វីដែលអ្នកទូលសូមនោះជារបស់អ្នកហើយ។

**៦.** ដោយសារតែព្រះជាម្ចាស់ទ្រង់ធ្វើគ្រប់យ៉ាងសម្រាប់អ្នករាល់គ្នា នោះគោលបំណងធំជាងគេរបស់អ្នក គឺចង់ឲ្យគ្រប់ការទាំងអស់ដែលអ្នកធ្វើ បានគាប់នឹងព្រះហឫទ័យរបស់ទ្រង់។ គ្មានបញ្ហាណាមួយ មានលទ្ធផលអាក្រក់ចំពោះគ្រីស្ទបរិស័ទ ដែលមានបំណងគាប់នឹងព្រះហឫទ័យព្រះនោះឡើយ ដូចជាផ្កាភ្លើងដែលងាយនឹងរលត់នៅក្នុងទឹកសមុទ្រ ដូច្នេះព្រះគុណរបស់ព្រះនឹងមិនបណ្តាលឲ្យមានលទ្ធផលអាក្រក់ដល់អ្នកឡើយ។ ដោយសារព្រះទ្រង់ធ្វើគ្រប់ការទាំងអស់ ទ្រង់ក៏មានអំណរនៅពេលយើងធ្វើតែការល្អ ឯយើងក៏មានសុវត្ថិភាពដែរ ទោះបីជាយើងស្ថិតនៅក្នុងភាពលំបាក និង គ្រោះថ្នាក់ធំប៉ុណ្ណាក៏ដោយ ដូច្នេះសូមឲ្យប្រាជ្ញាដែលយើងរកបានពីព្រះគម្ពីរ ជួយដឹកនាំយើង។ មិនត្រូវខ្លាចអ្វីឡើយ តែត្រូវខ្លាចអំពើបាបវិញ។ សូមឲ្យមានគោលបំណងដ៏ចំបង ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ ហើយទុកចិត្តព្រះអង្គក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ។ ទាំងនេះពិតជាការណែនាំសម្រាប់សុវត្ថិភាព និង ព្រះពរក្នុងគ្រប់ភាពមិនប្រាកដទាំងអស់នៅក្នុងជីវិតរបស់យើងនេះ។

# ជំពូក ៧

## បញ្ហាដែលសាំញ៉ាំ

*(ជំពូកនេះក៏រួមបញ្ចូលជាមួយនឹងជំពូក៨ របស់លោកហ្វាវែលដែរ)*

### ១• តើគ្រីស្ទបរិស័ទអាចរកឃើញបញ្ហាដែលមានប្រយោជន៍ ពីព្រះហឫទ័យព្រះយ៉ាងដូចម្តេច នៅពេលដែលស្ថិតក្នុងកាលៈទេសៈលំបាក និង សង្ស័យនោះ?

ជាដំបូងយើងត្រូវតែយល់ថា ព្រះហឫទ័យរបស់ព្រះជាម្ចាស់មានន័យដូចម្តេច។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជារឿងមានមុខពីរគឺ មានព្រះហឫទ័យសម្ងាត់ និង មានព្រះហឫទ័យដែលបានសំដែងឲ្យឃើញច្បាស់។ ព្រះបន្ទូលបានសំដែងថា *«អស់ទាំងសេចក្តីលាក់កំបាំង នោះស្រេចនៅព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នាទេ តែសេចក្តីដែលបានបើកសំដែងមកទាំងប៉ុន្មាន នោះស្រេចនៅយើងរាល់គ្នា»* (ចោទិយកថា ២៩:២៨)។ យើងគ្រាន់តែគិតខ្លួនឯង ជាមួយនឹងព្រះហឫទ័យដែលព្រះជាម្ចាស់បើកសំដែងឲ្យយើងប៉ុណ្ណោះ។ យើងអាចយល់ដឹងពីការទាំងនោះ តាមព្រះបន្ទូលរបស់ទ្រង់ ឬតាមរយៈកិច្ចការរបស់ទ្រង់។

**ក.** មានភាពខុសគ្នាយ៉ាងច្រើន នៅក្នុងកិច្ចការដែលព្រះជាម្ចាស់បានបើកសំដែងមក។ ព្រះបន្ទូលបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ ពីរឿងដ៏សំខាន់បំផុតរបស់ជំនឿគ្រីស្ទបរិស័ទ ប៉ុន្តែកិច្ចការដែលមិនសូវសំខាន់ ជួនកាលមានការពិបាកយល់ជាងនេះទៅទៀត។

**ខ.** មានភាពខុសគ្នាយ៉ាងខ្លាំង រវាងអស់អ្នកដែលព្រះជាម្ចាស់បានបើកសំដែងឲ្យឃើញបំណងព្រះហឫទ័យរបស់ទ្រង់។ អ្នកខ្លះមានលក្ខណៈដូចជាមនុស្សដែលមានកម្លាំងខ្លាំង ហើយខ្លះទៀតដូចជាទារកវិញ (១កូរិនថូស ៣:១)។ អ្នកខ្លះអាចយល់បានពីអ្វីដែលគេគួរធ្វើ ហើយអ្នកខ្លះទៀត ពិបាកយល់ពីការធ្វើនោះណាស់។

**គ.** វិធីដែលព្រះជាម្ចាស់សំដែងពីព្រះហឫទ័យរបស់ទ្រង់ទៅកាន់មនុស្ស ក៏មានលក្ខណៈខុសៗគ្នាដែរ។ នៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់បានបង្ហាញដល់មនុស្សពីអ្វីដែលត្រូវធ្វើដោយរបៀបពិសេសផ្ទាល់ ដូចជាពេលដែលសាំយូអែលបានជ្រើសរើសសូលធ្វើជាស្តេច (១សាំយូអែល ៩:១៥-១៧) ហើយនិងពេលដែលដាវីឌបានសុំឲ្យព្រះអម្ចាស់ប្រាប់គាត់ថា គាត់គួរទៅប្រយុទ្ធនឹងពួកភីលីស្ទីនឬទេ (១សាំយូអែល ២៣:២, ៤)។ ប៉ុន្តែ ឥឡូវនេះយើងមានព្រះគម្ពីរទាំងមូលដើម្បីធ្វើជាមគ្គទេសក៍របស់យើងហើយ ដូច្នេះយើងមិនគួរគិតថា ចាំបាច់ត្រូវតែមានការបើកសំដែងដ៏ពិសេសនោះទេ តែយើងត្រូវស្រាវជ្រាវពីព្រះបន្ទូល ហើយនៅពេលយើងរកមិនឃើញការណែនាំពិសេសដើម្បីដឹកនាំយើង នោះយើងត្រូវតែប្រើប្រាស់ការណែនាំជាទូទៅរបស់ព្រះគម្ពីរ ទាក់ទងនឹងបញ្ហារបស់យើងនោះ។

ទោះជាយ៉ាងណា យើងប្រហែលមានការសង្ស័យថាត្រូវធ្វើអ្វី។ ក្នុងករណីនេះ យើងមិនគួរមើលទៅតែព្រះតម្រិះសម្រេច ដើម្បីស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយខ្លួនឯងនោះទេ។ វិធីដែលត្រឹមត្រូវជាងគេនោះគឺ ពិចារណាពីព្រះតម្រិះសម្រេចដែលបានធ្វើតាមការបង្គាប់ និង ការសន្យានៅក្នុងព្រះគម្ពីរ។ ពេលដែលអ្នកអធិស្ឋានសូមឲ្យព្រះដឹកនាំជីវិត នោះអ្នកនឹងឃើញថា ព្រះតម្រិះសម្រេចស្របគ្នានឹងមនសិការ

របស់អ្នក ហើយនិងជាមួយពន្លឺដ៏ល្អបំផុត ដែលអ្នកអាចរកឃើញនៅក្នុងព្រះគម្ពីរ អ្នកអាចយកការនោះធ្វើជាការលើកទឹកចិត្ត ដើម្បីបន្តទៅតាមវិធីដែលបានបង្ហាញមក។ ប៉ុន្តែបើសិនអ្នកណានិយាយថា នោះជាកិច្ចការរបស់ព្រះតម្រិះសម្រេច តែផ្ទុយពីការណែនាំរបស់ព្រះបន្ទូល នោះអ្នកមិនគួរទៅតាមទេ ហើយប្រសិនបើមនុស្សប្រើព្រះតម្រិះសម្រេចដោយខ្លួនឯងជាការណែនាំដើម្បីដឹកនាំយើង ពេលនោះយើងអាចបញ្ជាក់ថា មនុស្សអាក្រក់ដែលធ្វើបាបអាចនិយាយថា ព្រះជាម្ចាស់បានដឹកនាំគេឲ្យធ្វើបាបនោះ។ ការ ណែនាំខាងក្រោមនេះ នឹងជួយអ្នកឲ្យរកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់ ៖

**ក.** មានការកោតខ្លាចដល់ព្រះ ជាពិតប្រាកដនៅក្នុងចិត្តរបស់អ្នក ហើយចេះតែខ្លាចចំពោះការប្រព្រឹត្តដែលធ្វើឲ្យទាស់ព្រះហឫទ័យទ្រង់ *«សេចក្តីមេត្រីមិត្ររបស់ព្រះយេហូវ៉ា នៅជាមួយនឹងអ្នកណាដែលកោតខ្លាចដល់ទ្រង់ ទ្រង់នឹងសំដែងឲ្យគេស្គាល់សេចក្តីសញ្ញារបស់ទ្រង់»* (ទំនុកដំកើង ២៥:១៤)។

**ខ.** ចូរសិក្សាព្រះបន្ទូលឲ្យបានច្រើនឡើង ហើយសិក្សាពីកិច្ចការនៅលោកិយឲ្យតិចជាង។ *«ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ»* (ទំនុកដំកើង ១១៩:១០៥)។ ព្រះបន្ទូលនឹងបង្ហាញអ្នកពីអ្វីដែលត្រូវធ្វើ និង ពីគ្រោះថ្នាក់ដែលត្រូវចៀសវាង។

**គ.** សូមយកអ្វីដែលអ្នកធ្លាប់ចេះមកអនុវត្ត *«បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ»* (យ៉ូហាន ៧:១៧)។ *«អស់អ្នកដែលកាន់តាម នោះមានយោបល់ល្អ»* (ទំនុកដំកើង ១១១:១០)។

**ឃ.** សូមអធិស្ឋានឲ្យមានពន្លឺ ហើយទូលសូមឲ្យព្រះអម្ចាស់ដឹកនាំអ្នក ដើម្បីមិនឲ្យអ្នកធ្លាក់ក្នុងអំពើបាបឡើយ (អែសរ៉ា ៨:២១)។

**ង.** បន្ទាប់មក សូមធ្វើតាមព្រះតម្រិះសម្រេច ដែលស្របទៅនឹងព្រះគម្ពីរ ហើយកុំធ្វើតាមអ្វីក្រៅពីព្រះគម្ពីរឡើយ។ នៅពេលមានទុក្ខលំបាក នោះជាពេល

ដែលត្រូវបន្ទាបខ្លួនក្រោមព្រះហស្តដ៏មានអំណាចរបស់ព្រះជាម្ចាស់។ ម្យ៉ាងវិញទៀត ជាពេលដែលត្រូវត្រេកអរក្នុងព្រះអម្ចាស់ នៅពេលទ្រង់បញ្ជូនព្រះតម្រិះសម្រេចឲ្យមកកំសាន្តចិត្តយើង *«នៅគ្រាដែលមានសេចក្ដីចំរើននោះចូរឲ្យមានចិត្តអរសប្បាយចុះ»* (សាស្តា ៧:១៤)។ យើងគួរតែរៀនពីអ្វីដែលព្រះជាម្ចាស់បង្រៀនយើងនៅក្នុងកាលៈទេសៈផ្សេងៗនោះ នៅពេលដែលព្រះតម្រិះសម្រេច បានចង្អុលបង្ហាញការបង្រៀននោះដល់យើងហើយ។

## ២. តើគ្រីស្ទបរិស័ទអាចរៀនឱ្យចេះរង់ចាំព្រះជាម្ចាស់ដូចម្ដេច ខណៈដែលព្រះតម្រិះសម្រេចបង្អែបង្អង់ចម្លើយនៃសេចក្ដីអធិស្ឋានរបស់គាត់?

មានវិធីពីរយ៉ាង ក្នុងការមើលទៅកាន់ការបង្អែបង្អង់ទាំងនោះ។ ទស្សនៈមួយថា ពេលវេលា និង រដូវកាល ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ (កិច្ចការ ១:៧) ប៉ុន្តែទស្សនៈរបស់យើង យើងតែងតែសង្ឃឹមថានឹងបានចម្លើយនៃសេចក្ដីអធិស្ឋានរបស់យើងឲ្យបានឆាប់ៗ។ ឥឡូវនេះ គ្មានអ្វីមួយដែលពិតប្រាកដ ឬច្បាស់ជាង អំពីពេលវេលាដែលព្រះជាម្ចាស់កំណត់ ដើម្បីឆ្លើយនឹងសំណូមពររបស់យើងនោះទេ។ ប្រសិនបើអ្នកប្រៀបធៀបកណ្ឌនិក្ខមនំ ១២:៤១ ជាមួយនឹងកណ្ឌកិច្ចការ ៧:១៧ នោះអ្នកនឹងឃើញមូលហេតុនៃការរំដោះពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទនោះ មិនបានពន្យារពេល សូម្បីតែមួយថ្ងៃ ពីព្រោះពេលសន្យារបស់ព្រះជាម្ចាស់បានមកដល់ហើយ។ យើងមានការខកចិត្តចំពោះការបង្អែបង្អង់របស់ព្រះតម្រិះសម្រេច ហើយក៏ចាប់ផ្ដើមសង្ស័យពីភាពស្មោះទ្រង់របស់ព្រះវិញ ប៉ុន្តែព្រះរាជតម្រិះរបស់ព្រះអង្គ មិនដូចនឹងគំនិតរបស់យើងទេ (អេសាយ ៥៥:៨)។ *«ព្រះអម្ចាស់មិនផ្អាកសេចក្ដីសន្យារបស់ទ្រង់ ដូចជាមានអ្នកខ្លះគិតស្មាននោះទេ»* (២ពេត្រុស ៣:៩)។ ព្រះអម្ចាស់មិនគិតពីពេលវេលានៃកិច្ចការរបស់ទ្រង់ ដោយសារគំនិតរបស់យើងនោះឡើយ។ ព្រះអង្គកំណត់

ពេលវេលា ហើយទោះជាចម្លើយតបរបស់ទ្រង់មានការបង្អែបង្អង់ យូរជាងអ្វីដែលយើងគិតក៏ដោយ ក៏ការនោះមិនលើសកំណត់ពេលវេលារបស់ទ្រង់ឡើយ។

កំឡុងពេលនៃការបង្អែបង្អង់នេះ រាស្ត្រទ្រង់ប្រហែលជាមានការធ្លាក់ទឹកចិត្ត។ ព្រះអម្ចាស់បានសន្យាតាមរយៈហោរាអេសាយថា ទ្រង់នឹងប្រទានសេចក្ដីមេត្តាដល់រាស្ត្រទ្រង់ក្នុងពេលដែលពួកគេនៅជាឈ្លើយសឹក ពួកគេបានរង់ចាំពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែគ្មានអ្វីកើតឡើងសោះ *«តែក្រុងស៊ីយ៉ូនបានថា ព្រះយេហូវ៉ាទ្រង់បានបោះបង់ចោលខ្ញុំទេ គឺព្រះអម្ចាស់ទ្រង់បានភ្លេចខ្ញុំហើយ»* (អេសាយ ៤៩:១៤) ស្ដេចដាវីឌក៏មានអារម្មណ៍យ៉ាងនោះដែរ។ ព្រះជាម្ចាស់បានសន្យាយ៉ាងដូច្នេះទៅកាន់ស្ដេចដាវីឌ ដែលគេបានហៅថា «សេចក្ដីមេត្តាចំពោះស្ដេចដាវីឌ» តែស្ដេចដាវីឌគិតថា ព្រះជាម្ចាស់ ភ្លេចទ្រង់ទៅវិញ។ ស្ដេចដាវីឌមានបន្ទូលថា *«តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត»* (ទំនុកដំកើង ១៣:១)។ មានហេតុផលបីយ៉ាង ដែលជាហេតុធ្វើឲ្យយើងធ្លាក់ទឹកចិត្តតាមរយៈការនេះ ៖

**ក.** យើងមានគំនិតមិនជឿ ហើយក៏មិនពឹងផ្អែកដោយជំនឿជឿជាក់ និង ទំនុកចិត្តយ៉ាងមុតមាំទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទ្រង់ស្មោះត្រង់ និងមិនចេះប្រែប្រួលដែរ។ យើងឃើញហេតុផលនៃចិត្តដែលទន់ខ្សោយនេះ មាននៅកណ្ឌទំនុកដំកើង ២៧:១៣ *«ខ្ញុំនឹងទន់ខ្សោយ លុះត្រាតែខ្ញុំជឿ»*។ យើងក៏អាចនិយាយថា ចិត្តដែលទន់ខ្សោយ គឺជាភស្ដុតាងនៃការមិនជឿ។

**ខ.** យើងមើលទៅអ្វីៗដែលបង្ហាញឲ្យឃើញចំពោះវិញ្ញាណរបស់យើង។ មានគេធ្លាប់និយាយពីលោកអ័ប្រាហាំថា *«ប្រឆាំងនឹងសេចក្ដីសង្ឃឹម»* គឺថាការប្រឆាំងនឹងភាពដែលអាចនឹងកើតមានឡើងជាធម្មតា គាត់ *«ជឿដោយសង្ឃឹម ...ទាំងសរសើរដំកើងដល់ព្រះវិញ»* (រ៉ូម៤:១៨,២០)។ យើងអាចរក្សាព្រលឹងវិញ្ញាណរបស់យើង ដោយសម្លឹងទៅឆ្ងាយមើលពីអ្វីដែលយើងមើលឃើញ

តាមរយៈភ្នែកធម្មតារបស់យើង ហើយដោយវាស់ស្ទង់គ្រប់យ៉ាងតាមការណែនាំមួយផ្សេងទៀត គឺថា ដោយសារអំណាច និង ភាពស្មោះត្រង់របស់ព្រះជាម្ចាស់ (២កូរិនថូស ៤:១៦, ១៨)។

**ឥ.** សាតាំងប្រើឱកាសទាំងនេះ ដើម្បីឲ្យយើងគិតមិនត្រឹមត្រូវពីព្រះជាម្ចាស់។ នៅពេលដែលយើងមានទឹកចិត្តស្រពាប់ស្រពោន នោះយើងព្រមស្តាប់សាតាំងច្រើនជាង។ សាតាំងតែងតែធ្វើឲ្យឆន្ទៈរបស់យើងខ្សោយ ហើយបញ្ឈប់យើងមិនឲ្យរង់ចាំព្រះទៀត។

ក្នុងន័យដែលយើងបាននិយាយ នោះជាការចាំបាច់ឲ្យយើងមានជីវិតដែលប្រយ័ត្នប្រយែង ហើយថ្វាយគ្រប់យ៉ាងទៅក្នុងព្រះហស្តទ្រង់ និង រង់ចាំការរំដោះឲ្យរួចរបស់ទ្រង់ដោយស្ងប់រម្ងាប់។ ដើម្បីជួយយើងឲ្យធ្វើកិច្ចការនេះបាន ខ្ញុំសូមផ្តល់គំនិតមួយចំនួនដូចខាងក្រោមនេះ ៖

**ក.** អ្នកគ្មានហេតុផលពិតប្រាកដ នឹងគិតមិនត្រឹមត្រូវពីព្រះជាម្ចាស់ទេ ដោយព្រោះ ប្រហែលព្រះអង្គមិនបានសន្យាឲ្យអ្វីដែលអ្នកគិតថាអ្នកគួរទទួលពីព្រះជាម្ចាស់នោះឡើយ។ អ្នកប្រហែលជាសន្យានឹងខ្លួនអ្នកផ្ទាល់ថា នឹងបានអ្វីមួយ ដូចជាភាពចម្រើន និង បន្តីរីករាយជាមួយអ្វីដែលអ្នកមានហើយ។ ប៉ុន្តែតើព្រះជាម្ចាស់ទ្រង់សន្យាការនេះនៅពេលណា? ការសន្យាដែលថា ព្រះជាម្ចាស់នឹងផ្តល់ឲ្យអ្វីដែលល្អមានកំរិតកំណត់ចំពោះអស់អ្នក *«ដែលដើរដោយទៀងត្រង់»* (ទំនុកដំកើង ៨៤:១១)។ សូមគិតពីចិត្តរបស់អ្នក ហើយមើលថា តើចិត្ត និង ជីវិតរបស់អ្នកបានបែរចេញពីព្រះដែរឬទេ ដើម្បីឲ្យដឹង ថាទ្រង់យុត្តិធម៌នឹងហូតយកការទាំងនោះចេញ។ យ៉ាងណាក៏ដោយ ក៏រាល់ការសន្យាល្អៗនៅក្នុងជីវិតរបស់អ្នកលើផែនដីនេះ នៅតែកំណត់ដោយព្រះតម្រិះ

និង ព្រះហឫទ័យរបស់ទ្រង់ដែរ។ តើអ្នកណាប្រាប់អ្នកឲ្យសង្ឃឹមថា នឹងបានសម្រាក មានភាពងាយស្រួល និង មានភាពរីករាយនៅលើផែនដីនេះអស់មួយជីវិតនោះ? ជាញឹកញយ ព្រះជាម្ចាស់តែងតែប្រាប់យើងថា យើងត្រូវតែជឿជាក់ថានឹងជួបប្រទះបញ្ហានៅលើផែនដីនេះ (យ៉ូហាន ១៦:៣៣) ហើយ *«ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន... ទើបនឹងចូលទៅក្នុងនគរព្រះបាន»* (កិច្ចការ ១៤:២២)។ ព្រះជាម្ចាស់បានសន្យាថា ព្រះអង្គនឹងគង់ជាមួយយើងនៅពេលមានការលំបាក ផ្ដល់ដល់យើងឲ្យបានតាមតម្រូវការពិតប្រាកដ និង ធ្វើឲ្យការទាំងអស់ផ្សំគ្នា សម្រាប់ការល្អរបស់យើង (ទំនុកដំកើង ៩១:១៥; អេសាយ ៤១:១៧; រ៉ូម ៨:២៨)។

**ខ.** បើសិនជាក្រោយអ្នកបានអធិស្ឋានទៅព្រះជាម្ចាស់ ទូលសូមព្រះពរខាងព្រលឹងវិញ្ញាណ រួចអ្នកក៏បានរង់ចាំអស់រយៈពេលជាយូរមកហើយដែរ តែអ្នកមិនបានទទួលអ្វីសោះ នោះខ្ញុំអាចសួរអ្នកថា អ្នកចង់បានព្រះពរបែបណាខ្លះ? ព្រះពរខាងព្រលឹងវិញ្ញាណមានពីរប្រភេទ គឺមួយសម្រាប់ការចាំបាច់ក្នុងការបន្តជីវិតរស់នៅខាងព្រលឹងវិញ្ញាណ និង មួយទៀត គឺសម្រាប់ការបង្កើនសេចក្ដីអំណរ និង ការកំសាន្តចិត្តរបស់យើង។ ព្រះពរទីមួយ គឺចាំបាច់យ៉ាងក្រៃលែង ហើយជាការសន្យាដែលពិតប្រាកដ និង មិនបរាជ័យឡើយ។ *«អញនឹងតាំងសេចក្ដីសញ្ញានឹងគេ ជាសេចក្ដីសញ្ញាដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចថា អញនឹងមិនបែរចេញពីគេឡើយ គឺនឹងឲ្យគេបានសេចក្ដីល្អវិញ អញនឹងដាក់សេចក្ដីកោតខ្លាចដល់អញក្នុងចិត្តគេ ប្រយោជន៍កុំឲ្យគេឃ្លាតចេញពីអញឡើយ»* (យេរេមា ៣២:៤០)។ ព្រះពរទីពីរ បានមកដោយសារព្រះអង្គទតឃើញថា ការនោះល្អសម្រាប់យើង ប៉ុន្តែរាស្ត្ររបស់ទ្រង់ជាច្រើន បានរស់នៅដោយគ្មានព្រះពរទាំងនេះ ជាយូរមកហើយ ។

**គ.** អ្នកគួរតែសួរខ្លួនអ្នកផ្ទាល់ថា អ្នកមានមូលហេតុអ្វីខ្លះដើម្បីបានព្រះពរទាំងនេះ។ ប្រហែលជាអ្នកមិនបានទទួលអ្វីដែលអ្នកសូមទេ ពីព្រោះអ្នកមិនចង់បានព្រះពរ តាមហេតុផលត្រឹមត្រូវ (យ៉ាកុប ៤:៣)។ ជួនកាល យើងគ្រាន់តែទូលសូមឲ្យផុតពីការលំបាកប៉ុណ្ណោះ ពីព្រោះការលំបាកនេះបំផ្លាញក្ដីរីករាយរបស់យើងនៅលើផែនដីនេះ។ ជាការពិត ព្រះអង្គប្រទានសេចក្ដីទុក្ខលំបាកដើម្បីឲ្យយើងមានជីវិតរស់នៅ ដែលស្ដាប់បង្គាប់ដល់ទ្រង់បានច្រើនឡើង។

**ឃ.** តើអ្នកពិតជាត្រៀមខ្លួនរួចជាស្រេច ឲ្យព្រះហឫទ័យរបស់ព្រះបានសម្រេចនៅក្នុងជីវិតរបស់អ្នកហើយឬនៅ? ការដែលធ្វើឲ្យអ្នកគាប់ចិត្ត ជាភាពសប្បាយរីករាយដែលចេញពីការប៉ងប្រាថ្នារបស់អ្នក ប៉ុន្តែព្រះអង្គសព្វព្រះហឫទ័យនៅពេលដែលអ្នកសម្រេចធ្វើតាមព្រះហឫទ័យទ្រង់វិញ។ ព្រះពរមិនប្រទានមកអ្នកទេ ទាល់តែអ្នកចង់ធ្វើតាមព្រះហឫទ័យទ្រង់ដោយអស់ពីចិត្ត។ ស្ដេចដាវីឌត្រូវរង់ចាំយ៉ាងយូរនូវអ្វីដែលព្រះជាម្ចាស់ មានបន្ទូលសន្យាជាមួយទ្រង់ ហើយនៅកំឡុងពេលនោះ ព្រលឹងរបស់ស្ដេចដាវីឌបានក្លាយទៅជា *«ក្មេងដែលផ្ដាច់ដោះ»* (ទំនុកដំកើង ១៣១:២)។ ប្រសិនបើស្ដេចដាវីឌ និង អ្នកដទៃផ្សេងទៀត ត្រូវតែរង់ចាំព្រះពរអស់រយៈពេលយូរ ចុះហេតុអ្វីបានជាអ្នកមិនត្រូវរង់ចាំដែរ?

**ង.** តើអ្នកបាត់បង់អ្វីឬទេ ដោយសារការរង់ចាំព្រះជាម្ចាស់នោះ? ពិតណាស់អ្នកមិនបាត់បង់អ្វីទេ។ ជាការប្រសើរ បើយើងដឹងពីព្រះគុណដែលព្រះជាម្ចាស់ធ្វើកិច្ចការនៅក្នុងជីវិតរបស់យើង ជាជាងយើងមានការកំសាន្តចិត្តទៅទៀតនោះ។ ព្រះអម្ចាស់ប្រទានមេរៀនពីជំនឿ និង ការអត់ធ្មត់មកកាន់អ្នក ហើយធ្វើឲ្យអ្នកចាប់អារម្មណ៍ច្រើនជាង ក្នុងការធ្វើតាមព្រះហឫទ័យទ្រង់វិញ។ នៅពេលព្រះពរដែលអ្នកចង់បាននោះមកដល់ នោះអ្នកនឹងកាន់តែរីករាយ ដោយព្រោះអ្នកបានប្រើជំនឿ និង ការអធិស្ឋានរួចមកហើយ។

**ច.** ប្រសិនបើព្រះពរដែលអ្នករំពឹងចង់បានពីព្រះជាម្ចាស់ មិនមានប្រយោជន៍សម្រាប់អ្នករង់ចាំទេ នោះគឺជាការល្ងង់ខ្លៅដែលអ្នកជាប់ក្នុងសេចក្តីទុក្ខវេទនានោះ ពីព្រោះអ្នកមិនបានទទួលព្រះពរទាំងនោះទេ។ អ្វីដែលព្រះជាម្ចាស់រំពឹងចង់បានពីអ្នកនោះ គឺគ្រាន់តែចង់ឲ្យអ្នករង់ចាំសេចក្តីមេត្តារបស់ទ្រង់ នោះជាព្រះគុណទទេរបស់ទ្រង់។ សូមគិតពីការសន្យាជាច្រើន ដែលព្រះអង្គបានធ្វើជាមួយនឹងអស់អ្នកដែលរង់ចាំព្រះអម្ចាស់ *«មានពរហើយ អស់អ្នកណាដែលរង់ចាំទ្រង់»* (អេសាយ ៣០:១៨) ហើយនិង *«តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច»* (អេសាយ ៤០:៣១)។

**ឆ.** សូមនឹកចាំថា ព្រះជាម្ចាស់បានរង់ចាំអ្នកយូរប៉ុណ្ណា មុនអ្នកបានបែរត្រឡប់មករកទ្រង់ និង ស្តាប់បង្គាប់ព្រះបន្ទូលទ្រង់វិញ។ តើជាការត្រឹមត្រូវដែរឬទេ ដែលថា ព្រះជាម្ចាស់ធ្វើឲ្យអ្នករង់ចាំព្រះពរនោះ? ការមិនជឿរបស់យើង ធ្វើឲ្យទ្រង់ព្រះកន្សែង *«តើដល់កាលណាទៀត ដែលគេនៅតែមិនជឿដល់អញ?»* (ជនគណនា ១៤:១១) ហើយ *«តើគំនិតអាក្រក់នឹងចេះតែនៅជាប់ក្នុងចិត្តខ្លួន ដល់កាលណាទៀត?»* (យេរេមា ៤:១៤)។

**ជ.** បើសិនជាអ្នកល្ងើយនឹងការរង់ចាំ នោះជាសេចក្តីអាក្រក់ដ៏ធំវិញ។ ប្រហែលជាអ្នកអាចទទួលសេចក្តីមេត្តាយ៉ាងឆាប់ៗ ប្រសិនបើព្រលឹងវិញ្ញាណរបស់អ្នកមានសភាពស្ងប់ស្ងាត់ ហើយព្រមចុះចូលព្រះហឫទ័យរបស់ទ្រង់។

**៣. តើគ្រីស្ទបរិស័ទដឹងដូចម្តេចបាន នៅពេលដែលព្រះតម្រិះសម្រេចធ្វើការល្អបំផុតឱ្យគាត់ ហើយកិច្ចការនោះកើតចេញមកពីសេចក្តីស្រឡាញ់របស់ព្រះ?**

ព្រះជាម្ចាស់អាចនឹងធ្វើកិច្ចការដ៏ល្អសម្រាប់រាស្ត្រទ្រង់ ចេញពីសេចក្តីអាក្រក់ (រ៉ូម ៨:២៨)។ អំពើបាប មិនដែលធ្វើការល្អសម្រាប់មនុស្សគ្រប់គ្នាទេ ប៉ុន្តែព្រះតម្រិះ

សម្រេចរបស់ព្រះជាម្ចាស់ អាចប្រើព្រឹត្តិការណ៍ដែលអំពើបាបមាននៅទីនោះ ក្លាយជាការល្អសម្រាប់រាស្ត្ររបស់ទ្រង់វិញ។ យើងមិនអាចដឹងថា ព្រឹត្តិការណ៍ពិតប្រាកដដែលកើតឡើងចំពោះយើង បានកើតឡើងសម្រាប់ការល្អចំពោះយើងឬក៏អត់នោះទេ។ មនុស្សអាក្រក់ ហើយអ្នកមិនជឿជាច្រើន *«គេមានច្រើនលើសជាងចិត្តប្រាថ្នាទៅទៀត»* (ទំនុកដំកើង ៧៣:៧) ដូច្នេះ យើងមិនអាចកាត់ក្តីពីសេចក្តីស្រឡាញ់របស់ ព្រះជាម្ចាស់ចំពោះយើង ដោយសារតែព្រះពរមួយចំនួនដែលយើងទទួលបាននោះទេ។ វិធីដែលកិច្ចការទាំងនេះកើតឡើងចំពោះយើង និង ឥទ្ធិពលរបស់វាចំពោះយើង នឹងបង្ហាញថា តើព្រះពរទាំងនោះកើតចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និង មកជាសេចក្តីល្អខាងព្រលឹងវិញ្ញាណសម្រាប់យើងយ៉ាងដូចម្តេច។

**ក.** ជាដំបូង សូមឲ្យយើងក្រឡេកមើលទៅព្រឹត្តិការណ៍ដែលបណ្តាលឲ្យយើងមានទុក្ខលំបាក និង សេចក្តីសោកសង្រេងទាំងនោះ។ យើងអាចដឹងថា ព្រឹត្តិការណ៍ទាំងនោះ ពិតជាព្រះពរចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នៅពេលការនោះកើតមានឡើងក្នុងកាលៈទេសៈ ដូចខាងក្រោមនេះ ៖

១. ព្រឹត្តិការណ៍ទាំងនោះកើតឡើងចំពេលត្រឹមត្រូវ ទាំងទប់យើងមិនឲ្យធ្លាក់ទៅក្នុងអំពើបាប ឬនាំយើងត្រឡប់ពីវិញ្ញាណធ្វេសប្រហែស ដែលយើងបានធ្លាក់ចូលទៅនោះ *«ត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្តីល្បួងផ្សេងៗ»* (១ពេត្រុស ១:៦)។

២. ព្រះជាម្ចាស់ជ្រើសរើសការលំបាកណាមួយដាក់មកលើយើង ដែលសមបំផុតទៅនឹងអត្តចរិតរបស់យើង។ ព្រះអង្គតែងតែដកហូតសេចក្តីកំសាន្តចិត្តដែលធ្វើឲ្យយើងចំណាយពេលជាច្រើន និង ទាញយើងចេញពីសេចក្តីស្រឡាញ់ និង សេចក្តីសប្បាយរីករាយក្នុងព្រះជាម្ចាស់ ទ្រង់មានលក្ខណៈដូចជាគ្រូពេទ្យ ដែលស្គាល់ក៏រិតថ្នាំត្រូវប្រើជាមួយ

អ្នកជំងឺ។ *«ទ្រង់បានធ្វើទោសដល់គេ តាមព្រះហឫទ័យសន្តោសវិញ ដោយបណ្តោញគេទៅ គឺទ្រង់បានផាត់គេចេញ ដោយខ្យល់គំហុក របស់ទ្រង់ នៅថ្ងៃដែលខ្យល់ពីទិសខាងកើតបក់មក ដូច្នេះអំពើទុច្ចរិត របស់ពួកយ៉ាកុបនឹងបានជំរះ»* (អេសាយ ២៧:៨, ៩)។

៣. នៅពេលដែលទុក្ខលំបាកនោះបានបំបែរចិត្តយើង ឲ្យទាស់ប្រឆាំងនឹងអំពើបាប តែមិនប្រឆាំងនឹងព្រះ នោះជាសញ្ញាដ៏ល្អ។ មនុស្សអាក្រក់ដែលមានទុក្ខលំបាកដ៏ខ្លាំង គេបែរជាទាស់ប្រឆាំងនឹងព្រះជាម្ចាស់។ *«មនុស្សលោកក៏ត្រូវខ្លោចទៅដោយអំណាចក្តៅជាខ្លាំង...គឺគេប្រមាថដល់ព្រះនាមព្រះ ដែលមានអំណាចលើសេចក្តីវេទនាទាំងនោះវិញ»* (វិវរណៈ ១៦:៩)។ ប៉ុន្តែ អ្នកដែលគោរពប្រតិបត្តិព្រះជាម្ចាស់ តែងបន្ទោសខ្លួនឯង ហើយសរសើរសិរីរុងរឿងដល់ព្រះជាម្ចាស់វិញ *«ឱព្រះអម្ចាស់អើយ សេចក្តីសុចរិតជារបស់ផងទ្រង់ហើយ តែខាងយើងខ្ញុំមានតែសេចក្តីជ្រប់មុខវិញ ដូចជាសព្វថ្ងៃនេះ»* (ដានីយ៉ែល ៩:៧)។

៤. នៅពេលដែលការលំបាកលាងសំអាតចិត្តពីបាប ហើយធ្វើឲ្យជីវិតរបស់គេកាន់តែបរិសុទ្ធសមនឹងនគរស្ថានសួគ៌ និង ចេះបន្ទាបខ្លួនជាងមុន នោះជាសញ្ញាដ៏ពិតប្រាកដដែលថា ការលំបាកទាំងនេះបានមកពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ តើគ្រីស្ទបរិស័ទប៉ុន្មាននាក់ដឹងថា ការនេះកើតឡើងជាពិតប្រាកដនោះ! ក្រោយពីគេបានឆ្លងកាត់ការលំបាកធំៗមួយចំនួនមក គេលែងស្រឡាញ់លោកិយទៀត ដូច្នេះអ្វីៗដែលនៅក្នុងលោកិយ នោះលែងមានប្រយោជន៍ចំពោះគេទៀតហើយ។ គួរឲ្យក្រៀមក្រំណាស់ ដែលឥទ្ធិពលល្អទាំងនោះមិនមានតទៅទៀត ដោយហេតុនេះហើយ បានជាព្រះជាម្ចាស់ទ្រង់ប្រៀនប្រដៅរាស្ត្រទ្រង់ ម្តងហើយម្តងទៀត។

៥. គ្រប់យ៉ាងដែលជួយយើងឲ្យកើនសេចក្ដីស្រឡាញ់ ចំពោះព្រះជាម្ចាស់ត្រូវតែកើតចេញពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះយើង។ ប្រសិនបើព្រះគុណរបស់ទ្រង់សណ្ឋិតនៅក្នុងចិត្តយើង នោះយើងនឹងនៅកៀកជាមួយទ្រង់ នៅពេលយើងមានការលំបាក។ យើងនឹងប្រកាន់កិរិយាដូចជាអ្នកនិពន្ធទំនុកដំកើងដែលនិយាយថា *«ការទាំងនោះបានកើតដល់យើងខ្ញុំហើយ ប៉ុន្តែយើងខ្ញុំមិនបានភ្លេចទ្រង់ឡើយ... ចិត្តយើងខ្ញុំមិនបានថយត្រឡប់ទេ ជំហាននៃយើងខ្ញុំក៏មិនបានទាសចេញពីផ្លូវទ្រង់ដែរ ទោះបើទ្រង់... គ្របយើងខ្ញុំដោយម្លប់នៃសេចក្ដីស្លាប់ក៏ដោយ»* (ទំនុកដំកើង ៤៤:១៧-១៩)។

៦. យើងដឹងថា ព្រះជាម្ចាស់ប្រទានពរដល់យើងក្នុងកាលដែលយើងមានទុក្ខ ខណៈដែលទ្រង់បង្រៀនយើងពីសេចក្ដីអាក្រក់របស់អំពើបាប ពីភាពទទេស្អាតនៃជីវិត និង ពីភាពពិតប្រាកដរបស់សេចក្ដីទាំងនោះដែលមិនអាចនឹងផ្លាស់ប្ដូរបាន *«ឱព្រះយេហូវ៉ាអើយ មានពរហើយមនុស្សណាដែលទ្រង់វាយផ្ចាលហើយបង្ហាត់បង្រៀនតាមក្រិត្យវិន័យទ្រង់ផង»* (ទំនុកដំកើង ៩៤:១២)។ នៅពេលដែលគ្រីស្ទបរិស័ទទទួលការប្រៀនប្រដៅពីព្រះជាម្ចាស់ នោះនាំឲ្យគេមើលឃើញពីព្រះពររបស់ព្រះជាម្ចាស់កាន់តែច្បាស់ឡើង។

**ខ.** ទីពីរ សូមឲ្យយើងក្រឡេកមើលព្រឹត្តិការណ៍ដែលនាំឲ្យយើងមានសេចក្ដីអំណារ និង សុភមង្គល។ កាលៈទេសៈដែលមានសេចក្ដីសុខសាន្ត និង សប្បាយ មិនមែនមានន័យថា ព្រះពររបស់ព្រះអង្គនៅក្នុងកាលៈទេសៈនោះទេ។ ជោគជ័យ ឬភាពចម្រើនដែលធ្វើឲ្យមនុស្សភ្លេចព្រះ ឬប្រើដើម្បីធ្វើឲ្យសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាមកម្រើកឡើង ឬមោទនភាពនៅក្នុងចិត្ត នោះមិនមែនជាមធ្យោបាយទទួលព្រះពរទេ។

ប៉ុន្តែ សេចក្តីកំសាន្តចិត្ត និង ក្តីមេត្តាទាំងនោះ បានបន្ទាបព្រលឹងយើងនៅចំពោះព្រះ ដោយផ្តល់ឲ្យភាពគ្មានតម្លៃ ក្លាយទៅជាព្រះពរវិញ។ លោកយ៉ាកុបនិយាយថា *«ទូលបង្គំមិនគួរឲ្យបានអស់ទាំងសេចក្តីសប្បុរស នឹងអស់ទាំងសេចក្តីស្មោះត្រង់ ដែលទ្រង់បានផ្តល់មកទូលបង្គំជាអ្នកបម្រើទ្រង់ទេ»* (លោកុប្បត្តិ ៣២:១០)។ សេចក្តីមេត្តាដូច្នេះ ធ្វើឲ្យយើងនៅឆ្ងាយពីអំពើបាប និង ឲ្យយើងមានសេចក្តីស្រឡាញ់ដល់ព្រះកាន់តែច្រើនឡើង។ សេចក្តីមេត្តាតែមួយមុខ មិនដែលធ្វើឲ្យយើងស្អប់ចិត្តនោះទេ។ បើយើងមានលទ្ធភាពបម្រើព្រះដោយក្តីពេញចិត្ត ដោយសារតែសេចក្តីកំសាន្តរបស់យើង និង កង្វល់ជាច្រើនពីសេចក្តីត្រូវការរបស់អ្នកដទៃ នោះជាសញ្ញាពិតប្រាកដថា ព្រះជាម្ចាស់កំពុងតែប្រទានសេចក្តីកំសាន្តដល់យើងមែន។ ជាថ្មីម្តងទៀត នោះជាការពិតដែលថា បើយើងបានទទួលការល្អជាចម្លើយតបពីសេចក្តីអធិស្ឋានរបស់យើង ការនោះបានមកដល់យើងដោយសារសេចក្តីស្រឡាញ់របស់ទ្រង់។

**៤. នៅពេលដែលព្រះតម្រិះសម្រេច បាននាំឱ្យយើងមានការផ្លាស់ប្តូរជាច្រើននៅក្នុងជីវិតយើង តើយើងអាចមានវិញ្ញាណដែលស្ថិតស្ថេរ និង ស្ងប់ស្ងាត់ដោយរបៀបណា?**

ព្រះតម្រិះសម្រេច បណ្តាលឲ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់មនុស្សគ្រប់ជាតិសាសន៍ក្នុងពិភពលោកនេះ។ *«ទ្រង់ចំរើនសាសន៍ទាំងប៉ុន្មាន ហើយក៏បំផ្លាញគេវិញ ទ្រង់ពង្រីកឲ្យគេធំឡើង រួចក៏ដឹកនាំគេទៅជាឈ្លើយ»* (យ៉ូប ១២:២៣)។ មានមនុស្សជាច្រើនមានលក្ខណៈដូចជាន៉ាអូមី ដែលស្ថានភាពបានផ្លាស់ប្តូរយ៉ាងចម្លែក ធ្វើឲ្យពួកបណ្តាជននៅក្រុងបេថ្លេហិមនិយាយថា *«នេះតើជាន៉ាអូមីមែនឬអី?»* (នាងរស់ ១:១៩)។

កំដៅ និង ភាពត្រជាក់ សាកល្បងសុខភាព និង កម្លាំងរបស់រូបកាយយើង ដូច្នេះ ការផ្លាស់ប្តូរក្នុងជីវិតយើងកើតឡើងដោយសារព្រះតម្រិះសម្រេច ដែលសាកល្បង កម្លាំងនៃព្រះគុណព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើង។ ស្តេចហេសេគាជាមនុស្សល្អ ប៉ុន្តែភាពកំសោយរបស់ទ្រង់ក៏បានលេចឡើងមក នៅពេលដែលព្រះតម្រិះសម្រេច នាំទ្រង់ឲ្យមានការឈឺចាប់ និង មានជំងឺ (អេសាយ ជំពូក៣៨)។ វិញ្ញាណរបស់ស្តេច ដាវីឌមិនដែលស្កប់ និង ស្រួលឡើយ ខណៈដែលភាពគ្រោះថ្នាក់នៅព័ទ្ធជុំវិញទ្រង់នោះ ទ្រង់ប្រាប់យើងថា *«ក្នុងគ្រានៃសេចក្តីចំរើនរបស់ទូលបង្គំ ទូលបង្គំមិនត្រូវរង្គើ ឡើយ... កាលទ្រង់បានលាក់ព្រះភក្ត្រទៅ នោះទូលបង្គំមានសេចក្តីតក់ស្លុត»* (ទំនុក ដំកើង ៣០:៦, ៧)។ លោកប៉ុលពិតជាមានព្រះគុណជាបរិបូរណ៍ ហើយខណៈនោះគាត់ និយាយថា *«ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយ ដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ»* (ភីលីព ៤:១២)។

សូមឲ្យយើងគិតពិចារណាថែមទៀត ពីរបៀបដែលយើងអាចមានសន្តិភាព នៅ ក្នុងចិត្ត និង គំនិតរបស់យើង ក្នុងគ្រប់កាលៈទេសៈទាំងអស់។

**ក.** នៅពេលដែលកាលៈទេសៈនោះងាយស្រួល យើងតែងតែចាំបានថា ការទាំង អស់អាចផ្លាស់ប្តូរបានយ៉ាងឆាប់រហ័ស។ ការដែលអ្នកសប្បាយចិត្តក្នុង កិត្តិយសនៅថ្ងៃនេះ ប្រហែលមិនមែនជារបស់អ្នកទៀតទេ នៅថ្ងៃស្អែក។ ព្រះបន្ទូលសំដែងថា *«ដ្បិតទ្រព្យសម្បត្តិតែងតែដុះស្លាបជាមិនខាន ក៏នឹង ហើរទៅលើមេឃ បែបដូចជាឥន្ទ្រី»* (សុភាសិត ២៣:៥)។ ស្តេចហេសេគា មានភាពរុងរឿងដោយសារទ្រព្យសម្បត្តិរបស់ទ្រង់ តែហោរាអេសាយបាន ទូលទ្រង់ថា មិនយូរប៉ុន្មានទ្រង់នឹងបាត់បង់ទ្រព្យសម្បត្តិនោះទាំងអស់វិញ

(អេសាយ ៣៩:២-៧)។ អ្នកមិនដឹងថា មានសេចក្តីអាក្រក់អ្វីនៅក្នុងចិត្តរបស់អ្នកទេ ទាល់តែព្រះតម្រិះសម្រេចធ្វើឲ្យអ្នកដឹងថា អ្នកស្រឡាញ់ព្រះជាម្ចាស់តិចប៉ុណ្ណា ហើយអ្នកនៅតែស្រឡាញ់របស់នៅលោកិយនេះប៉ុណ្ណា កាលដែលអ្នកនៅក្រជាងសព្វថ្ងៃនេះ តើអ្នកមិនស្គាល់ព្រះជាម្ចាស់ និង មិនស្រឡាញ់ទ្រង់ជាងនេះទេឬអី?

**ខ.** នៅពេលដែលគ្រប់យ៉ាងទាស់ប្រឆាំងនឹងយើង នោះយើងប្រហែលជាប្តូរទៅតាមផ្លូវផ្សេងវិញ ហើយត្រូវការជំនួយដើម្បីឲ្យចិត្តយើងបានស្ថិតស្ថេរ។ ព្រះតម្រិះសម្រេចដែលនាំឲ្យមានទុក្ខលំបាក និង សេចក្តីសោកសង្រេងដែលយើងជួបប្រទះនោះ មានប្រយោជន៍សម្រាប់រាស្ត្រទ្រង់។ ជាការពិត រាស្ត្ររបស់ទ្រង់មិនអាចរស់នៅខាងព្រលឹងវិញ្ញាណដោយគ្មានសេចក្តីលំបាក និង សោកសៅទាំងនោះបានទេ។ គ្រីស្ទបរិស័ទដែលមានជំនឿរឹងមាំមិនយូរប៉ុន្មានក៏ឃើញថា ការទំនាក់ទំនងស្និទ្ធស្នាលជាមួយព្រះនៃព្រលឹងគាត់ នឹងចាប់ផ្តើមចុះខ្សោយ ប្រសិនបើគាត់គ្មានការលំបាកនោះ។ ប៉ុន្តែ គ្មានអ្វីមួយដែលញែករាស្ត្ររបស់ទ្រង់ចេញពីព្រះគ្រីស្ទបានឡើយ ព្រះបន្ទូលសំដែងថា *«តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន តើសេចក្តីទុក្ខលំបាកឬ?»* (រ៉ូម ៨:៣៥)។ លោកយ៉ូបរកឃើញថា ការនេះពិតប្រាកដមែន (យ៉ូប ១៩:២៥)។ ថ្ងៃនៃសេចក្តីទុក្ខលំបាកដ៏វែង វាមានទីបញ្ចប់ ហើយបើសិនអ្នកមានទុក្ខលំបាកមួយពាន់ នោះវាក៏នឹងមានទីបញ្ចប់ដែរ ដូចជាលោកប៉ុលមានប្រសាសន៍ថា *«ដ្បិតសេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ»* (២កូរិនថូស ៤:១៧)។

**ត.** នៅពេលដែលគ្រប់យ៉ាងហាក់ដូចជាមិនពិតប្រាកដ ហើយយើងមិនដឹងថា ព្រះតម្រិះសម្រេចរបស់ព្រះជាម្ចាស់នឹងធ្វើកិច្ចការរបស់ទ្រង់តាមវិធីណា នោះ ការដែលយើងរវល់ជាមួយនឹងការខ្វល់ខ្វាយ និង ការថប់បារម្ភ នៅក្នុងស្ថាន ភាពមិនពិតប្រាកដបែបនេះ ជាការឥតប្រយោជន៍ទទេ ដូចជាព្រះបន្ទូលបាន សម្ដែងថា *«ចុះនៅក្នុងពួកអ្នករាល់គ្នា តើមានអ្នកឯណាដែលអាចនឹង បន្ថែមកំពស់ខ្លួន១ហត្ថ ដោយសារសេចក្តីខ្វល់ខ្វាយបានឬទេ?»* (ម៉ាថាយ ៦:២៧)។ នៅពេលយើងមានសេចក្តីខ្វល់ខ្វាយមិនត្រឹមត្រូវ យើងនឹងបាត់បង់ សន្តិភាព ហើយក៏ពន្លិចចិត្តរបស់យើងផងដែរ។ យើងមិនអាចផ្លាស់ប្តូរអ្វីនៅ ក្នុងកាលៈទេសៈរបស់យើងបានទេ ផ្ទុយទៅវិញ យើងគួរតែជៀសវាងទុក្ខ លំបាក និង ការឈឺចាប់ ហើយរង់ចាំដោយស្ងៀមស្ងាត់ រហូតដល់យើង មើលឃើញរបៀបរបស់ព្រះតម្រិះសម្រេច កំពុងតែសម្រេចព្រះហឫទ័យ របស់ទ្រង់នៅក្នុងជីវិតយើង។គំនិតរបស់យើងអាចសម្រាកដោយទុកចិត្តនៅ ក្នុងសេចក្តីស្មោះត្រង់របស់ព្រះ។ យើងមានឥទ្ធិឫទ្ធិនៃព្រះបន្ទូលព្រះជាម្ចាស់ ដែលថា ទ្រង់ត្រូវធ្វើឲ្យសេចក្តីខ្វល់ខ្វាយរបស់យើង ប្រែទៅជាក្តីសប្បាយ រីករាយវិញ។ មិនត្រឹមតែសេចក្តីសង្គ្រោះដ៏នៅអស់កល្បរបស់យើងទេ តែគឺ គ្រប់ទាំងសេចក្តីត្រូវការរបស់យើងនៅក្នុងលោកិយនេះ ក៏មានសុវត្ថិភាពនៅ ក្នុងព្រះហស្តទ្រង់ដែរ។ ដូច្នេះ ចូរស្ងៀមស្ងាត់នៅក្នុងលទ្ធផលសប្បាយរីករាយ ពិតប្រាកដ ដែលនឹងមកក្រោយការលំបាកនៅសព្វថ្ងៃនេះ *«ចូរទុកដាក់អស់ ទាំងការឯង នៅនឹងព្រះយេហូវ៉ាចុះ នោះអស់ទាំងគំនិតរបស់ឯងនឹងបាន សម្រេច»* (សុភាសិត ១៦:៣)។

**៥• ទីបំផុត នៅពេលគ្រីស្ទបរិស័ទឃើញការលំបាក និង ទុក្ខសោក កំពុងតែឈាន មករកពួកគេ តើគេអាចទទួលយកព្រះហឫទ័យទ្រង់ដោយរបៀបណា?**

ទោះបីជាមានបញ្ហាលំបាកយ៉ាងណា យើងអាចធ្វើបានតាមរយៈព្រះគ្រីស្ទដែល

បានចំរើនកំឡាំងដល់យើង (ភីលីព ៤:១៣)។ ប៉ុន្តែបើគ្មានទ្រង់ទេ នោះយើងមិនអាចធ្វើអ្វីបានឡើយ (យ៉ូហាន ១៥:៥)។ ព្រះអង្គមិនបានមានបន្ទូលថា «បើសិនជាគ្មានយើងទេ ឯងអាចធ្វើបានបន្តិច» ប៉ុន្តែទ្រង់បានមានបន្ទូលថា «បើសិនជាគ្មានយើងទេ ឯងនឹងមិនអាចធ្វើអ្វីបានទាំងអស់»។ ប្រហែលជាជំងឺនៅក្នុងខ្លួនយើង ឬក្នុងគ្រួសារយើងកាន់តែធ្ងន់ទៅ ហើយយើងខ្លាចចុងបំផុតនៃសេចក្តីស្លាប់នោះ ឬយើងបារម្ភថាសង្គ្រាមអាចកើតឡើង ហើយបាត់សេចក្តីសុខសាន្តទាំងអស់របស់អ្នក។ យើងត្រៀមខ្លួនរួចជាស្រេច ដើម្បីនិយាយដូចជាស្ត្រីមេម៉ាយម្នាក់ដែលបាននិយាយទៅលោកអេលីយ៉ាថា *«ឱអ្នកសំណប់របស់ព្រះអើយ តើខ្ញុំនឹងលោកមានការណ៍អ្វីនឹងគ្នា លោកបានមកឯណេះ ដើម្បីរំលឹកពីអំពើបាបរបស់ខ្ញុំ ហើយនឹងសំឡាប់កូនខ្ញុំឬ?»* (១ពង្សាវតារក្សត្រ ១៧:១៨)។ កាលណាសាតាំងវាឆ្លៀតយកប្រយោជន៍ពីចិត្តនៃអំពើបាបរបស់យើង ហើយធ្វើឲ្យគំនិតយើងកាន់តែវេទនា ដោយវាបន្ថែមយោបល់របស់វា យើងក៏មិនអាចដឹងថា នោះជាគំនិតរបស់យើង ឬជាគំនិតរបស់វាទេ។ ព្រលឹងវិញ្ញាណរបស់យើងកាន់តែខ្សោយទៅ ដូចជាមនុស្សដែលសម្រាកមិនបានពេញមួយយប់ ដោយគិតពីការធ្វើដំណើរដ៏លំបាករបស់គាត់នៅថ្ងៃបន្ទាប់ ហើយពេលដល់ថ្ងៃស្អែកឡើង គាត់ក៏សន្លប់នៅពាក់កណ្តាលផ្លូវ ដោយសារសម្រាកមិនគ្រប់គ្រាន់ពីយប់មុន។

ការសំខាន់បំផុតរបស់គ្រីស្ទបរិស័ទគឺឲ្យមានចិត្តទទួលយកព្រះហឫទ័យរបស់ព្រះ ហើយថ្វាយលទ្ធផលនៃរាល់ព្រឹត្តិការណ៍ទាំងអស់ ទៅទ្រង់វិញដោយសង្ឃឹម និងស្ងប់ចិត្ត។ តាមវិធីនេះ ស្តេចដាវីឌមានបន្ទូលទៅកាន់សាដុក ដែលជាសម្តេចសង្ឃថា *«ចូរនាំយកហឹបនៃព្រះត្រឡប់ទៅឯទីក្រុងវិញទៅ បើសិនជាយើងនឹងបានប្រកបដោយព្រះគុណនៃព្រះយេហូវ៉ា នោះមុខជាទ្រង់នឹងនាំយើងមកវិញ ឲ្យបានឃើញទាំងហឹបនេះ នឹងទីលំនៅរបស់ទ្រង់ផង។ តែបើទ្រង់មានបន្ទូលមកដូច្នេះថា អញមិនសព្វព្រះហឫទ័យនឹងឯងទេ នោះមើល យើងនេះហើយ សូមទ្រង់ប្រព្រឹត្តនឹងយើងតាមព្រះហឫទ័យចុះ»* (២សាំយូអែល ១៥:២៥- ២៦) នេះជាអាកប្បកិរិយាខាង

ព្រលឹងវិញ្ញាណដ៏ល្អណាស់ ដែលយើងត្រូវធ្វើតាម។ ប៉ុន្តែ ការបោះបង់ឆន្ទៈរបស់យើង ថ្វាយទៅព្រះជាម្ចាស់នោះ គឺជាការពិបាកមែន។ យើងប្រាកដថានឹងមានសន្តិភាព បើសិនជាយើង អាចនាំចិត្តយើងឲ្យធ្វើដូចជានេះ។ យើងនឹងទទួលជំនួយដើម្បីធ្វើការនោះ ដោយសារជំនួយរបស់ព្រះ បើយើងប្រើសំណួមខាងក្រោមនេះ ៖

**ក.** ព្យាយាមឲ្យបានយល់ជ្រៅ និង ខ្ជាប់ខ្ជួនអំពីព្រះតម្រិះរបស់ព្រះ ហើយពីភាពឆោតល្ងង់របស់យើង ព្រមទាំងការបដិសេធន៍របស់យើងផង។ *«ប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់»* (ទំនុកដំកើង ១៤៧:៥)។ *«ព្រះតម្រិះទ្រង់ក៏ជ្រៅណាស់ផង»* (ទំនុកដំកើង ៩២:៥)។ យើងបាននិយាយជាញឹកញយថា យោបល់របស់យើងមិនត្រឹមត្រូវ ហើយយើងក៏បានធ្វើកំហុសច្រើនដែរ! អ្នកដទៃផ្សេងទៀតដែលជាមនុស្សមានប្រាជ្ញា និង មានជំនាញច្រើនជាងយើង ដូចជាវេជ្ជបណ្ឌិត ឬមេធាវីជាដើម បានដឹកនាំយើងជាញឹកញាប់។ ដូច្នេះ យើងគួរបោះបង់ចោលមូលហេតុបែបមនុស្ស និង ការយល់ដឹងតិចតួចចំពោះព្រះដ៏អស្ចារ្យ ទ្រង់មានគ្រប់អំណាច ហើយជ្រាបដឹង និង មានប្រាជ្ញាឆ្លាតគ្រប់ទាំងអស់។ មានតែអំនួតទេ ដែលធ្វើឲ្យយើងពិបាកនឹងថ្វាយការនេះទៅព្រះជាម្ចាស់។

**ខ.** សូមពិចារណាដោយប្រុងប្រយ័ត្ន ពីអំពើបាបនៃការនាំសេចក្ដីវេទនាមកលើខ្លួនឯងដោយគំនិតដែលខ្វល់ខ្វាយ ពីព្រោះអ្នកសង្ស័យខ្លះបាននិយាយថា ប្រហែលជាព្រះតម្រិះសម្រេចមិនអាចធ្វើការល្អចំពោះអ្នកទេ។ គំនិតទាំងនេះជាលទ្ធផលនៃអំនួត និង ការមិនជឿ ហើយក៏ជាការឥតប្រយោជន៍សម្រាប់យើងដែរ។ យើងមិនអាចទាញព្រះជាម្ចាស់ចេញពីព្រះបល្ល័យទ្រង់បានទេ ហើយយើងក៏មិនគួរសង្ស័យពីភាពល្អរបស់ទ្រង់ដែរ។

**គ.** នៅក្នុងព្រះគម្ពីរមានឧទាហរណ៍ដែលនិយាយអំពី អ្នកដែលបានលះបង់ជីវិតដើម្បីដើរតាមព្រះហឫទ័យទ្រង់ ច្រើនជាងអ្វីដែលអ្នកបានធ្វើទៅទៀត។ នៅពេលដែលព្រះជាម្ចាស់ ហៅលោកអ័ប្រាហាំឲ្យចេញពីស្រុកកំណើតរបស់គាត់ ទៅរស់នៅកន្លែងមួយផ្សេងទៀតដែលគាត់មិនដឹងទាល់តែសោះ តែគាត់បានធ្វើតាមទ្រង់ភ្លាម។ លោកប៉ុលដឹងថា នៅពេលគាត់ធ្វើដំណើរទៅកាន់ក្រុងយេរូសាឡិម គាត់នឹងជួបគ្រោះថ្នាក់យ៉ាងខ្លាំងដូចជាជាប់គុក និង សេចក្ដីស្លាប់ ប៉ុន្តែគាត់ និង គ្រីស្ទបរិស័ទដែលគាត់ដោះលែងនោះក៏អាចនិយាយថា *«សូមតាមព្រះហឫទ័យព្រះអម្ចាស់ចុះ»* (កិច្ចការ ២១:១៤)។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅតែជាគំរូដ៏ល្អបំផុតសម្រាប់យើង នៅពេលដែលព្រះវរបិតាប្រទានពែងនៃសេចក្ដីរងទុក្ខទៅក្នុងព្រះហស្តទ្រង់ ក្នុងសួនច្បារគែតសេម៉ានីជាពែងនៃសេចក្ដីក្រោធរបស់ព្រះ និង ដ៏រន្ធត់។ ភាពសោកសៅរបស់ព្រះគ្រីស្ទនេះ បានធ្វើឲ្យទ្រង់ស្រែកឡើងថា *«ឱអ័ប្បា ព្រះវរបិតាអើយ ទ្រង់អាចនឹងធ្វើការទាំងអស់កើត សូមយកពែងនេះចេញពីទូលបង្គំផង»* (ម៉ាកុស ១៤:៣៦) តែការថ្វាយទៅកាន់ព្រះវរបិតានោះ ទ្រង់មានបន្ទូលថា *«ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមសម្រេចតាមព្រះហឫទ័យទ្រង់វិញ»* (ម៉ាកុស ១៤:៣៦)។ តើអ្នកស្ថិតក្នុងស្ថានភាពបែបយ៉ាងណា បើប្រៀបធៀបទៅនឹងស្ថានភាពរបស់ព្រះយេស៊ូវនោះ?

**ឃ.** សូមគិតពីអត្ថប្រយោជន៍ដ៏ពិសេសរបស់ឆន្ទៈ ដែលធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់។ មានសេចក្ដីសន្តោសក្រៃលែងដូចជាថ្ងៃសម្រាកម្យ៉ាង នៅក្នុងព្រលឹងរបស់មនុស្សដែលទទួលយកព្រះហឫទ័យទ្រង់ទាំងស្រុង សម្រាប់ជីវិតរបស់ខ្លួន។ លោក ម៉ាធិន លូធើ (Martin Luther) ជាអ្នកបង្កើតចលនាសាសនានៃក្រុមជំនុំប្រូតេស្តង់ បាននិយាយទៅកាន់អ្នកដែលមានភាពខ្វល់ខ្វាយយ៉ាងខ្លាំងនៅក្នុងព្រលឹងវិញ្ញាណរបស់គេថា «ព្រះអម្ចាស់ទ្រង់ធ្វើគ្រប់

ការសម្រាប់អ្នកហើយ អ្នកមិនចាំបាច់ធ្វើអ្វីទាំងអស់ គ្រាន់តែធ្វើជាថ្ងៃឈប់សម្រាករបស់ព្រះគ្រីស្ទវិញ»។ តាមវិធីនេះហើយដែលព្រះអម្ចាស់ «*ប្រោសប្រទានឲ្យពួកស្ងួនភ្ងាររបស់ទ្រង់ បានដេកលក់សប្បាយ*» (ទំនុកដំកើង ១២៧:២) ទោះបីជាអ្នកដែលជឿព្រះអង្គរស់នៅក្នុងការលំបាកជាច្រើនក៏ដោយ គេក៏បានរក្សាខ្លួនគេនៅក្នុងជំនឿដោយសេចក្តីសុខសាន្ត ដូចជាគេដេកលក់យ៉ាងស្រួល។ អាកប្បកិរិយាដែលចុះចូលចំពោះព្រះជាម្ចាស់ នោះធ្វើឲ្យព្រលឹងមនុស្សអាចប្រកបដោយស្និទ្ធស្នាលជាមួយនឹងព្រះបាន ហើយព្រះពរក៏នៅជិតពួកគេដែរ។ ដូច្នេះសូមកុំមានការសោកស្តាយទៀត កុំមានការឈ្លោះទៀត តែសម្រាកយ៉ាងស្ងប់នៅទៀបព្រះបាទរបស់ព្រះវរបិតាវិញ ហើយនិយាយគ្រប់កាលៈទេសៈ និង គ្រប់ពេលវេលាទាំងអស់ថា «សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេច»។

# ចំណារបន្ថែម

ដោយសារយើងមិនអាចចងចាំបានល្អ នៅពេលយើងអានព្រះគម្ពីរ

ជាផែនការល្អ បើយើងសរសេរទុក

ពីវិធីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងព្រះតម្រិះសម្រេច។

ការធ្វើបែបនេះ នឹងជួយយើងឲ្យចេះប្រៀបធៀប

ពីបទពិសោធន៍នៅពេលបច្ចុប្បន្នរបស់យើង ទៅនឹងបទពិសោធន៍ពីអតីតកាល

ហើយរក្សាតម្លៃនៃបទពិសោធន៍ទាំងនោះ សម្រាប់អនាគតកាលផង។

## បញ្ជីឈ្មោះសៀវភៅទាំងមូល

## សៀវភៅលំហាត់ កូនសៀវភៅខិតប័ណ្ណ និង លិខិតដែលបោះពុម្ពដោយ

**ក្រេសផាប្លីខេសិន ត្រាស** (GRACE PUBLICATIONS TRUST)

**(ដោយរួមបញ្ចូលទាំង «ចំរៀងពីព្រះគុណ»)**

**ដែលអាចទទួលយកពីលេខាធិការ**

**ក្រេសផាប្លីខេសិន ត្រាស**

**ផ្លូវលេខ១៣៩ ក្រូសវ៉ែន័រ, ទីក្រុងឡុង, អិន៥ ២អិនអេច**

Grace Publications Trust,

139 Grosvenor Avenue,

London, N5 2NH.

# សៀវភៅគ្រីស្ទបរិស័ទវណ្ណៈគតិមិនប្រែប្រួល

## លំដាប់លេខ២ «ព្រះហឫទ័យរបស់ព្រះ»

លោក ចន ហ្វាវែល កើតនៅឆ្នាំ១៦២៨ ហើយទទួលមរណភាពនៅឆ្នាំ ១៦៩១។ លោកជាកូនរបស់គ្រូគង្វាលម្នាក់ ដែលបានស្លាប់ក្នុងគុក ដោយសារគំនិតមិនចុះសម្រុងគ្នាជាមួយគេឯង។ នៅឆ្នាំ១៦៥៦ បន្ទាប់ពីការសិក្សានៅសកលវិទ្យាល័យអ័ក្សហ្វឺត លោកហ្វាវែលបានទទួលការអញ្ជើញឲ្យធ្វើជាគ្រូគង្វាលនៃក្រុមជំនុំមួយ នៅក្រុងដាតម៉ោស្ស ស្រុកដេវ៉ុន ជាកន្លែងដែលលោកបានរស់នៅភាគច្រើននៃជីវិតរបស់លោក។ ទោះបីជាច្បាប់នៅឆ្នាំ១៦៦២ បានប្រកាសថា ព័ន្ធកិច្ចសាធារណៈរបស់លោកខុសច្បាប់ក៏ដោយ ក៏លោកនៅតែបន្តការអធិប្បាយ និង ការនិពន្ធ នៅក្រោមសំពាធនៃការបៀតបៀនដែរ។

លោក ចន ហ្វាវែល មានសមត្ថភាពពិសេសដែលអាចបកបញ្ចូលសំណេររបស់លោក ឲ្យប៉ះពាល់យ៉ាងជ្រៅដល់ចិត្ត និង គំនិតអ្នកអាន។ សៀវភៅរបស់លោកដែលមានប្រជាប្រិយភាពនោះ មានចំណងជើងថា *«គ្មានការសង្ស័យ»* រីឯសៀវភៅដែលមានចំណងជើងថា *«ការប្រតិបត្តិនៃព្រះ ឬ អាថ៌កំបាំងនៃព្រះតម្រិះសម្រេច»* នោះបានបោះពុម្ពនៅឆ្នាំ១៦៧៧ ហើយគេបានយកសៀវភៅនេះមករៀបចំឡើងវិញ ដើម្បីឲ្យស្រួលអាន។

# អ្វីដែលយើងចង់បានពីលោកអ្នក!

*សូមជំរាបយើងខ្ញុំឲ្យបានដឹងថា*

សៀវភៅនេះបានផ្តល់ចំណេះដឹងយ៉ាងណា

ហើយអ្នកបានទទួលអ្វីខ្លះ

ជាប្រយោជន៍សំរាប់ការរស់នៅរបស់អ្នក!

សូមទាក់ទងមកការិយាល័យយើងខ្ញុំតាម :

ទូរស័ព្ទលេខ : ០២៣-៨៨៣.៨៩៥

សារអេឡិចត្រូនិច : fountofwisdom@online.com.kh

គេហទំព័រ : www.fountofwisdomph.com

យើងខ្ញុំរីករាយនឹងទទួលគំនិត ព្រមទាំងយោបល់ផ្សេងៗ

ដើម្បីកែលំអសៀវភៅនេះ

ឲ្យមានភាពកាន់តែប្រសើរឡើង!




# ធី អ៊ី អ៊ី ជាប្រភពរបស់អ្នកសំរាប់ បង្ហាត់បង្រៀនសិស្ស និងហ្វឹកហ្វឺនក្រុមជំនុំ។

សមាគម ការសិក្សាវិជ្ជាព្រះតាមមូលដ្ឋាន កម្ពុជា ហៅកាត់ថា ធីអ៊ីអ៊ី មានកម្មវិធីសិក្សាសំរាប់ជួយបណ្តុះបណ្តាលអ្នក ឱ្យក្លាយជាអ្នកដឹកនាំក្រុមជំនុំរបស់ព្រះប្រកបដោយប្រសិទ្ធិភាព។ ឯកសារសិក្សារបស់យើង បានរៀបចំឡើងដោយតំរូវតាមពេលវេលាផ្ទាល់របស់អ្នក និងមានតម្លៃសមរម្យ។ សូមសាកសួរពត៌មានពីការិយាល័យយើងឥឡូវនេះ!

## សមាគម ការសិក្សាវិជ្ជាព្រះតាមមូលដ្ឋាន កម្ពុជា
## បណ្តុះបណ្តាល ប្រដាប់កាយ និង ហ្វឹកហ្វឺនបន្ត

**ការិយាល័យ៖** ផ្ទះលេខ៣៦ ផ្លូវ៣០៧ សង្កាត់បឹងកក់២
ខណ្ឌទួលគោក ភ្នំពេញ
**លេខទូរស័ព្ទ៖** 023 881 050 ឬ 092 192 300
**អ៊ីមែល៖** teeacpp@online.com.kh